ធនាគារ កម្ពុជា អាស៊ី
CAMBODIA ASIA BANK
柬埔寨亚洲银行

របាយការណ៍ប្រចាំឆ្នាំ 2025



អំពីធនាគារ កម្ពុជា អាស៊ី


ចក្ខុវិស័យរបស់យើង

គោលបំណងរបស់ធនាគារ កម្ពុជា អាស៊ី គឺដើម្បីបង្កើនប្រតិបត្តិការរបស់ធនាគារសម្រាប់ចូលរួមកសាងជាតិ និងធានាអោយប្រជាជនកម្ពុជាទទួលបាននូវសេវាធនាគារពាណិជ្ជដែលមានអត្រាការប្រាក់ប្រកួតប្រជែង និងបង្កើនការសន្សំដើម្បីផ្តល់មូលនិធិឱ្យមានកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។

បេសកកម្មរបស់យើង

ធនាគារ កម្ពុជា អាស៊ី នឹងនៅតែជាធនាគារពាណិជ្ជដែលមានភាពរឹងមាំ និងស្ថេរភាព។ តាមរយៈបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈ រួសរាយរាក់ទាក់ សុភាពរាបសា និងមាន ចំណេះដឹង។ យើងនឹងផ្តល់ជូននូវផលិតផល និងសេវាកម្មដែលជាតម្រូវការនៃទីផ្សារដែលស្ថិតនៅក្នុងលក្ខណៈតម្រង់ទិសផ្តល់ជាផលចំណេញដល់ប្រជាជន។ យើងនឹងបន្តភាពខ្លាំងក្នុងការផ្តល់សេវាសម្រាប់អាជីវកម្ម និងផ្នែកទីផ្សារអតិថិជននៅក្នុងតំបន់ពាណិជ្ជកម្មរបស់យើងទាំងមូល។

គុណតម្លៃស្នូល



ចំណុចសំខាន់ៗផ្នែកហិរញ្ញវត្ថុ

គិតត្រឹមបំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ	2025	2024	2023	2022
លទ្ធផលប្រតិបត្តិការ (ពាន់ដុល្លារអាមេរិក)				
ចំណូលពីការប្រាក់ - សុទ្ធ	2,530	2,640	3,706	3,325
ចំណូលមិនមែនការប្រាក់ - សុទ្ធ	3,190	3,168	4,884	4,101
ចំណូលប្រតិបត្តិការសរុប - សុទ្ធ	5,721	5,808	8,591	7,427
ចំណាយប្រតិបត្តិការផ្សេងទៀតសរុប	-7,368	-8,134	-6,407	-6,673
ចំណេញ/(ខាត)ប្រតិបត្តិការមុនការខាតបង់តណាទាន	-1,647	-2,325	2,183	753
ដែលរំពឹងទុក/និងចំណាយពន្ធលើប្រាក់ចំណូល				
ការខាតបង់តណាទានដែលរំពឹងទុក / ការខាតបង់លើឱនភាពចំពោះតណាទាន	-990	95	-626	-128
ចំណេញ/(ខាត)សុទ្ធ	-2,637	-2,482	1,367	719
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ពាន់ដុល្លារអាមេរិក)				
តណាទានដុល	78,546	81,823	83,785	78,763
ប្រាក់ឧបត្ថម្ភសម្រាប់ការខាតបង់តណាទានដែលរំពឹងទុក / ប្រាក់ឧបត្ថម្ភសម្រាប់គណនីជាប់សង្ស័យ	3,187	2,295	2,691	2,065
ទ្រព្យសកម្មសរុប	240,500	258,045	221,432	209,494
ប្រាក់បញ្ញើ	149,931	164,462	128,515	117,682
បំណុលសរុប	157,516	172,423	133,328	122,757
មូលធនសរុប	82,984	85,621	88,104	86,736
សូចនាករលទ្ធផល				
អនុបាតចំណេញ/(ខាត)ធៀបនឹងទ្រព្យសកម្ម (ROA)	-1.10%	-0.96%	0.62%	0.34%
អនុបាតចំណេញ/(ខាត)ធៀបនឹងដើមទុន (ROE)	-3.18%	-2.90%	1.55%	0.83%

សារពីប្រធានក្រុមប្រឹក្សាភិបាល

ក្នុងឱកាសពិនិត្យឡើងវិញនូវសមិទ្ធផលប្រចាំឆ្នាំ២០២៥ យើងខ្ញុំមានមោទនភាពយ៉ាងជ្រាលជ្រៅ និងមានទំនុកចិត្តយ៉ាងមុតមាំចំពោះដំណើរអភិវឌ្ឍន៍ទៅមុខរបស់ធនាគារ កម្ពុជា អាស៊ី។

នាឆ្នាំកន្លងមក គឺជាឆ្នាំដែលពិភពលោកប្រឈមនឹងបរិយាកាសសេដ្ឋកិច្ចដ៏ស្មុគស្មាញ ពោរពេញដោយភាពមិនប្រាកដប្រជា ការប្រែប្រួលនៃសក្តានុពលទីផ្សារ និងការរីរឹឡយ៉ាងឆាប់រហ័សនៃតម្រូវការ និងការរំពឹងទុករបស់អតិថិជន។ ក្នុងបរិបទបែបនេះ សមត្ថភាពរបស់ធនាគារ កម្ពុជា អាស៊ី ក្នុងការរក្សាបាននូវស្ថិរភាព ខណៈពេលបន្តវិនិយោគសម្រាប់អនាគត គឺជាសក្ខីភាពដ៏ច្បាស់លាស់នៃភាពរឹងមាំរបស់ស្ថាប័ន និងយុទ្ធសាស្ត្រដ៏រឹងមាំរបស់យើង។ ទោះបីជាលទ្ធផលហិរញ្ញវត្ថុក្នុងឆ្នាំ២០២៥មានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០២៤ក៏ដោយ យើងខ្ញុំជឿជាក់យ៉ាងមុតមាំថា ក្នុងបរិយាកាសសេដ្ឋកិច្ចដ៏ស្មុគស្មាញបែបនេះ ការរក្សាបាននូវស្ថិរភាព គឺជាទម្រង់មួយនៃភាពរឹងមាំ និងភាពជោគជ័យ។

ឆ្នាំ២០២៥ ក៏ជាឆ្នាំនៃវឌ្ឍនភាពដ៏មានអត្ថន័យផងដែរ។ យើងបានពង្រឹងទំនាក់ទំនងជាមួយអតិថិជន ធ្វើការពង្រីកវិសាលភាពសេវាកម្ម និងបន្តអភិវឌ្ឍសមត្ថភាពផ្នែកឌីជីថលយ៉ាងគួរឱ្យកត់សម្គាល់។ យើងបានកែលម្អប្រព័ន្ធធនាគារចល័តឱ្យកាន់តែទំនើប និងមានប្រសិទ្ធភាព ដើម្បីផ្តល់នូវបទពិសោធន៍សេវាកម្មដែលលឿន រលូន និងងាយស្រួលប្រើប្រាស់ជាងមុន ព្រមទាំងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខសាយប័រ ដើម្បីការពារទំនុកចិត្តរបស់អតិថិជនគ្រប់រូបដែលបានជ្រើសរើសប្រើប្រាស់សេវាកម្មរបស់យើងខ្ញុំ។ ឆ្ពោះទៅកាន់អនាគតខាងមុខ ធនាគារ កម្ពុជា អាស៊ីនឹងត្រូវបានដឹកនាំដោយសសរស្តម្ភយុទ្ធសាស្ត្រស្នូលចំនួនពីរ៖

1. នវានុវត្តន៍ផ្តោតលើអតិថិជន

យើងខ្ញុំនឹងបន្តវិនិយោគលើបច្ចេកវិទ្យាទំនើប ការវិភាគទិន្នន័យ និងបញ្ញាសិប្បនិម្មិត ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីតម្រូវការដែលកំពុងវិវឌ្ឍរបស់អតិថិជន និងឆ្លើយតបឱ្យបានកាន់តែប្រសើរ តាមរយៈការផ្តល់ជូននូវបទពិសោធន៍សេវាធនាគារដែលមានលក្ខណៈផ្ទាល់ខ្លួនយ៉ាងរលូន និងមានសុវត្ថិភាពខ្ពស់នៅគ្រប់បណ្តាញដែលបម្រើសេវាកម្ម។

2. កំណើនប្រកបដោយចីរភាព

ធនាគារ កម្ពុជា អាស៊ីប្តេជ្ញាក្លាយជាធនាគារប្រកបដោយការទទួលខុសត្រូវ។ យើងនឹងពង្រីកលទ្ធភាពផ្តល់ជូនដំណោះស្រាយផ្នែកឥណទានសម្រាប់អាជីវកម្មដើម្បីគាំទ្រ និងផ្តល់អំណាចដល់សហគ្រិន និងសហគ្រាសគ្រប់ទំហំក្នុងការបន្តរីកចម្រើនទៅមុខ បង្កើតឱកាសការងារ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាឱ្យកាន់តែប្រសើរជាងមុន។

យើងខ្ញុំមានសុទិដ្ឋិនិយមយ៉ាងមុតមាំចំពោះអនាគតតទៅមុខទៀតនេះ។ មូលដ្ឋានគ្រឹះដែលយើងបានពង្រឹងបានក្នុងឆ្នាំ២០២៥ បានជួយឲ្យធនាគារយើងខ្ញុំត្រៀមខ្លួនរួចជាស្រេច ក្នុងការបន្តលូតលាស់ជាមួយនឹងគោលដៅច្បាស់លាស់ដែលប្រកបដោយចីរភាព និងគុណតម្លៃ។

ដោយក្តីគោរព



វ៉ា ដាឡុត
ប្រធានក្រុមប្រឹក្សា

សារពីនាយកប្រតិបត្តិ

ឆ្នាំ២០២៥ បានជួយឱ្យយើងផ្តោតកាន់តែខ្លាំង និងពង្រឹងមូលដ្ឋានគ្រឹះត្រៀមខ្លួនសម្រាប់ការរីកចម្រើនទាពេលអនាគត។ បរិយាកាសសេដ្ឋកិច្ចសកលដែលពោរពេញដោយភាពមិនប្រាកដប្រជា ការប្រែប្រួលនៃសក្តានុពលទីផ្សារ និងការរីរឡយ៉ាងឆាប់រហ័សនៃតម្រូវការ និងការរំពឹងទុករបស់អតិថិជន បានទាមទារឱ្យយើងប្រកាន់ខ្ជាប់នូវវិន័យ និងការគ្រប់គ្រងប្រកបដោយការប្រុងប្រយ័ត្នជាជាងការគេចចេញពីបញ្ហាប្រឈម។ ធនាគារ កម្ពុជា អាស៊ី បានឆ្លើយតបចំពោះបរិបទនេះដោយមានទិសដៅច្បាស់លាស់ គ្រប់គ្រងហានិភ័យដោយយកចិត្តទុកដាក់ ឈរជាមួយអតិថិជនដោយរឹងមាំ និងរៀបចំស្ថាប័នឱ្យមានសមត្ថភាពខ្លាំងគ្រប់គ្រាន់សម្រាប់ការរីកចម្រើនប្រកបដោយចីរភាពនាពេលខាងមុខ។ បញ្ហាប្រឈមមិនមែនជាអ្វីដែលកំណត់អត្តសញ្ញាណរបស់យើងនោះទេ ប៉ុន្តែរបៀបដែលយើងឆ្លងកាត់ និងឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនោះ ទើបជាកត្តាដែលបង្ហាញពីភាពរឹងមាំ និងតម្លៃពិតប្រាកដរបស់ស្ថាប័នយើងខ្ញុំ។

ការរក្សាបាននូវភាពរឹងមាំក្នុងឆ្នាំដែលពោរពេញដោយបញ្ហាប្រឈម

ឆ្នាំ២០២៥ យើងខ្ញុំបានបន្តសម្រេចនូវរឱ្ឍនភាពប្រកបដោយអត្ថន័យ និងចេតនាច្បាស់លាស់លើវិស័យសំខាន់ៗ ដែលនឹងកំណត់សមត្ថភាពប្រកួតប្រជែងរបស់ធនាគារយើងខ្ញុំក្នុងរយៈពេលខាងមុខ៖

- **វិន័យហិរញ្ញវត្ថុ**
  យើងខ្ញុំបានរក្សាសុខភាពហិរញ្ញវត្ថុរបស់ធនាគារឱ្យមានភាពរឹងមាំតាមរយៈការគ្រប់គ្រងហានិភ័យយ៉ាងម៉ឺងម៉ាត់ និងការត្រួតពិនិត្យផលប័ត្រឥណទានយ៉ាងសកម្ម។ ការរក្សាទ្រព្យសកម្មឱ្យស្ថិតក្នុងកម្រិតល្អក្នុងបរិបទទីផ្សារឥណទានដែលមានការលំបាកគឺជាអាទិភាពសំខាន់មួយដែលយើងបានអនុវត្តដោយភាពប្រុងប្រយ័ត្ន និងស្ថិរភាព។

- **រឱ្ឍនភាពឌីជីថល**
  យើងបានបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធធនាគារបែបឌីជីថលដោយពង្រឹងមុខងារ ប្រសិទ្ធភាព និងភាពជឿជាក់នៃប្រព័ន្ធសេវាកម្មរបស់យើង។ ការវិនិយោគទាំងនេះនឹងក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការលើកកម្ពស់បទពិសោធន៍នៃការប្រើប្រាស់របស់អតិថិជន និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់ធនាគារនៅពេលបរិយាកាសអាជីវកម្មប្រសើរឡើង។

- **ការប្តេជ្ញាចិត្តចំពោះអតិថិជន**
  យើងបានឈរជាមួយអតិថិជនរបស់យើងជានិច្ច មិនថាជាបុគ្គល គ្រួសារ ឬសហគ្រាសអាជីវកម្ម ក្នុងអំឡុងពេលដែលសេដ្ឋកិច្ចប្រឈមនឹងភាពមិនប្រាកដប្រជា។ វិធានការគាំទ្រប្រកបដោយភាពបត់បែន និងការចូលរួមយ៉ាងសកម្មជាមួយអតិថិជន បានឆ្លុះបញ្ចាំងពីជំនឿរបស់យើងថា ទំនាក់ទំនងធនាគារមិនត្រូវបានកសាងឡើងត្រឹមតែក្នុងគ្រាដែលមានភាពរីកចម្រើនប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានពង្រឹងក្នុងគ្រាដែលមានការលំបាកផងដែរ។

ឆ្ពោះទៅមុខដោយទំនុកចិត្ត

ការចោះជំហានចូលឆ្នាំ២០២៦ ខ្ញុំមើលឃើញហេតុផលជាច្រើនដែលអាចធ្វើឱ្យយើងមានសុទិដ្ឋិនិយម។ មូលដ្ឋានគ្រឹះសេដ្ឋកិច្ចរបស់កម្ពុជា នៅតែមានភាពរឹងមាំ ហើយគោលដៅកំណើនរបស់អាជីវកម្ម អ្នកប្រើប្រាស់ និងវិនិយោគិន នៅតែមានភាពសកម្ម និងមិនបានថមថយឡើយ។ ធនាគារ កម្ពុជា អាស៊ី កំពុងឈានចូលឆ្នាំថ្មីជាមួយនឹងមូលដ្ឋានគ្រឹះកាន់តែរឹងមាំ យុទ្ធសាស្ត្រកាន់តែច្បាស់លាស់ និងក្រុមការងារដែលបានបង្ហាញពីការតស៊ូ និងសមត្ថភាពក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមយ៉ាងមានប្រសិទ្ធភាព។ យើងស្ថិតនៅក្នុងទីតាំងដ៏ល្អសម្រាប់ការត្រឡប់ទៅរកគន្លងកំណើន និងការផ្តល់លទ្ធផលដែលភាគីពាក់ព័ន្ធរបស់យើងរំពឹងទុក និងសាកសមនឹងទទួលបាន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្របំផុតចំពោះអតិថិជនរបស់យើងខ្ញុំសម្រាប់ការជឿទុកចិត្តជាបន្តបន្ទាប់ ម្ចាស់ភាគហ៊ុនសម្រាប់ការគាំទ្រដោយការយោគយល់ និងអត់ធ្មត់ ដៃគូអាជីវកម្មសម្រាប់កិច្ចសហប្រតិបត្តិការដ៏រឹងមាំ និងជាពិសេសបុគ្គលិកទាំងអស់របស់ធនាគារសម្រាប់ការលះបង់ និងការប្រឹងប្រែងបំពេញការងារដោយការប្តេជ្ញាចិត្តពេញមួយឆ្នាំ។ ការរួមចំណែករបស់លោកអ្នកគឺជាកម្លាំងស្នូលដែលធ្វើឱ្យស្ថាប័នរបស់យើងខ្ញុំនៅតែមានភាពរឹងមាំ និងរីកចម្រើន។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់



Wong Tow Fock
នាយកប្រតិបត្តិធនាគារ កម្ពុជា អាស៊ី

ប្រតិបត្តិការ និងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម

១. ទិដ្ឋភាពទូទៅនៃបរិយាកាសប្រតិបត្តិការ

ជីវប្រវត្តិធនាគារ

ធនាគារ កម្ពុជា អាស៊ី គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជាដែលប្តេជ្ញាជំរុញកំណើនសេដ្ឋកិច្ច និងផ្តល់អំណាចដល់សហគមន៍តាមរយៈដំណោះស្រាយធនាគារប្រកបដោយភាពច្នៃប្រឌិត។ ជាមួយនឹង មូលដ្ឋានគ្រឹះដ៏រឹងមាំដែលឈរលើគោលការណ៍សុចរិតភាព និងការយកចិត្តទុកដាក់ចំពោះអតិថិជន ធនាគារ កម្ពុជា អាស៊ី បន្តពង្រីកវិសាលភាពរបស់ខ្លួន និងលើកកម្ពស់សេវាកម្មរបស់ខ្លួនដើម្បីបំពេញតម្រូវការដែល កំពុងរីកចម្រើននៃទីផ្សារកម្ពុជា។

ធនាគារ កម្ពុជា អាស៊ី ផ្តល់ជូននូវបណ្តុំផលិតផល និងសេវាកម្មបុគ្គលដ៏ទូលំទូលាយរួមទាំងគណនីសន្សំ គណនីចរន្ត ប្រាក់បញ្ញើមានកាលកំណត់ ប្រាក់កម្ចីផ្ទាល់ខ្លួន និងប័ណ្ណឥណទាន។ យើងប្តេជ្ញាផ្តល់ដំណោះ ស្រាយហិរញ្ញវត្ថុផ្ទាល់ខ្លួន ដើម្បីជួយបុគ្គលម្នាក់ៗឱ្យសម្រេចបាននូវគោលដៅហិរញ្ញវត្ថុរបស់ពួកគេ។

ធនាគារ កម្ពុជា អាស៊ី គឺជាដៃគូដែលខិតខំប្រឹងប្រែងសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) ដោយផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុសមស្រប ដើម្បីគាំទ្រដល់កំណើន និងការពង្រីកធុរកិច្ចរបស់ពួកគេ។ សេវាកម្មធនាគារ របស់យើងរួមមានកម្ចីធុរកិច្ច ប្រាក់កម្ចីទិញផ្ទះ កម្ចីទាន់ចិត្ត និងហិរញ្ញវត្ថុ ពាណិជ្ជកម្ម។ យើងស្វែងយល់អំពីបញ្ហាដែលសហគ្រាសធន់តូច និងមធ្យមកំពុងប្រឈមហើយយើងប្តេជ្ញា ផ្តល់ធនធានហិរញ្ញវត្ថុ និងជំនាញដែលពួកគេត្រូវការ ដើម្បីទទួលបានជោគជ័យ។

ធនាគារ កម្ពុជា អាស៊ី ប្តេជ្ញាផ្តល់សេវាធនាគារងាយស្រួល និងអាចប្រើប្រាស់ការបានតាមរយៈ ប្រព័ន្ធឌីជីថល ប្រកបដោយភាពច្នៃប្រឌិត។ ដំណោះស្រាយធនាគារ ទូរស័ព្ទចល័តរបស់យើងអនុញ្ញាតឱ្យអតិថិជនគ្រប់គ្រងគណនីរបស់ពួកគេ ធ្វើការទូទាត់ និងផ្ទេរប្រាក់ដោយសុវត្ថិភាព និងងាយស្រួល ទៅកាន់ និងពីគ្រប់ទីកន្លែងក្នុងពិភពលោក។

២. ប្រតិបត្តិការធុរកិច្ច

ធនាគារ កម្ពុជា អាស៊ី គឺជាធនាគារពាណិជ្ជឈានមុខគេនៅកម្ពុជា ដែលមានបណ្តាញសាខា បញ្ជរប្រតិបត្តិការ និង ម៉ាស៊ីនអេធីអឹមដែលគ្រប់ដណ្តប់ពេញផ្ទៃប្រទេស។ ទីតាំងយុទ្ធសាស្ត្ររបស់ធនាគារនៅក្នុងប្រទេសកម្ពុជាផ្តល់ឱ្យនូវអត្ថប្រយោជន៍ប្រកួតប្រជែងល្អឥតខ្ចោះ ដែលអាចធ្វើឱ្យធនាគារផ្តល់ជូននូវផលិតផល និងសេវាកម្មជូនអតិថិជនគ្រប់ស្រទាប់ រាប់ចាប់ពីសហគ្រាសធុនតូច និងមធ្យម (SMEs) រហូតដល់ធំ ក៏ដូចជាអតិថិជនទូទៅផងដែរ។

ការសម្រេចចិត្តរបស់ ធនាគារ កម្ពុជា អាស៊ី ក្នុងការបង្កើតប្រតិបត្តិការធុរកិច្ចរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាឆ្លុះបញ្ចាំងពីការទទួលស្គាល់នូវគុណសម្បត្តិ និងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការបម្រើតម្រូវការសេវាធនាគារផ្នែកធុរកិច្ច និងជូនប្រជាជនកម្ពុជា។ សាខារបស់ធនាគារមានទីតាំងនៅទីក្រុងធំៗ និងទីប្រជុំជនខេត្ត ដោយធានាថាអតិថិជនអាចទទួលបានសេវាធនាគារនៅគ្រប់ទីកន្លែងដែលពួកគេរស់នៅ។

ប្រតិបត្តិការធុរកិច្ចរបស់ធនាគារ កម្ពុជា អាស៊ីនៅកម្ពុជាអនុញ្ញាតឱ្យធនាគារបម្រើអតិថិជនចម្រុះ និងទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ចដែលកំពុងរីកចម្រើនរបស់កម្ពុជា។ បណ្តាញសាខា បញ្ជរប្រតិបត្តិការ និង ម៉ាស៊ីន ATM ដ៏ធំទូលាយរបស់ធនាគារនៅទូទាំងប្រទេសភាពជាដៃគូជាមួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ផ្សេងទៀតនៅក្នុងតំបន់ និងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការជួយដល់កំណើននៃសហគ្រាសធុនតូច និងមធ្យម និងសាជីវកម្មធំដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ធ្វើឱ្យវាក្លាយជាតួអង្គសំខាន់ក្នុងវិស័យធនាគារនៅក្នុងប្រទេស។ នៅពេលដែលកម្ពុជាបន្តអភិវឌ្ឍ និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ ធនាគារ កម្ពុជា អាស៊ីមានទីតាំងល្អក្នុងការជួយដល់កំណើននេះ និងរួមចំណែកដល់ភាពជោគជ័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

យុទ្ធសាស្ត្រអាជីវកម្ម

យុទ្ធសាស្ត្ររបស់ធនាគារ កម្ពុជា អាស៊ី

ក្លាយជាធនាគារបញ្ញានិម្មិតដើម្បីបម្រើគ្រប់តម្រូវការសេវាធនាគារប្រចាំថ្ងៃជូនអតិថិជន

ចីរភាព

ចីរភាព និងនវានុវត្តន៍ ការអភិវឌ្ឍន៍

ភាពជាដៃគូយុទ្ធសាស្ត្រ

កំណើន យុទ្ធសាស្ត្រ

- សាលារៀន
- បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech)
- ទំនិញ FMCG
- ធនាគារក្រៅប្រទេស – ធនាគារ BPI
- ធានារ៉ាប់រង
- សាជីវកម្មធានាឥណទានកម្ពុជា

កំណើនអាជីវកម្ម

- ចំណែកទីផ្សារ
- រីកចម្រើនជាមួយអតិថិជនដែលមានស្រាប់ និងអតិថិជនថ្មី
- បើកសក្តានុពលនៃបណ្តាញសំខាន់ៗចំនួន៣

អំណោយផល

- ការរិភាគទិន្នន័យ
- សេវាធនាគារលើទូរសព្ទដៃ
- ហានិភ័យ និងអនុលោមភាព

លើកកម្ពស់ផលិតភាពផ្អែកលើគុណតម្លៃ

ដំណើរការនៃការផ្លាស់ប្តូរ

សមត្ថភាព

- សមត្ថភាពបច្ចេកវិទ្យាទំនើបលំដាប់ពិភពលោក
- ការគ្រប់គ្រងហានិភ័យ និងអនុលោមភាពលក្ខណៈបុរេសកម្ម
- សន្តិសុខសាយប័រ
- មានទេពកោសល្យ និងដំណើរការរហ័ស
- ភាពជាដៃគូរ និងបណ្តាញឌីជីថល
- ការចំណាយ និងការទូទាត់សង

១. ប្រាក់បញ្ញើ

នៅឆ្នាំ ២០២៥ ធនាគារ កម្ពុជា អាស៊ី បានរក្សាប៉ូស៊ីសិនសន្ទនីយភាពដ៏រឹងមាំពេញមួយឆ្នាំ។ យើងក៏បានអនុលោមតាមយ៉ាងពេញលេញនូវអតិរេកប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃ កម្ពុជាទាំងប្រាក់រៀល និងរូបិយប័ណ្ណបរទេស។ ធនាគារបានបន្តពង្រឹងមូលដ្ឋានផ្តល់ទុនរបស់ខ្លួនតាមរយៈការធ្វើពិពិធកម្មនិងការលាយបញ្ចូលគ្នាដ៏ចម្រុះនៃប្រាក់បញ្ញើរបស់អតិថិជន និងកម្ចីតាមស្ថាប័នជាយុទ្ធសាស្ត្រ។ យុទ្ធសាស្ត្រផ្តល់ទុនរបស់យើងនៅតែផ្តោតលើការរក្សាភាពធន់ និងភាពបត់បែនក្នុងបរិយាកាសហិរញ្ញវត្ថុប្រកបដោយថាមវន្តខណៈពេលដែលធានាបាននូវការអនុលោមតាមស្តង់ដារប្រុងប្រយ័ត្នដែលកំណត់ដោយធនាគារជាតិនៃ កម្ពុជា (NBC)។

២. ឥណទាន

ធនាគារ កម្ពុជា អាស៊ី បានដាក់ឱ្យប្រើប្រាស់កម្មវិធីហិរញ្ញប្បទានដើម្បីគាំទ្រដល់បុគ្គល និងអាជីវកម្មដែលត្រូវការចរិកាបន្ទាន់សម្រាប់បន្តប្រតិបត្តិការ និងរក្សាការងាររបស់បុគ្គលិក។ កម្មវិធីនេះបានអនុញ្ញាតឱ្យអតិថិជនអាចសម្របខ្លួនទៅនឹងស្ថានភាពទីផ្សារដែលកំពុងផ្លាស់ប្តូរ អនុវត្តវិធីសាស្ត្រអាជីវកម្ម និងបច្ចេកវិទ្យាថ្មីៗ ព្រមទាំងធានាបាននូវនិរន្តរភាពនៃប្រតិបត្តិការអាជីវកម្មក្នុងអំឡុងពេលដែលមានបញ្ហាប្រឈម។

៣. ការផ្តោតលើអតិថិជន

អតិថិជន និងសេវាកម្ម

ធនាគារ កម្ពុជា អាស៊ី បន្តពង្រឹងគំរូអាជីវកម្មរបស់ខ្លួន ពោលគឺយុទ្ធសាស្ត្រផ្តោតលើអតិថិជន ដែលធនាគារផ្តោតលើការផ្តល់ជូននូវសេវាកម្មកែតម្រូវតាមបុគ្គលដើម្បីបំពេញតាមតម្រូវការសេវាហិរញ្ញវត្ថុតាមរយៈធនាគារ សម្រាប់អាជីវកម្មធុនតូច មធ្យម ធំ និងប្រជាពលរដ្ឋទូទៅដែលយើងដឹងយ៉ាងច្បាស់តាមរយៈក្រុមស្រាវជ្រាវទីផ្សាររបស់យើង។ នាឆ្នាំ២០២៥ យើងបានផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់ជំនួយដោយផ្ទាល់ ឬដោយប្រយោល ជូនដល់ក្រុមទាំងអស់នៃអតិថិជនរបស់យើងដើម្បីអោយពួកគាត់អាចរក្សាជីវភាព និងអាជីវកម្ម របស់ពួកគាត់នៅក្នុងអំឡុងពេលនៃភាពមិនប្រាកដប្រជាណាមួយ។ លើសពីនេះយើងបានផ្តល់នូវសេវាកម្មប្រកប ដោយការយកចិត្តទុកដាក់ និងបរិយាប័ន្តដែលបានឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនជាដៃគូហិរញ្ញវត្ថុជាទីទុកចិត្ត និងជាធនាគារប្រតិបត្តិការចម្បងរបស់អតិថិជនផងដែរ។

ផលិតផល និងសេវាកម្មរបស់យើង

នៅឆ្នាំ ២០២៥ ធនាគារ កម្ពុជា អាស៊ី បានបន្តពង្រឹង និងពង្រីកភាពចម្រុះនៃផលិតផល និងសេវាកម្មរបស់ខ្លួន ដោយបញ្ចាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការបម្រើអតិថិជនដែលជាបុគ្គល គ្រួសារនិងអាជីវកម្មនានានៅទូទាំងប្រទេសកម្ពុជា។ ផលិតផល និងសេវាកម្មរបស់យើងរួមមាន សេវាធនាគារឌីជីថល ផលិតផលប្រាក់បញ្ញើ ដំណោះស្រាយហិរញ្ញប្បទាន សេវាកម្មទូទាត់ប្រាក់ និងដំណោះស្រាយធនាគារសម្រាប់អាជីវកម្ម ដែលសុទ្ធសឹងតែត្រូវបានរចនាឡើងដើម្បីផ្តល់ជូនអតិថិជននូវភាពងាយស្រួលក្នុងការទទួលបានសេវា និងតម្លៃកាន់តែប្រសើរ។

កម្មវិធីទូរស័ព្ទដៃរបស់ធនាគារ កម្ពុជា អាស៊ី

វេទិកាធនាគារឌីជីថលរបស់យើងដែលផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុយ៉ាងសម្បូរបែប និងទូលំទូលាយ នៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ តាមរយៈកម្មវិធីនេះ អតិថិជនអាច៖

- ផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន រឺទៅកាន់គណនីធនាគារ កម្ពុជា អាស៊ីផ្សេងទៀត
- ធ្វើប្រតិបត្តិការផ្ទេរប្រាក់ក្នុងស្រុក និងអន្តរជាតិ
- បើកគណនីសន្សំ និងគណនីប្រាក់បញ្ញើមានកាលកំណត់
- បញ្ចូលទឹកប្រាក់ទូរស័ព្ទ និងទូទាត់វិក្កយបត្រអគ្គិសនី
- ធ្វើប្រតិបត្តិការទូទាត់តាមរយៈ QR Code និងប្រព័ន្ធទូទាត់បាគង

កម្មវិធីទូរស័ព្ទដៃរបស់ធនាគារ កម្ពុជា អាស៊ី ត្រូវបានរចនាឡើងដោយផ្តោតលើភាពងាយស្រួល និងសុវត្ថិភាពខ្ពស់ ហើយនៅតែបន្តដើរតួនាទីជាបណ្តាញទំនាក់ទំនងចម្បង ដែលអតិថិជនអាចគ្រប់គ្រងតម្រូវការហិរញ្ញវត្ថុប្រចាំថ្ងៃរបស់ពួកគាត់បាន។



គណនីសន្សំ Super Saver

ផលិតផលសន្សំប្រាក់ប្រកបដោយវិន័យដែលត្រូវបានរចនាឡើងដោយផ្អែកលើគោលការណ៍ដ៏សាមញ្ញ ប៉ុន្តែមានប្រសិទ្ធភាពខ្ពស់។ ការប្តេជ្ញាចិត្តសន្សំជាប្រចាំគឺមានសារៈសំខាន់ជាងទំហំនៃទឹកប្រាក់បញ្ញើនីមួយៗ។ អតិថិជននឹងទទួលបានអត្រាការប្រាក់ខ្ពស់បំផុតដែលធនាគារផ្តល់ជូន ដោយរក្សាទម្លាប់សន្សំប្រចាំខែជាទៀងទាត់តាមរយៈការផ្ទេរប្រាក់ដោយស្វ័យប្រវត្តិជារៀងរាល់ខែពីគណនីប្រភព។ គណនី Super Saverផ្តល់ការលើកទឹកចិត្តលើទម្លាប់នៃការសន្សំជាប្រចាំ មិនមែនផ្តោតត្រឹមតែទៅលើសមតុល្យទឹកប្រាក់នោះទេដែលធ្វើឱ្យវាក្លាយជាដំណោះស្រាយដ៏ល្អបំផុតសម្រាប់អតិថិជនដែលមានបំណងចង់កសាងទ្រព្យសម្បត្តិរបស់ខ្លួនឱ្យកើនឡើងជាបន្តបន្ទាប់ទៅតាមពេលវេលា។

គណនីប្រាក់បញ្ញើមានកាលកំណត់សម្រាប់ជរាជន

គម្រោងប្រាក់បញ្ញើពិសេសមួយ ដែលត្រូវបានរចនាឡើងសម្រាប់តែអតិថិជនដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ។ ផលិតផលនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ធនាគារ កម្ពុជា អាស៊ី ក្នុងការផ្តល់សេវាធនាគារប្រកបដោយបរិយាបន្នហិរញ្ញវត្ថុ និងលើកកម្ពស់សន្តិសុខហិរញ្ញវត្ថុសម្រាប់អតិថិជនគ្រប់ជំនាន់។ គណនីនេះផ្តល់ជូននូវជម្រើសរយៈពេលដាក់ប្រាក់បញ្ញើដែលមានភាពបត់បែន និងអត្រាការប្រាក់ខ្ពស់ជាងគណនីប្រាក់បញ្ញើមានកាលកំណត់ធម្មតាដែលអនុញ្ញាតឱ្យអតិថិជនអាចរីករាយជាមួយការសន្សំប្រាក់ប្រកបដោយសុវត្ថិភាព និងទទួលបានផលចំណេញកាន់តែប្រសើរ។ ផលិតផលនេះបញ្ចាក់ពីការប្តេជ្ញាចិត្តរបស់ធនាគារ កម្ពុជា អាស៊ី ក្នុងការផ្តល់សេវាធនាគារប្រកបដោយបរិយាបន្នហិរញ្ញវត្ថុ និងការគាំទ្រដល់សុខុមាលភាពហិរញ្ញវត្ថុរបស់មនុស្សគ្រប់ជំនាន់។

គណនីសន្សំបង់ថ្លៃសិក្សា

ផលិតផលសន្សំប្រាក់ដែលត្រូវបានរៀបចំឡើងជាពិសេស ដើម្បីជួយមាតាបិតា និងអាណាព្យាបាលក្នុងការគ្រប់គ្រងការចំណាយលើការអប់រំរបស់បុត្រធីតា។ គណនីនេះដំណើរការជាទម្រង់ប្រាក់បញ្ញើសន្សំដែលមានភាពបត់បែន ដោយអនុញ្ញាតឱ្យមាតាបិតាឬអាណាព្យាបាលអាចដាក់ប្រាក់ចូលទៅក្នុងគណនីនេះ ដើម្បីទូទាត់ថ្លៃសិក្សារបស់បុត្រធីតានៅតាមបណ្តាសាលារៀនជាដៃគូរបស់ធនាគារ កម្ពុជា អាស៊ី។

គណនីសន្សំ Child Future៖ ស្រលាញ់តែងតែផ្សារភ្ជាប់ជាមួយនឹងទំនួលខុសត្រូវ។ ធនាគារ កម្ពុជា អាស៊ី យល់ពីក្តីបារម្ភរបស់មាតាបិតាចំពោះអនាគតរបស់បុត្រធីតា។ គណនីសន្សំ Child Future ជាគណនីសន្សំប្រាក់បង្គរដែលត្រូវបានរចនាឡើងយ៉ាងយកចិត្តទុកដាក់ ដើម្បីជួយមាតាបិតាក្នុងការសន្សំកញ្ចប់ថវិកាមួយសម្រាប់គាំទ្រដល់ការសិក្សា ឬជាការបំរុងទុកសម្រាប់ការចំណាយសំខាន់ៗផ្សេងទៀតដែលមើលមិនឃើញជាមុនរបស់បុត្រធីតានៅថ្ងៃអនាគត។ ការផ្តល់ជូនពិសេសនេះនឹងផ្តល់ជូនអតិថិជននូវអត្រាការប្រាក់ខ្ពស់ ព្រមទាំងអត្ថប្រយោជន៍ជាច្រើនសម្រាប់ទាំងមាតាបិតា និងបុត្រធីតា។

គណនីសន្សំបង្គរ IWISH៖ គឺជាផលិតផលប្រាក់បញ្ញើសន្សំជាប្រចាំ ដែលត្រូវបានរៀបចំឡើងដើម្បីជួយអតិថិជនសម្រេចបាននូវគោលដៅហិរញ្ញវត្ថុ និងបំពេញបំណងប្រាថ្នារបស់ខ្លួន ព្រមទាំងរក្សាប្រាក់សន្សំរបស់ពួកគាត់ឱ្យមានសុវត្ថិភាពខ្ពស់។ ជាមួយនឹងជម្រើសនៃការដាក់ប្រាក់ដែលមានភាពបត់បែន និងអត្រាការប្រាក់ប្រកួតប្រជែង ផលិតផលនេះធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួនកាន់តែងាយស្រួលជាងមុនសម្រាប់អតិថិជន និងបោះជំហានឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង។

កាតធនាគារ កម្ពុជា អាស៊ី៖ ជាមួយនឹងប័ណ្ណតណពន្ធវីសា និងប័ណ្ណតណទាន UnionPay របស់ធនាគារ កម្ពុជា អាស៊ី អតិថិជននឹងរីករាយជាមួយនឹងការដកប្រាក់នៅតាមគ្រប់ម៉ាស៊ីនអេធីអឹម ព្រមទាំងទូទាត់ប្រាក់តាមរយៈម៉ាស៊ីនឆូតកាតនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅជុំវិញពិភពលោក នៅរាល់ទីកន្លែងដែលមានបង្ហាញស្លាកសញ្ញា VISA និង UnionPay ។

គណនីសន្សំ៖ គឺជាផលិតផលប្រាក់បញ្ញើប្រកបដោយសុវត្ថិភាព ដែលត្រូវបានរចនាឡើងដើម្បីជួយបុគ្គលម្នាក់ៗ ក៏ដូចជាអាជីវកម្មក្នុងការបង្កើនទុនខណៈពេលដែលរក្សាបាននូវភាពងាយស្រួលក្នុងការដកសាច់ប្រាក់ប្រើប្រាស់។ ផលិតផលនេះក៏ផ្តល់ជូននូវអត្រាការប្រាក់ប្រកួតប្រជែង ជម្រើសនៃការដាក់ប្រាក់ប្រកបដោយភាពបត់បែន និងភាពងាយស្រួលតាមរយៈប្រព័ន្ធធនាគារឌីជីថលផងដែរ។

គណនីសន្សំសកម្ម៖ គឺជាប្រាក់បញ្ញើសន្សំប្រកបដោយភាពបត់បែន ដែលត្រូវបានរចនាឡើងដើម្បីផ្តល់រង្វាន់លើកទឹកចិត្តដល់អតិថិជនដោយផ្អែកលើសមតុល្យសាច់ប្រាក់ប្រចាំថ្ងៃនៅក្នុងគណនី។ ការប្រាក់ត្រូវបានគណនាជារៀងរាល់ថ្ងៃ និងទូទាត់ជូនទៅតាមកម្រិតថ្នាក់នៃសមតុល្យសាច់ប្រាក់ ដែលធានាបាននូវការផ្តល់ត្រឡប់មកវិញប្រកបដោយភាពសមរម្យ តម្លាភាព និងផ្អែកលើទំហំនៃការសន្សំជាក់ស្តែង។

គណនីចរន្ត៖ គឺជាផលិតផលប្រាក់បញ្ញើតាមតម្រូវការ ដែលផ្តល់ជូនដោយធនាគារ កម្ពុជា អាស៊ី ដែលត្រូវបានរចនាឡើងដើម្បីផ្តល់ឱ្យអតិថិជននូវលទ្ធភាពប្រើប្រាស់ថវិកាដោយមិនមានការរឹតបន្តឹង សម្រាប់ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃ។ គណនីនេះផ្តល់នូវការគាំទ្រទាំងអតិថិជនបុគ្គល និងអតិថិជនសាជីវកម្ម (ក្រុមហ៊ុន) ដែលត្រូវការសាច់ប្រាក់ងាយស្រួលខ្ពស់ និងមានតម្រូវការធ្វើប្រតិបត្តិការញឹកញាប់។

គណនីប្រាក់បញ្ញើមានកាលកំណត់៖ គឺជាផលិតផលប្រាក់បញ្ញើមានកាលកំណត់ប្រកបដោយសុវត្ថិភាពដែលផ្តល់ជូនដោយធនាគារ កម្ពុជា អាស៊ី ដោយទឹកប្រាក់បញ្ញើត្រូវបានរក្សាទុកក្នុងរយៈពេលជាក់លាក់ណាមួយ ជាមួយនឹងអត្រាការប្រាក់ដែលបានកំណត់ទុកជាមុន។ ផលិតផលនេះផ្តល់ជូនអតិថិជនទាំងបុគ្គល និងអង្គភាពសាជីវកម្ម នូវជម្រើសវិនិយោគដ៏គួរឱ្យទុកចិត្តមួយ ដែលធានាបាននូវការផ្តល់ត្រឡប់មកវិញនូវផលចំណេញយ៉ាងពិតប្រាកដ ជួយគាំទ្រដល់ការរៀបចំផែនការហិរញ្ញវត្ថុ និងផ្តល់នូវភាពបត់បែនក្នុងការជ្រើសរើសរយៈពេលកំណត់។

ផលិតផលឥណទាន

ផលប័ត្រឥណទានរបស់ធនាគារ កម្ពុជា អាស៊ី ត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវហិរញ្ញប្បទាន ទាន់ពេលវេលា ងាយស្រួលទទួលបាន និងសមស្រប ជូនដល់ទាំងបុគ្គល និងអាជីវកម្ម។ ផលិតផលឥណទានទីមួយៗត្រូវបានរចនាឡើងស្របតាមស្ថានភាពហិរញ្ញវត្ថុ និងគោលបំណងជាក់លាក់របស់ក្រុមអតិថិជនគោលដៅ ដោយផ្តល់ជូននូវអត្រាការប្រាក់ប្រកួតប្រជែង លក្ខខណ្ឌសងត្រឡប់ប្រកបដោយភាពបត់បែន ព្រមទាំងការគាំទ្រនិងការប្រឹក្សាយោបល់យ៉ាងយកចិត្តទុកដាក់ពីមន្ត្រីទំនាក់ទំនងអតិថិជនក្នុងអំឡុងពេលវដ្តនៃឥណទាន។

១. ឥណទានអាជីវកម្ម និងឥណទានផ្ទាល់ខ្លួន៖ ធនាគារ កម្ពុជា អាស៊ី ផ្តល់ជូននូវដំណោះស្រាយហិរញ្ញប្បទានប្រកបដោយភាពបត់បែន ដើម្បីគាំទ្រដល់ការរីកចម្រើននៃអាជីវកម្ម ក៏ដូចជាតម្រូវការហិរញ្ញវត្ថុផ្ទាល់ខ្លួន។ អាជីវកម្មនានាអាចទទួលបានប្រភពទុនសម្រាប់ប្រើប្រាស់ជាទុនបង្វិល ការទិញឧបករណ៍បរិក្ខារ ការពង្រីកអាជីវកម្ម និងឱកាសរីកចម្រើនផ្សេងៗទៀត ខណៈពេលដែលបុគ្គលម្នាក់ៗអាចទទួលបានហិរញ្ញប្បទានសម្រាប់ការជួសជុលកែលម្អលំនៅឋាន ការសិក្សាអប់រំ ការចំណាយលើការព្យាបាលជំងឺ ការទិញទ្រព្យសម្បត្តិសំខាន់ៗ និងតម្រូវការផ្ទាល់ខ្លួនផ្សេងៗទៀត។ ជាមួយនឹងអត្រាការប្រាក់ប្រកួតប្រជែង លក្ខខណ្ឌសងត្រឡប់ដ៏ងាយស្រួល និងដំណើរការដាក់ពាក្យស្នើសុំឥណទានដ៏រហ័សទាន់ចិត្ត ធនាគារ កម្ពុជា អាស៊ី ផ្តល់ជូននូវដំណោះស្រាយឥណទានដែលត្រូវបានរចនាឡើងយ៉ាងសមស្រប ក្នុងគោលបំណងជួយជម្រុញអតិថិជនឱ្យសម្រេចបាននូវគោលដៅហិរញ្ញវត្ថុរបស់ខ្លួន។

២. តណទានរហ័ស

ផលិតផលនេះអនុញ្ញាតឱ្យអតិថិជនទទួលបានហិរញ្ញប្បទាន ដោយប្រើប្រាស់ប្រាក់បញ្ញើមានកាលកំណត់របស់ខ្លួនជាទ្រព្យធានា ដោយមិនចាំបាច់ដកប្រាក់បញ្ញើនោះចេញមុនកាលកំណត់ ឬបាត់បង់ការប្រាក់ដែលបានបង្ករនោះឡើយ។ ប្រាក់បញ្ញើដែលបានដាក់ធានានោះនៅតែបន្តទទួលបានការប្រាក់ពេញមួយអំឡុងពេលតណទាន ខណៈពេលដែលអតិថិជនទទួលបានអត្ថប្រយោជន៍ពីអត្រាការប្រាក់តណទានជាទីគាប់ចិត្ត។ ផលិតផលនេះគឺជាដំណោះស្រាយដ៏ប្រសើរបំផុតសម្រាប់បំពេញតម្រូវការសាច់ប្រាក់ងាយស្រួលក្នុងរយៈពេលខ្លី ព្រមទាំងអាចរក្សាទុកនូវប្រាក់សន្សំរយៈពេលវែងបានផងដែរ។

៣. តណទានទាន់ចិត្ត

តណទានទាន់ចិត្ត គឺជាដំណោះស្រាយហិរញ្ញប្បទានសម្រាប់អាជីវកម្ម និងផ្ទាល់ខ្លួន ដែលត្រូវបានរចនាឡើងជាពិសេសសម្រាប់ម្ចាស់អាជីវកម្ម និងបុគ្គលិកដែលមានប្រាក់បៀវត្សរ៍។ ផលិតផលនេះផ្តល់ជូននូវអត្រាការប្រាក់សមរម្យ រយៈពេលសងត្រឡប់រហូតដល់ ២៤ ខែ ព្រមទាំងដំណើរការដាក់ពាក្យស្នើសុំដ៏សាមញ្ញ។ ផលិតផលនេះផ្តល់នូវជម្រើសហិរញ្ញប្បទានដ៏ងាយស្រួលនិងមានតម្លៃសមរម្យ ដែលជួយគាំទ្រដល់តម្រូវការទុនបង្វិលរបស់អាជីវកម្ម និងលើកកម្ពស់សុខុមាលភាពហិរញ្ញវត្ថុរបស់អតិថិជន។

៤. តណទានវិបារូបន៍

សេវាកម្មតណទានវិបារូបន៍របស់ធនាគារ កម្ពុជា អាស៊ី ផ្តល់ជូនអាជីវកម្ម និងបុគ្គលនូវលទ្ធភាពទទួលបានហិរញ្ញប្បទានរយៈពេលខ្លីប្រកបដោយភាពបត់បែន តាមរយៈគណនីចរន្តរបស់ខ្លួន។ អតិថិជនអាចដកប្រើប្រាស់ប្រាក់បានតាមតម្រូវការជាក់ស្តែងក្នុងដែនកំណត់ដែលបានអនុម័ត ហើយការបង់ការប្រាក់គឺគិតតែលើចំនួនទឹកប្រាក់ដែលបានប្រើប្រាស់ប៉ុណ្ណោះ។ ផលិតផលនេះគឺសមស្របសម្រាប់ការគ្រប់គ្រងលំហូរសាច់ប្រាក់ ការបំពេញតម្រូវការទុនបង្វិល និងការដោះស្រាយការខ្វះខាតប្រាក់ជាបណ្តោះអាសន្ន ប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួល។

៥. តណទានគេហដ្ឋាន

តណទានគេហដ្ឋានរបស់ធនាគារ កម្ពុជា អាស៊ី គឺជាដំណោះស្រាយហិរញ្ញប្បទានរយៈពេលវែងដែលត្រូវបានរចនាឡើងដើម្បីជួយបុគ្គលម្នាក់ៗ និងក្រុមគ្រួសារសម្រេចបាននូវក្តីស្រមៃក្នុងការក្លាយជាម្ចាស់កម្មសិទ្ធិលើលំនៅឋានផ្ទាល់ខ្លួន។ ផលិតផលនេះផ្តល់ជូននូវជម្រើសសងត្រឡប់ប្រកបដោយភាពបត់បែន អត្រាការប្រាក់ប្រកួតប្រជែង ព្រមទាំងដំណើរការដាក់ពាក្យស្នើសុំដ៏សាមញ្ញដែលជួយឱ្យអតិថិជនកាន់តែងាយស្រួលក្នុងការក្លាយជាម្ចាស់លំនៅឋានក្នុងក្តីស្រមៃប្រកបដោយទំនុកចិត្ត។

សាជីវកម្ម

ជាមួយនឹងការប្តេជ្ញាចិត្តក្លាយជាធនាគារជម្រើសដំបូងសម្រាប់អតិថិជនសាជីវកម្ម ធនាគារ កម្ពុជា អាស៊ី ប្តេជ្ញាផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុដែលលើសពីសេវាធនាគារបែបប្រពៃណី ដើម្បីជួយឱ្យអាជីវកម្មទានាបង្កើនសមត្ថភាពប្រកួតប្រជែង សម្រួលប្រតិបត្តិការ និងសម្រេចបាននូវកំណើនប្រកបដោយចីរភាព។ នៅឆ្នាំ ២០២៥ យើងខ្ញុំបានបន្តពង្រឹងសំណើតម្លៃនៃសេវាធនាគារសម្រាប់សាជីវកម្មតាមរយៈការអភិវឌ្ឍផលិតផលដោយផ្តោតលើតម្រូវការជាក់លាក់និងចៃរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអតិថិជន។ធនាគារ កម្ពុជា អាស៊ី ផ្តល់អាទិភាពដល់ការផ្តល់ជូនផលិតផល និងសេវាកម្មដែលបំពេញតាមតម្រូវការរបស់អតិថិជនបានគ្រប់ជ្រុងជ្រោយ ក្នុងន័យប្រតិបត្តិការអាជីវកម្ម អ្នកផ្គត់ផ្គង់ ម្ចាស់អាជីវកម្ម និងនិយោជិតរបស់ពួកគាត់។ យើងមានគោលបំណងពង្រឹងសមត្ថភាពប្រកួតប្រជែង និងប្រសិទ្ធផលនៃការគ្រប់គ្រងអាជីវកម្មរបស់ពួកគាត់ ស្របពេលដែលរក្សាជំហររបស់យើងក្នុងនាមជាធនាគារចម្បងរបស់ពួកគាត់ផងដែរ។

បណ្តាញសេវាកម្ម

នៅឆ្នាំ ២០២៥ ធនាគារ CAB Bank បានបន្តពង្រឹងបណ្តាញផ្តល់សេវារបស់ខ្លួន ដើម្បីផ្តល់ជូនអតិថិជន និងដៃគូអាជីវកម្មនូវបទពិសោធន៍ធនាគារដែលរលូន ងាយស្រួល និងអាចទុកចិត្តបាន គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ តាមរយៈការពង្រឹងភាពជាដៃគូ ការកែលម្អសេវាកម្មឌីជីថល និងសេវាកម្មតាមសាខារបស់យើង យើងបានបង្កើនប្រសិទ្ធភាពពង្រីកលទ្ធភាពក្នុងការទទួលអតិថិជន និងផ្តល់ជូននូវសេវាកម្មប្រកបដោយគុណភាពខ្ពស់ហើយមានប្រសិទ្ធភាពក្នុងការចំណាយ។

បណ្តាញសេវាអេឡិចត្រូនិក

បណ្តាញសេវាអេឡិចត្រូនិករបស់ធនាគារ កម្ពុជា អាស៊ី ផ្តល់ជូនអតិថិជននូវការចូលប្រើប្រាស់សេវាធនាគារប្រកបដោយភាពជឿជាក់គ្រប់ពេលវេលា តាមរយៈបណ្តាញឌីជីថល និងសេវាកម្មស្វ័យប្រវត្តិដែលកំពុងពង្រីកជាបន្តបន្ទាប់។ នៅឆ្នាំ ២០២៥ យើងបានបន្តវិនិយោគលើការពង្រឹងប្រសិទ្ធភាពប្រព័ន្ធ និងការពង្រីកវិសាលភាពសេវាកម្ម ដើម្បីឆ្លើយតបទៅនឹងការរីវត្តយ៉ាងឆាប់រហ័សនៃវិស័យធនាគារឌីជីថលនៅកម្ពុជា។

(i) ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) របស់ធនាគារ កម្ពុជា អាស៊ី បណ្តាញម៉ាស៊ីន ATM របស់ធនាគារ កម្ពុជា អាស៊ី ត្រូវបានដាក់ពង្រាយយ៉ាងមានយុទ្ធសាស្ត្រនៅតាមទីតាំងដែលមានចរាចរណ៍មមាញឹក ដើម្បីធានាបាននូវការគ្របដណ្តប់ទូលំទូលាយ និងការចូលប្រើប្រាស់សាច់ប្រាក់ប្រកបដោយភាពងាយស្រួលនៅទូទាំងប្រទេស។ ក្នុងឆ្នាំ ២០២៥ យើងបានបន្តផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យម៉ាស៊ីនមានដំណើរការប្រក្រតីជាបន្តបន្ទាប់ និងការបង្កើនប្រសិទ្ធភាពទីតាំងដំឡើងម៉ាស៊ីន ដើម្បីធានាថា អតិថិជនអាចប្រើប្រាស់សេវាកម្មរបស់យើងបានដោយទំនុកចិត្តនៅគ្រប់ចំណុច
ប៉ះពាល់សេវាកម្ម។

(ii) ផ្នែកទំនាក់ទំនងអតិថិជន ផ្នែកទំនាក់ទំនងអតិថិជនរបស់យើងខ្ញុំបើកដំណើរការ ២៤ ម៉ោងក្នុងមួយថ្ងៃ និង ៧ ថ្ងៃក្នុងមួយសប្តាហ៍ ដោយផ្តល់សេវាគាំទ្រអតិថិជនយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព ជាភាសាខ្មែរ អង់គ្លេស និងចិន។ អតិថិជនអាចទាក់ទងមកយើងតាមរយៈទូរស័ព្ទ Facebook Instagram និង Telegram ដើម្បីទទួលបានជំនួយពីក្រុមការងារជំនាញតាមរយៈមធ្យោបាយទំនាក់ទំនងដែលពួកគេចង់ប្រើប្រាស់។

(iii) សេវាធនាគារចល័ត CAB Mobile Banking គឺជាបណ្តាញសេវាឌីជីថលដ៏សំខាន់មួយ ដែលផ្តល់ជូនអតិថិជននូវការចូលប្រើប្រាស់សេវាធនាគារប្រកបដោយសុវត្ថិភាព ភាពងាយស្រួល និងអាចប្រើប្រាស់បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ នៅឆ្នាំ ២០២៥ ធនាគារបាន បន្តពង្រឹងប្រសិទ្ធភាព ភាពជឿជាក់ និងបទពិសោធន៍ប្រើប្រាស់របស់វេទិកានេះ ដើម្បីគាំទ្រដល់ការកើនឡើងនៃការប្រើប្រាស់សេវាធនាគារឌីជីថល និងប្រតិបត្តិការទូទាត់ដោយមិនប្រើក្រដាសប្រាក់។

សាខា និងបណ្តាញសេវាហិរញ្ញវត្ថុ

បណ្តាញសាខា	ចំនួនទីតាំង
បញ្ជរ (១)	៩
សាខា	៨

កំណត់សម្គាល់៖
(១) សេវាកម្មនៅតាមការិយាល័យសាខារួមមាន សេវាប្តូរប្រាក់បរទេស សេវាផ្ទេរប្រាក់តាមប្រព័ន្ធ Western Union និង សេវាដកសាច់ប្រាក់តាមម៉ាស៊ីន POS សម្រាប់ប័ណ្ណ VISA និង MasterCard។

ប្រតិបត្តិការរបស់ ធនាគារ កម្ពុជា អាស៊ី

ការគ្រប់គ្រងធនធានមនុស្ស

នៅធនាគារ កម្ពុជា អាស៊ី បុគ្គលិករបស់យើងគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុត។ នៅឆ្នាំ ២០២៥ យើងបានបន្តពង្រឹងជំនឿនេះតាមរយៈការវិនិយោគលើផែនការបណ្តុះបណ្តាលផ្ទៃក្នុងដែលមានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ដើម្បីបំពាក់បំប៉នបុគ្គលិកគ្រប់លំដាប់ថ្នាក់ឱ្យមានចំណេះដឹង ជំនាញ និងទំនុកចិត្តដែលចាំបាច់ សម្រាប់បម្រើអតិថិជនប្រកបដោយឧត្តមភាព និងសុចរិតភាព។ ការបណ្តុះបណ្តាលត្រូវបានចាត់ទុកជាកាតព្វកិច្ចចាំបាច់ និងជាមូលដ្ឋានគ្រឹះសម្រាប់កសាងស្ថាប័នមួយដែលមានសមត្ថភាព អនុលោមតាមបទប្បញ្ញត្តិ និងផ្តោតលើអតិថិជនជាស្នូល។ ធនាគារ កម្ពុជា អាស៊ី បានអនុវត្តយុទ្ធសាស្ត្រធនធានមនុស្ស និងស្របតាមយុទ្ធសាស្ត្ររបស់ធនាគារ កម្ពុជា អាស៊ី។ គំនិតផ្តួចផ្តើមសំខាន់ៗ គឺមានដូចខាងក្រោម៖

- **ធានាឱ្យបាននូវអ្នកដឹកនាំ និងវប្បធម៌សក្តិសមល្អប្រសើរ៖** យើងបានបង្កើតគុណវុឌ្ឍិសម្រាប់ថការដឹកនាំប្រកបដោយគោលបំណង និងអាចអនុវត្តបានស្របតាមគោលការណ៍ណែនាំអំពីតរិយាបថ ដែលរួមមានដូចជាការស្គាល់ខ្លួនឯង តម្រង់ទិសដើម្បីទទួលបានលទ្ធផល ការធ្វើការជាក្រុម និងសមាហរណកម្ម។ កិច្ចការនេះគឺដើម្បីធានាថា សកម្មភាពដែលនឹងត្រូវអនុវត្តប្រកប ដោយទទួលខុសត្រូវចំពោះការងារខ្លួនឯង ការងារជាក្រុម អតិថិជន និងអង្គភាពនៅទូទាំងដំណើរការនៃការងារ។ ធនាគារ កម្ពុជា អាស៊ី បានរៀបចំសកម្មភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំជាបន្តបន្ទាប់ ដោយចាប់ផ្តើមពីដំណើរការជ្រើសរើសបុគ្គលិក។ ការសម្ភាសន៍ជ្រើសរើស និងលក្ខណៈវិនិច្ឆ័យសម្រាប់ការសាកល្បងការងារថ្មី ត្រូវបានបង្កើតឡើងស្របតាម គោលការណ៍ណែនាំអំពីតរិយាបថរំពឹងទុកពាក់ព័ន្ធនឹងគុណតម្លៃនៃភាពជាអ្នកដឹកនាំ។

- **ជំរុញយុទ្ធសាស្ត្ររីកចម្រើន៖** ធនាគារ កម្ពុជា អាស៊ី បានអនុវត្តការរៀបចំរចនាសម្ព័ន្ធអង្គភាពឡើងវិញ និងបានជ្រើសរើសបុគ្គលិកដើម្បីគាំទ្រការអភិវឌ្ឍន៍អាជីវកម្មរបស់ធនាគារ កម្ពុជា អាស៊ី។ យើងបានផ្តោតលើការបង្កើនជំនាញ បទពិសោធន៍ និងសមត្ថភាពរបស់និយោជិតនៅក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ និងទទួលខុសត្រូវចំពោះមតិយោបល់ជាច្រើន ជាពិសេសនិយោជិតដែលចូលរួមជាមួយការពង្រីកអាជីវកម្មនៅក្នុងតំបន់ ទិន្នន័យ និងការវិភាគ និងការបង្កើតយុទ្ធសាស្ត្រ។ លើសពីនេះ សមត្ថភាពរបស់និយោជិត គឺត្រូវបានពង្រឹង ដើម្បីឱ្យស្របតាមរបៀបរបបធ្វើការងាររហ័សនៅក្នុងអំឡុងពេលនៃការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាដ៏រហ័សនេះ។ ការវាយតម្លៃសមិទ្ធផលការងារក៏ត្រូវបានកែតម្រូវ ដើម្បីសម្របតាមទម្រង់ការងារថ្មីនេះ។ ធនាគារ កម្ពុជា អាស៊ី បានបង្កើតគោលការណ៍ណែនាំ សម្រាប់របៀបធ្វើការងាររហ័ស ដែលមានបួនជំហានសម្រាប់ការចូលរួមរបស់និយោជិត និងក្រមប្រតិបត្តិដើម្បីធានាបាននូវបរិយាកាសការងារមានលក្ខណៈជាប្រព័ន្ធ និងស្មើភាពគ្នា។

ជំហានទាំងនោះមានដូចខាងក្រោម៖

១) ផ្តត់គំនិតរហ័ស/បណ្តុំជំនាញ៖ និយោជិតត្រូវបានលើកទឹកចិត្តឱ្យធ្វើការងារប្រកបដោយភាពបត់បែន ហ៊ានបញ្ចេញភាពច្នៃប្រឌិត និងនវានុវត្តន៍ ព្រមទាំងដើរឱ្យបានមុនការផ្លាស់ប្តូរ។

២) របៀបធ្វើការងាររួម៖ មានការផ្តោតការយកចិត្តទុកដាក់លើការងារក្រុមជាក់ស្តែង ដែលស្របទៅនឹងទម្រង់ការងារថ្មីៗឲ្យទាន់តាមបច្ចុប្បន្នភាព។

៣) របៀបធ្វើការងាររហ័ស៖ និយោជិតរបស់យើងត្រូវបានជំរុញឱ្យអនុវត្តយករបៀបធ្វើការងាររហ័ស ដើម្បីបង្កើនភាពបត់បែន និងល្បឿននៃការងារអន្តរនាយកដ្ឋានឱ្យដល់កម្រិតអតិបរិមា។ យើងក៏បានរៀបចំសកម្មភាពផ្តល់រង្វាន់បុគ្គលិក ដើម្បីទទួលស្គាល់និយោជិតដែលមានសមិទ្ធផលការងារល្អបំផុត និងជំរុញទឹកចិត្តនៅក្នុងចំណោមសហការីផងដែរ។

៤) សហគមន៍នៃការអនុវត្ត៖ យើងបានលើកទឹកចិត្តឱ្យនិយោជិតដែលមិនមានបទពិសោធន៍លើរបៀបធ្វើការងាររហ័ស ឱ្យរៀនសូត្រពីការអនុវត្ត និងពីអ្នកដទៃ ដូច្នេះបង្កើតជាសហគមន៍នៃការអនុវត្ត ជាកន្លែងដែលសហការីប្រមូលផ្តុំគ្នា ដើម្បីចែករំលែកការអនុវត្តល្អអោយគ្នាទៅវិញទៅមក។ ដើម្បីលើកកម្ពស់សមត្ថភាពនិយោជិតដែលចូលរួមជាមួយអាជីវកម្មក្នុងតំបន់ ធនាគារ កម្ពុជា អាស៊ី បានបង្កើតកម្មវិធីសំណើគុណតម្លៃនិយោជិត (កន្លែងល្អបំផុតក្នុងការធ្វើការងារ រៀនសូត្រ និងដឹកនាំ) ដើម្បីគាំទ្រដល់កម្លាំងជំរុញរបស់យើងក្នុងការជ្រៀតចូលទីផ្សារក្នុងតំបន់ ស្របតាមយុទ្ធសាស្ត្ររបស់យើងក្នុងការក្លាយជាអ្នកដឹកនាំក្នុងតំបន់។ លើសពីនេះទៅទៀត យើងក៏បានគូសបញ្ជាក់អំពីការធ្វើអាជីវកម្មទីផ្សារសេរីនៃការលូតលាស់ដែលគ្មានដែនកំណត់ ដើម្បីផ្សព្វផ្សាយដល់មនុស្សជំនាន់ក្រោយអំពីឱកាស កំណើនគ្មានព្រំដែនដោយសារតែយើងមានការជំរុញទឹកចិត្តក្នុងការក្លាយ ជាអង្គភាពដែលបម្រើដល់មូលដ្ឋានគ្រឹះនៃសង្គមកម្ពុជា និងសហគមន៍សេដ្ឋកិច្ចអាស៊ានផងដែរ។

ការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យ គឺជាផ្នែកដ៏សំខាន់មួយនៃវប្បធម៌ក្រុមហ៊ុនរបស់យើង។ យើងបានបង្កើតគោលនយោបាយគ្រប់គ្រងហានិភ័យ និងការកំណត់ហានិភ័យ ហើយការគ្រប់គ្រងហានិភ័យ គឺត្រូវបានយកមកពិចារណានៅពេលបង្កើតយុទ្ធសាស្ត្រ និងសកម្មភាពអាជីវកម្មរបស់យើង ដើម្បីគាំទ្រដល់កំណើនអាជីវកម្ម។ កិច្ចការនេះ គឺដើម្បីធានាបាននូវលទ្ធភាពចំណេញប្រកបដោយចីរភាព និងបង្កើនផលចំណេញរបស់ភាគីពាក់ព័ន្ធឱ្យដល់កម្រិតអតិបរមា។ យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ធនាគារ កម្ពុជា អាស៊ី ត្រូវបានបង្កើតឡើងស្របតាមគោលការណ៍ណែនាំជាតិ និងអន្តរជាតិដើម្បីអនុវត្តឲ្យសមស្របនឹងធនាគារទាំងមូល។ យើងចូលរួមនៅក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសរុបដែលសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងហានិភ័យជាច្រើនដូចជា ឧទាហរណ៍៖ ហានិភ័យឥណទាន ហានិភ័យ
ទីផ្សារ ហានិភ័យសន្ទនីយភាព ហានិភ័យប្រតិបត្តិការ និងហានិភ័យយុទ្ធសាស្ត្រ។ រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យ កំណត់យ៉ាងច្បាស់អំពីភារកិច្ច និងទំនួលខុសត្រូវពាក់ព័ន្ធនឹងអង្គភាពពាក់ព័ន្ធ រួមបញ្ចូលទាំងអង្គភាពគ្រប់គ្រងហានិភ័យឯករាជ្យ ខណៈដែលការវាស់វែងកែតម្រូវហានិភ័យត្រូវបានអនុវត្តជាមួយនឹងសកម្មភាពអាជីវកម្មនីមួយៗផ្ទាល់។

ការគ្រប់គ្រងហានិភ័យមូលធន និងសន្ទនីយភាពគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល ដែលទទួលខុសត្រូវចំពោះការធានានូវកម្រិតមូលធន និងសន្ទនីយភាពសមស្រប ដើម្បីការពារឱ្យបានសម្របសម្រួលប្រតិបត្តិការអាជីវកម្មបច្ចុប្បន្ន និងអនាគតរបស់យើង។ ទន្ទឹមនឹងនេះ ធនាគារ កម្ពុជាអាស៊ី ធានាថា គោលនយោបាយ ដំណើរការ និងប្រព័ន្ធសម្រាប់គ្រប់គ្រង តាមដានត្រួតពិនិត្យ និងរាយការណ៍អំពី ហានិភ័យ មូលធន និងសន្ទនីយភាព គឺដាក់ឱ្យអនុវត្តចំណែកឯការបែងចែកតួនាទី និងខ្សែរាយការណ៍គឺត្រូវបានកំណត់យ៉ាងច្បាស់លាស់ស្រប ទៅនឹងគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងល្អរបស់ធនាគារ។ យើងក៏សង្កត់ធ្ងន់លើការអនុវត្តការបង្ហាញ ហានិភ័យមូលធន និងសន្ទនីយភាពយ៉ាងលម្អិត សុក្រឹត និងទៀងទាត់។ យើងក៏សង្កត់ធ្ងន់ទៅលើការបង្ហាញអំពីការគ្រប់គ្រងហានិភ័យមូលធន និងសន្ទនីយភាពលម្អិត សុក្រឹត និងទៀងទាត់ដល់ទំនុកចិត្តរបស់សាធារណជនផងដែរ។

ការអភិវឌ្ឍន៍សំខាន់ៗដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យ

ធនាគារ កម្ពុជា អាស៊ី យកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ គោលនយោបាយឧបករណ៍ និងនីតិវិធីគ្រប់គ្រងហានិភ័យត្រូវបានបង្កើតឡើង និងត្រួតពិនិត្យជាប្រចាំដើម្បីឆ្លើយតបទៅនឹងនិន្នាការហានិភ័យថ្មីៗ ស្របតាមភាពប្រែប្រួលនៃទីផ្សារ និងធានាឱ្យមានភាពស្របគ្នាជាមួយនឹងតម្រូវការបទប្បញ្ញត្តិដែលបានទឹងកំពុងវិវត្តរួមទាំងគោលនយោបាយសេដ្ឋកិច្ចក្នុងស្រុក និងអន្តរជាតិ។ ចំនុចខាងក្រោមនេះបង្ហាញអំពីគំនិតផ្តួចផ្តើម និងសកម្មភាពសំខាន់ៗដែលធនាគារបានអនុវត្តក្នុងអំឡុងពេលរាយការណ៍។

(ក) ពង្រឹងដំណើរការ និងសំវិធានធនឱនភាព រួមបញ្ចូលទាំងការធ្វើស្ត្រេសតេស្តតាមលក្ខខណ្ឌតម្រូវផ្ទៃក្នុង និងលក្ខខណ្ឌតម្រូវរបស់ធនាគារជាតិនៃកម្ពុជា៖ គំរូហានិភ័យឥណទាន ការចាត់ថ្នាក់ទ្រព្យសកម្មសំវិធានធនកត្តាសេដ្ឋកិច្ចសេណារីយ៉ូករណីអាជីវកម្ម និងសូចនាករសេដ្ឋកិច្ច ត្រូវបានដាក់បញ្ចូលទៅក្នុងបទដ្ឋានរបស់យើង។ ជាមួយគ្នានេះដែរ យើងបានអនុលោមតាមលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិ និងបានផ្តល់នូវការព្យាករណ៍ហិរញ្ញវត្ថុ ដល់គណៈគ្រប់គ្រងជាន់ខ្ពស់ពីស្ថានភាពហិរញ្ញវត្ថុ និងយន្តការគ្រប់គ្រងចំណាយរបស់ ធនាគារដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានដែលអាចនឹងប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្ម និងផែនការវិនិយោគរបស់យើងរយៈពេលពីរឆ្នាំបន្ទាប់។

(ខ) ការបន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន៖ ធនាគារ កម្ពុជា អាស៊ី បានបន្តវិនិយោគលើការពង្រឹងនិងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មានរបស់ខ្លួន ។ ការធ្វើបច្ចុប្បន្នភាពក្នុងអំឡុងពេលរាយការណ៍នេះ រួមមានការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខ ការគ្រប់គ្រងសិទ្ធិចូលប្រើប្រាស់ និងសមត្ថភាពត្រួតពិនិត្យតាមដាន ដើម្បីធានាថាធនាគារមានយន្តការការពារដ៏រឹងមាំប្រឆាំងនឹងការគំរាមកំហែងផ្នែកសន្តិសុខសាយប័រដែលកំពុងកើនឡើង និងបន្តអនុលោមតាមក្របខ័ណ្ឌសន្តិសុខព័ត៌មានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

(គ) ការពង្រឹងការការពារទិន្នន័យ និងឯកជនភាពរបស់អតិថិជន៖ ក្រុមការងារបានអនុវត្តជំហានក្នុងការធានាការត្រៀមរៀបចំ ដោយអនុលោមតាមការការពារទិន្នន័យ និងឯកជនភាព។ វិធានការរួមមាន ការកែតម្រូវគោលនយោបាយព្រមទាំងការធ្វើបច្ចុប្បន្នភាពដំណើរការ និងបច្ចេកវិទ្យា ដោយគ្របដណ្តប់លើវិធានការត្រួតពិនិត្យ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការគ្រប់គ្រងការអនុញ្ញាត និងការអនុវត្តសិទ្ធិរបស់អតិថិជន។ លើសពីនេះ យើងបានផ្សព្វផ្សាយជាបន្តបន្ទាប់ដល់និយោជិត និងដៃគូសាជីវកម្ម ដើម្បីធានាថាពួកគាត់ទទួលស្គាល់អំពីសារៈសំខាន់នៃអនុលោមភាពតាមការការពារទិន្នន័យ និងឯកជនភាព ស្របពេលដែលរបាយការណ៍វឌ្ឍនភាពត្រូវបានត្រួតពិនិត្យ និងបង្ហាញជូនគណៈគ្រប់គ្រងរបស់ ធនាគារ កម្ពុជា អាស៊ី យ៉ាងទៀងទាត់។

(ឃ)ការបង្កើតក្របខ័ណ្ឌគ្រប់គ្រងផលិតផលពេញលេញ៖ ធនាគារ កម្ពុជា អាស៊ី បានដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌគ្រប់គ្រងផលិតផលបែបដ៏ទូលំទូលាយមួយ ដែលត្រូវបានរៀបចំឡើងដើម្បីធានាថា ផលិតផល និងសេវាកម្មសំខាន់ៗទាំងអស់ត្រូវបានអភិវឌ្ឍ ដាក់ឱ្យប្រើប្រាស់ និងតាមដានត្រួតពិនិត្យតាមរបៀបដែលមានស្តង់ដារ ស្របគ្នា និងស្ថិតក្រោមការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព។ ក្របខ័ណ្ឌនេះធានាថា ការផ្តល់ជូនផលិតផល និងសេវាកម្មនៅតែស្របតាមតម្រូវការរបស់អតិថិជន ស្ថិតក្រោមវិធានការគ្រប់គ្រងហានិភ័យសមស្រប និងត្រូវបានគ្រប់គ្រងឱ្យស្ថិតនៅក្នុងកម្រិតនៃការទទួលយកហានិភ័យដែលអាចទទួលយកបាន ពេញមួយវដ្តជីវិតរបស់ផលិតផល។

(ង) ការបង្កើតគោលការណ៍ណែនាំ និងការត្រួតពិនិត្យហានិភ័យប្រតិបត្តិការ៖ ធនាគារបានពង្រឹងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យប្រតិបត្តិការ ឱ្យកាន់តែមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់នៅទូទាំងនាយកដ្ឋាននានា ដោយមានការត្រួតពិនិត្យ និងទទួលខុសត្រូវពីប្រធាននាយកដ្ឋាននីមួយៗ ដែលជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រង។ ការពង្រឹងនេះមានគោលបំណងធានាថា ធនាគារអាចផ្តល់ជូននូវផលិតផល និងសេវាកម្មចម្រុះ ដែលស្របតាមតម្រូវការរបស់អតិថិជន និងត្រៀមខ្លួនសម្រាប់កំណើនអាជីវកម្មក្នុងយុគសម័យឌីជីថលប្រកបដោយប្រសិទ្ធភាពកាន់តែខ្ពស់ ខណៈដែលហានិភ័យសំខាន់ៗ និងបញ្ហាអនុលោមភាពត្រូវបានកំណត់ អនុវត្តការគ្រប់គ្រង និងតាមដានយ៉ាងមានសុវត្ថិភាព និងសមស្រប។

(ច) ការពង្រឹងការគ្រប់គ្រងដៃគូអាជីវកម្ម និងការគ្រប់គ្រងហានិភ័យភាគីទីបី៖ ដែលគ្របដណ្តប់លើការវាយតម្លៃហានិភ័យ ការជ្រើសរើស ដំណើរការ ការរៀបចំកិច្ចសន្យា ការតាមដានត្រួតពិនិត្យហានិភ័យ និងការបញ្ចប់សេវាកម្មជាមួយដៃគូអាជីវកម្ម និងភាគីទីបី ដើម្បីធានានូវការពង្រឹងសន្តិសុខសម្រាប់ប្រតិបត្តិការអាជីវកម្ម និងការបង្កើនប្រសិទ្ធភាពទៅលើការចាប់រកការក្លែងបន្លំក្នុងទម្រង់ជាច្រើន ដើម្បីការគ្របដណ្តប់កាន់តែទូលាយ។

(ឆ) ដាក់ឱ្យដំណើរការនូវការគ្រប់គ្រងក្រមប្រតិបត្តិទីផ្សារ៖ ស្របតាមតម្រូវការ ស្ថានភាពហិរញ្ញវត្ថុ និងការយល់ដឹងរបស់អតិថិជន ដើម្បីធានាថាអតិថិជនទទួលបានសេវា និងការប្រព្រឹត្តចំពោះប្រកបដោយយុត្តិធម៌ជាមួយនឹងព័ត៌មានពេញលេញ និងសុក្រឹតអំពីផលិតផល និងសេវាកម្ម។

ការគ្រប់គ្រងហានិភ័យ

ធនាគារ កម្ពុជាអាស៊ី ចំកាត់ បានសង្កត់ធ្ងន់ផ្តោតទៅលើការគ្រប់គ្រងហានិភ័យគ្រប់ជ្រុងជ្រោយដូចជា ហានិភ័យ តណទាន ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព ហានិភ័យប្រតិបត្តិការ និង ហានិភ័យយុទ្ធសាស្ត្រ ហានិភ័យ ទាំងអស់នេះគឺត្រូវបានត្រួតពិនិត្យតាមដាន និងគ្រប់គ្រងបានយ៉ាងសមស្រប។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ មានគោលបំណង និងគោលដៅការពារធនាគារ និងដំណើរការគ្រប់គ្រងរបស់ខ្លួន ដោយការដោះស្រាយយ៉ាងសកម្មនូវការគំរាមកំហែង ឬបញ្ហាណាមួយដែលអាចកើតមាន។

នាយកដ្ឋានគ្រប់គ្រងហានិភ័យបានទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍ អនុវត្ត និងត្រួតពិនិត្យកម្មវិធីគ្រប់គ្រងហានិភ័យ របស់ធនាគារ។ រួមបញ្ចូលទាំងការធានាថា ធនាគារ សំដៅទៅលើការបាត់បង់សក្តានុពលដែលជាច្រើនកើតឡើង ដោយសារតែភាពមិនច្បាស់លាស់នៃការកើតឡើងនៃព្រឹត្តិការណ៍មួយចំនួន។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ ក៏បានផ្តល់ការណែនាំ និងការបណ្តុះបណ្តាលដល់បុគ្គលិកគ្រប់ផ្នែក/នាយកដ្ឋានផ្សេងៗ លើបញ្ហាគ្រប់គ្រងហានិភ័យ និងសហការជាមួយនាយកដ្ឋានផ្សេងទៀត ដើម្បីធានាថាហានិភ័យត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

នៅក្នុងឆ្នាំ២០២៥ នាយកដ្ឋានគ្រប់គ្រងហានិភ័យ បានបោះជំហានយ៉ាងសំខាន់ក្នុងការពង្រឹងកម្មវិធីគ្រប់គ្រងហានិភ័យ របស់ធនាគារ កម្ពុជា អាស៊ី។ ការគ្រប់គ្រងហានិភ័យដើម្បីធានា និងផ្តល់នូវសកម្មភាពត្រួតពិនិត្យហានិភ័យសម្រាប់ប្រភេទហានិភ័យសំខាន់ៗនៅក្នុងសកម្មភាពរបស់ធនាគារ និង/ឬសមិទ្ធិផលសំខាន់ៗមួយចំនួនរួមមាន:

- **ការគ្រប់គ្រងហានិភ័យតណទាន**

ហានិភ័យតណទានសំដៅដល់ហានិភ័យដែលកើតឡើងតាមរយៈ សមភាគី ឬអ្នកខ្ចី អាចនឹងខកខានមិនបំពេញតាមកាតព្វកិច្ចនៃកិច្ចសន្យា កិច្ចព្រមព្រៀង ឬមានចេតនាទុច្ចរិត មិនគោរពកាតព្វកិច្ចតាមកិច្ចព្រមព្រៀងដែលបណ្តាលឱ្យមានការសងត្រឡប់មកដល់ធនាគារ កម្ពុជាអាស៊ី ។ ដូច្នេះធនាគារ កម្ពុជាអាស៊ី ក៏បានសង្កត់ធ្ងន់ជាសំខាន់លើការគ្រប់គ្រងហានិភ័យតណទាន ស្រប តាមបទដ្ឋានអន្តរជាតិ និងលក្ខខណ្ឌបទប្បញ្ញត្តិជាតិ ដើម្បីការពារផលប៉ះពាល់សង្គម បរិស្ថាន និងការប្រែប្រួល អាកាសធាតុ ដែលអាចនឹងបង្កឡើងដោយប្រតិបត្តិការអាជីវកម្មរបស់ ធនាគារ កម្ពុជាអាស៊ី ក្នុងគោលបំណងដើម្បីធានាបាននូវកំណើនប្រកបដោយចីរភាព និងផលចំណេញសមហេតុផលដល់ភាគីពាក់ព័ន្ធ។

នៅក្នុងឆ្នាំ២០២៥ ធនាគារ កម្ពុជា អាស៊ី បានផ្តោតលើសេវាអតិថិជន និងការគ្រប់គ្រងហានិភ័យ តណទាន សម្រាប់គ្រប់អតិថិជនគោលដៅទាំងអស់ ដើម្បីធានាថាកម្រិតហានិភ័យគឺស្ថិតនៅក្រោម ការកំណត់ហានិភ័យដែលធនាគារអាចទទួលយកបាន។ ទន្ទឹមនឹងនេះការរីកចំរើន ក៏ដូចជាការរំខានផ្នែក ឌីជីថលដែលជំរុញឱ្យ ធនាគារ កម្ពុជា អាស៊ី ផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនលើលក្ខណៈវិនិច្ឆ័យត្រួតពិនិត្យអតិថិជនតឹងរ៉ឹង ស្របពេលដែលកំណត់អាទិភាពលើវិធានការជំនួយប្រកប ដោយចីរភាពជាពិសេសសម្រាប់អាជីវកម្មធុនតូច និងមីក្រូ ក៏ដូចជាអាជីវកម្មលក់រាយដែលមានស្ថានភាពហិរញ្ញវត្ថុ រឹងមាំ និងសមត្ថភាពសងបំណុលល្អ។ លើសពីនេះ ធនាគារ កម្ពុជាអាស៊ី ចំកាត់ មានគោលនយោបាយ ដើម្បីដាក់បញ្ចូលហានិភ័យពាក់ព័ន្ធ និងសុខភាពហិរញ្ញវត្ថុសាធារណៈដែលអាចនឹងប៉ះពាល់ដល់ប្រតិបត្តិការ អាជីវកម្មរបស់អតិថិជនតាមរយៈហានិភ័យរូបសាស្ត្រ និងហានិភ័យអន្តរកាលដែលជាកត្តាមួយក្នុង ចំណោមកត្តានានាសម្រាប់ដំណើរការធានាតណទាន និងប្រើប្រាស់គោលនយោបាយនេះជាសមាសធាតុមួយក្នុងចំណោមសមាសធាតុនានាក្នុងការវាយតម្លៃផលប៉ះពាល់មកលើផលបត្រតណទានរបស់ធនាគារ។ ធនាគារ កម្ពុជា អាស៊ី ក៏បានផ្តោតលើការគ្រប់គ្រងផលបត្រ ដើម្បីរក្សាការប្រមូលផ្តុំតណទាន ជាមួយនឹងកម្រិតកំណត់ដែលបានបង្កើតនិងគោលដៅកំណើនតណទានត្រូវបានបង្កើតឡើងដោយ ស្របតាមស្ថានភាពសេដ្ឋកិច្ចអំណោយផល ដោយគិតគូរពិចារណាទៅលើអតិថិជនគោលដៅ វិស័យ និងឧស្សាហកម្ម ផលិតផល ដើម្បីបង្កើនផលចំណេញឱ្យដល់កម្រិតអតិបរិមានៅក្រោមវិសាប់ភៃថាយ។ ធនាគារ បានសង្កត់ធ្ងន់ទៅលើការរកឃើញសញ្ញាព្រមានដំបូងរបស់អតិថិជន និងការតាមដានត្រួតពិនិត្យតរិយាបថដើម្បីធានាបាននូវដំណើរការតាមដានត្រួតពិនិត្យ ស្តារឡើងវិញ និងប្រមូលប្រកប ដោយប្រសិទ្ធភាព។ លើសពីនេះ អាចរក្សាសំវិធានធនសមស្របដាច់ដោយឡែក ដើម្បីធានាការពារ និងគ្របដណ្តប់លើ ការខាតបង់តណទានដែលរំពឹងទុកដែលស្របតាមប្រតិបត្តិការអាជីវកម្មដោយការយកចិត្តទុកដាក់នៅគ្រាមានភាពមិនច្បាស់លាស់ផ្នែកសេដ្ឋកិច្ចដែលនឹងកំពុងប្រឈមបន្តជាដើម។

- **ការគ្រប់គ្រងហានិភ័យទីផ្សារ**

ហានិភ័យទីផ្សារ អាចកើតឡើងពីការប្រែប្រួលនៃអត្រាការប្រាក់ ការប្តូររូបិយប័ណ្ណបរទេស និងតម្លាតតណទាន។ ការប្រែប្រួលទាំងនេះប៉ះពាល់ដល់ចំណូលមូលធន តម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មដូចជាធាតុក្រៅតារាងតុល្យការរបស់ធនាគារនាពេលបច្ចុប្បន្ន និងអនាគត។ ធនាគារ កម្ពុជាអាស៊ី ចំកាត់ បានចូលរួមនៅក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសរុបតាមរយៈការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការសំខាន់ៗ សម្រាប់ការគ្រប់គ្រងហានិភ័យទីផ្សារនៃផលិតផលហិរញ្ញវត្ថុបានទាន់ពេលវេលា និងសមស្រប។ លើសពីនេះ យើងបានបង្កើតដំណើរការគ្រប់គ្រងផលិតផលសម្រាប់ទាំងផលិតផលមានស្រាប់ និងផលិតផលថ្មីដោយផ្អែកលើផែនការអាជីវកម្មដោយមានការត្រួតពិនិត្យ និងការពារហានិភ័យទីផ្សារ លើគោលបំណង និងដំណើរការប្រតិបត្តិការកត្តាពាក់ព័ន្ធហានិភ័យទីផ្សារការវិភាគហានិភ័យ និងផលប៉ះពាល់ដែលអាចកើតមាន ក៏ដូចជាគោលការណ៍ណែនាំអំពីការវាយតម្លៃនិងគ្រប់គ្រងហានិភ័យផងដែរ។

- **ការគ្រប់គ្រងហានិភ័យសន្ទនីយភាព**

ហានិភ័យសន្ទនីយភាព គឺត្រូវបានកំណត់និយមន័យថាជាហានិភ័យបង្កឡើងដោយការខកខានមិនអាចទទួលបានមូលនិធិគ្រប់គ្រាន់នៅថ្លៃចំណាយសមស្រប ដើម្បីបំពេញកាតព្វកិច្ចនៅពេលកាលបរិច្ឆេទកំណត់ និងឬការមិនមានលទ្ធភាពនៅក្នុងការបម្លែង

ទ្រព្យសកម្មទៅជាសាច់ប្រាក់។ ហានិភ័យសន្ទនីយភាព នៃការបាត់បង់ដែលកើតឡើងពីស្ថានភាពដែល 1) នឹងមិនមានសាច់ប្រាក់គ្រប់គ្រាន់ និង/ឬសមមូលសាច់ប្រាក់ដើម្បីបំពេញតម្រូវការរបស់អ្នកដាក់ប្រាក់បញ្ញើ អ្នកខ្ចី និងបំណុលដែលអាចកើតមាន 2) ការលក់ទ្រព្យសកម្មមិនអាចទទួលបានទិន្នផលទាបជាងតម្លៃសមធម៌របស់ពួកគេ និង 3) ទ្រព្យសកម្មដែលមិនអាចលក់បាននៅពេលខ្វះអ្នកទិញ។

សន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារ គឺមានការកើនឡើងនៅពេលដែលកំណើនឥណទានធំជាងកំណើនប្រាក់បញ្ញើ ខណៈដែលធនាគារបានយកប្រាក់ចំណេញរក្សាទុក និងបំណុលរបស់ខ្លួនមកបន្ធូរបន្ថយសម្ពាធសេដ្ឋកិច្ច និងផ្តល់នូវការបន្ធូរបន្ថយដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSME) និងអ្នកប្រើប្រាស់ក្នុងការពន្យារពេលបង់ប្រាក់ និងកំណត់រយៈពេលឥណទានរបស់ពួកគេឡើងវិញ។ ធនាគារ បានបំពាក់ជាមួយនូវឧបករណ៍យ៉ាងពេញលេញសម្រាប់ការគ្រប់គ្រងសន្ទនីយភាពសមស្រប ដើម្បីការពារធនាគាររបស់យើងពីកង្វះសន្ទនីយភាព។ ក្រៅពីការតាមដានត្រួតពិនិត្យហានិភ័យសន្ទនីយភាពប្រកប ដោយប្រសិទ្ធភាពនៅក្នុងស្ថានភាពដែលអាចទទួលរងហានិភ័យដោយប្រយោល យើងក៏បានអនុម័តយកនូវផែនការបន្តអាជីវកម្ម ដើម្បីការពារពីការរំខានដល់ប្រតិបត្តិការ និងប្រព័ន្ធសំខាន់ៗដែលអនុញ្ញាតឱ្យយើងបំពេញកាតព្វកិច្ចរបស់យើងបានទៅក្នុងគ្រាអាសន្ន។ធនាគារ បានអនុវត្តការវាយតម្លៃ និងការវិភាគហានិភ័យសន្ទនីយភាពជាទៀងទាត់ ដើម្បីធានាបាននូវសន្ទនីយភាពគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់យើង តាមរយៈការវិភាគគម្លាតសន្ទនីយភាព ដោយគ្របដណ្តប់ទាំងស្ថានភាពធម្មតា និងស្ថានភាពមានវិបត្តិដែលស្ថិតនៅក្រោមសេណារីយ៉ូចំនួនបី ឧទាហរណ៍ វិបត្តិសន្ទនីយភាពដែលជាក់លាក់តាមធនាគារ ទូទាំង ទីផ្សារ ឬជាការរួមផ្សំនៃកាលៈទេសៈទាំងពីរនេះ។ ធនាគារ ក៏បានបង្កើតនូវឧបករណ៍ដើម្បីវាយតម្លៃ និងវិភាគហានិភ័យសន្ទនីយភាពដែលបំពេញតាមបទដ្ឋានអន្តរជាតិ រួមបញ្ចូលទាំងអនុបាតក្របខ័ណ្ឌសន្ទនីយភាព (LCR) និងអនុបាតមូលនិធិស្ថិរភាពសុទ្ធ (NFSR)។ ធនាគារបានបង្កើតឧបករណ៍សម្រាប់ការវាយតម្លៃ និងការវិភាគហានិភ័យសន្ទនីយភាព ជាបន្តបន្ទាប់ស្របតាមបទដ្ឋានអន្តរជាតិ។ យើងកំណត់នូវយុទ្ធសាស្ត្រសមស្រប ដើម្បីរក្សាកម្រិតសមស្របនៃទ្រព្យសកម្ម សន្ទនីយភាពនៃរូបិយប័ណ្ណបរទេស ឱ្យមានសង្គតិភាពជាមួយនឹងកំណើនប្រាក់បញ្ញើ និងដើម្បីការពារពីហានិភ័យសន្ទនីយភាពកើនឡើងណាមួយដែលកើតចេញពីភាពឆាប់ប្រែប្រួលនៅក្នុងសេដ្ឋកិច្ចសកល និងការប្រែប្រួលយ៉ាងឆាប់រហ័សនៃទីផ្សារហិរញ្ញវត្ថុ ដោយពិចារណាទៅលើសក្តានុពលរីកចម្រើននៃអាជីវកម្ម។

កត្តាដែលបានតាមដានត្រួតពិនិត្យបានដិតដល់ ដែលអាចប៉ះពាល់ដល់ហានិភ័យសន្ទនីយភាព និងអត្រាការប្រាក់ រួមមាន៖
(ក) ទិន្នាការអត្រាគោលនយោបាយសំខាន់ៗរបស់ ធនាគារជាតិនៃកម្ពុជា និងធនាគារ កណ្តាល។
(ខ) ចលនាមូលធនបរទេសដោយផ្ទាល់ និងដោយប្រយោលដែលជំរុញដោយហានិភ័យផ្ទៃក្នុង និងហានិភ័យខាងក្រៅ។
(គ) ការប្រកួតប្រជែងកាន់តែខ្លាំង នៅក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុទៅលើផលិតផលបញ្ញើសន្សំ និងវិនិយោគដែលអាចប៉ះពាល់ដល់សន្ទនីយភាពទាំងមូលនៅក្នុងប្រព័ន្ធធនាគារ។
(ឃ) តម្រូវការឥណទានកើនឡើង ដែលអាចបង្កើតឱ្យមានសម្ពាធទៅលើសន្ទនីយភាពនៅក្នុងប្រព័ន្ធ។

- **ការគ្រប់គ្រង់ហានិភ័យប្រតិបត្តិការ**

ហានិភ័យប្រតិបត្តិការ សំដៅទៅលើហានិភ័យនៃការខាតបង់ដោយផ្ទាល់ ឬដោយប្រយោលចំពោះចំណូល ឬមូលធនកើតចេញពីដំណើរការ បុគ្គលិក ប្រព័ន្ធប្រតិបត្តិការ និងឬប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ឬព្រឹត្តិការណ៍ខាងក្រៅ។ ដូច្នេះ ធនាគារ កម្ពុជាអាស៊ី បានផ្តោតសំខាន់ទៅលើការគ្រប់គ្រងហានិភ័យប្រតិបត្តិការតាមរយៈការបង្កើតគោលនយោបាយ និងក្របខ័ណ្ឌហានិភ័យប្រតិបត្តិការ ដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យប្រតិបត្តិការជាបទដ្ឋានឯកសណ្ឋានជំរុញការពង្រឹងដែលអនុញ្ញាតឱ្យយើងរាយតម្លៃហានិភ័យ និងស្វែងរកវិធានការទប់ស្កាត់លក្ខណៈបុរេសកម្ម។

ធនាគារ កម្ពុជា អាស៊ី បានដាក់ឱ្យប្រើប្រាស់នូវដំណើរការពិចារណាលើហានិភ័យពាក់ព័ន្ធសុខភាពសាធារណៈនៅទូទាំងធនាគារ មានដូចជា ការកំណត់ វាយតម្លៃ និងបញ្ចៀសផលប៉ះពាល់ពាក់ព័ន្ធនឹងអាកាសធាតុមកលើធនាគារ ដើម្បីធានាបាននូវការបន្តអាជីវកម្ម និងការការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់អតិថិជន និយោជិត និងភាគីពាក់ព័ន្ធផ្សេងៗទៀតរបស់យើង។ ដំណើរការពិរចាណាលើហានិភ័យ ត្រូវបានអនុវត្តជាផ្នែកមួយនៃនីតិវិធីគ្រប់គ្រងហានិភ័យទាំងមូលជារៀងរាល់ឆ្នាំ ឬលើសពីម្តងក្នុងមួយឆ្នាំ ដើម្បីតាមទាន់និន្នាការថ្មីៗ ដោយធានាថា យើងអាចសម្របខ្លួនទៅនឹងហានិភ័យពាក់ព័ន្ធនឹងអាកាសធាតុបានទាន់ពេលវេលា។

- **ការគ្រប់គ្រងហានិភ័យយុទ្ធសាស្ត្រ**

ហានិភ័យយុទ្ធសាស្ត្រ សំដៅដល់ហានិភ័យដែលកើតចេញពីការបង្កើត និងការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការអាជីវកម្មដែលមិនសមស្របនិងមិនមានសង្គតិភាពជាមួយនឹងកត្តាខាងក្នុង និងបរិយាកាសខាងក្រៅ ដែលអាចនឹងប៉ះពាល់ដល់ការរកប្រាក់ចំណេញ មូលនិធិដើមទុន ឬស្ថិរភាពរបស់ ធនាគារ កម្ពុជាអាស៊ី ចំកាត់។ ដូច្នេះ ធនាគារ សង្កត់ធ្ងន់ទៅលើសមាហរណកម្មនៃដំណើរការបង្កើត និងអនុវត្តយុទ្ធសាស្ត្រ។ ដំណើរការនេះចាប់ផ្តើមពីការប្រមៃប្រមូល និងវិភាគទិន្នន័យលក្ខណៈជាប្រព័ន្ធសម្រាប់ប្រើប្រាស់នៅក្នុងការត្រួតពិនិត្យ និងកំណត់យុទ្ធសាស្ត្រទូទាំងធនាគារសមស្រប ដែលបន្ទាប់មកត្រូវបានបកស្រាយទៅជាយុទ្ធសាស្ត្រសម្រាប់អង្គភាពអាជីវកម្ម និងអង្គភាពគាំទ្រគោលបំណង និងលទ្ធផលសំខាន់ៗ។

ដំណើរការនេះក៏រួមបញ្ចូលនូវការបែងចែកធនធាន ឬការផ្សព្វផ្សាយនៅទូទាំងធនាគារនៃផែនការយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ការបង្កើតផែនការប្រតិបត្តិការ និងដំណើរការតាមដានត្រួតពិនិត្យច្បាស់លាស់ ក៏ដូចជាការកំណត់ពីបញ្ហា និងដំណោះស្រាយផងដែរ។

ទន្ទឹមនឹងនេះ ធនាគារ កម្ពុជាអាស៊ី ក៏បានចូលរួមដោះស្រាយបញ្ហាប្រឈមទៅនឹងហានិភ័យប្រតិបត្តិការដែលប៉ះពាល់ពីអនុលោមភាពតាមគោលនយោបាយរដ្ឋាភិបាល រួមបញ្ចូលទាំងវិធាន និងបទប្បញ្ញត្តិ និងបទដ្ឋានថ្មីៗ ពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រឹះស្ថានហិរញ្ញវត្ថុដើម្បីផ្តល់ជំនួយឱ្យដល់ អាជីវកម្ម និងអតិថិជនលក់រាយដែលរងការប៉ះពាល់ដោយការរាតត្បាតនៃជំងឺ ឬបញ្ហាសង្គ្រាមក្នុងកំឡុងពេលដែលមានការប្រែប្រួលសំហូរមូលធនសកលបង្កឡើងដោយការស្តារឡើងវិញខុសៗគ្នានៅតាមបណ្តាប្រទេសជាច្រើនជាពិសេស ការស្តារសេដ្ឋកិច្ចឡើងវិញ។

៤. យុទ្ធសាស្ត្រឌីជីថលជាចម្បង

ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន

ចាប់តាំងពីឆ្នាំ២០២១មក ធនាគារ កម្ពុជាអាស៊ី បានវិនិយោគទៅលើប្រព័ន្ធសេវាធនាគារស្នូលថ្មីៗដែលដំណើរការដោយ Oracle Flexcube និងបានដាក់ឱ្យដំណើរការនូវបច្ចេកវិទ្យាបណ្តាញហិរញ្ញវត្ថុថ្មីៗឆ្លើយតបទៅនឹងការផ្លាស់ប្តូរទៅកាន់បច្ចេកវិទ្យារូបិយប័ណ្ណឌីជីថល ដោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា សម័យថ្មី ព្រមទាំងស្រារជ្រារកនវានុវត្តន៍ស្របជាមួយនឹងទិសដៅជាយុទ្ធសាស្ត្ររបស់ធនាគារ កម្ពុជា អាស៊ី។ កិច្ចខិតខំប្រែងប្រែងទាំងនេះគឺត្រូវបានអនុវត្តជាមួយនឹងដំណើរការការងារប្រកបដោយប្រសិទ្ធផលនៅក្រោមបទដ្ឋានអន្តរជាតិនិងប្រព័ន្ធគ្រប់គ្រងសន្តិសុខប្រព័ន្ធអ៊ីនធឺណិតថ្មីចុងក្រោយបង្អស់។ គោលការណ៍ណែនាំអំពីការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីសម្របទៅនឹងផលប៉ះពាល់រយៈពេលខ្លី មធ្យម និងរយៈពេលវែងនៅក្នុងអំឡុងពេលនៃអន្តរកាលនេះ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្ររក្សាលទ្ធភាពប្រកួតប្រជែងរបស់ធនាគារ កម្ពុជា អាស៊ី និងការក្លាយជាធនាគារនាំមុខគេក្នុងតំបន់ជាទីទុកចិត្តនៅក្នុងសម័យបច្ចេកវិទ្យា។ គំនិតផ្តួចផ្តើមចម្បងៗអាចសង្ខេប បានដូចតទៅ៖

ជាផ្នែកមួយនៃការអភិវឌ្ឍន៍ផលិតផល និងសេវាកម្មថ្មីៗ ធនាគារបានទទួលយកបច្ចេកវិទ្យាទំនើបៗ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរអាកប្បកិរិយារបស់អតិថិជន និងតម្រូវការនៃប្រព័ន្ធអេកូហិរញ្ញវត្ថុទំនើប។ ការច្នៃប្រឌិតសំខាន់ៗដែលត្រូវបានណែនាំក្នុងឆ្នាំនេះរួមមានប្រព័ន្ធគ្រប់គ្រងកាត (CMS), Visa, UPI, Master Card, ប្រព័ន្ធធនាគារស្នូល (CBS), ធនាគារឌីជីថល, NBC Bakong, KHQR Merchant, CSS, NCS និង FAST ។ ភាពជឿនលឿនទាំងនេះដាក់ធនាគារ កម្ពុជា អាស៊ី នៅជួរមុខនៃធនាគារឌីជីថល ដោយបើកដំណើរការសេវាកម្មហិរញ្ញវត្ថុកាន់តែរហ័ស សុវត្ថិភាព និងផ្តោតលើអតិថិជន។

ភាពជាដៃគូរបស់យើង គឺត្រូវបានបង្កើនជាមួយនឹងចំណេះដឹង និងការអនុវត្តល្អដែលជាសិល្បៈនៃការធ្វើអាជីវកម្ម និងបានបណ្តុះបណ្តាលដល់និយោជិតនៃ ធនាគារ កម្ពុជា អាស៊ីរបស់យើង។

កិច្ចពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

សេចក្តីសង្ខេបប្រតិបត្តិនៃកិច្ចពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

យើងបានបន្តពង្រឹងសមត្ថភាព និងនវានុវត្តចំពោះសេវាកម្មរបស់យើង តាមរយៈការអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថល ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដើម្បីឱ្យតាមទាន់តរិយាបថអតិថិជនដែលមានការប្រែប្រួល ស្របពេលដែលផ្តល់នូវឱកាសអាជីវកម្មថ្មីៗ បរិបទអាជីវកម្មដែលពិចារណាលើការគ្រប់គ្រងហានិភ័យរួមបញ្ចូលដែលមានលក្ខណៈបុរេសកម្ម ក៏ដូចជារឹប្បធម៌យល់ដឹងអំពីហានិភ័យនៅទូទាំងធនាគារ ដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់យើងជាគ្រឹះស្ថានហិរញ្ញវត្ថុនាំមុខគេមួយ ដែលតែងតែត្រៀមលក្ខណៈរួចរាល់សម្រាប់ការប្រែប្រួលសេដ្ឋកិច្ចដែលអាចកើតមានឡើងទាំងនៅក្រោមស្ថានភាពធម្មតា និងស្ថានភាពលំបាក។

ដូច្នេះសមិទ្ធផលប្រតិបត្តិការឆ្នាំ២០២៥ របស់ ធនាគារ កម្ពុជាអាស៊ី បានបំពេញតាមគោលដៅអាជីវកម្មរបស់យើងដូចបានរំពឹងទុកស្របជាមួយនឹងលក្ខខណ្ឌសេដ្ឋកិច្ច។ ប្រតិបត្តិការរបស់យើងទទួលបានការទទួលយក និងការទទួលស្គាល់យ៉ាងទូលំទូលាយនៅប្រទេសកំណើត និងភ្ញៀវទេសចរមកពីជុំវិញពិភពលោក តាមរយៈវត្តមានរបស់យើង នៅមជ្ឈមណ្ឌលជីកជញ្ជួនអន្តរជាតិទីតាំងទេសចរណ៍ សំខាន់ៗ មជ្ឈមណ្ឌលកម្សាន្ត និងវេទិកាសង្គម។ ដូច្នេះ រាល់កិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលទាំងអស់ខាងលើរបស់ធនាគារ កម្ពុជា អាស៊ី ត្រូវបានអនុវត្តប្រកបដោយការយកចិត្តទុកដាក់ និងតាមទាន់តម្រូវការរបស់អតិថិជនដែលមានការប្រែប្រួលជានិច្ចរួមជាមួយនឹងការយល់ដឹងអំពីភាពមិនច្បាស់ លាស់ផ្នែកសេដ្ឋកិច្ច ដែលកំពុងតែងើបឡើងវិញជាបណ្តើរៗតាមរយៈការរស់នៅតាមបែបគន្លងថ្មី។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងអនុញ្ញាតឱ្យយើងបង្កើតផែនការក្នុងការសម្របខ្លួនទៅនឹងផលប៉ះពាល់ដែលអាចកើតឡើងណាមួយមកលើអាជីវកម្មរបស់យើង ស្របពេលដែលផ្តល់ជូនអតិថិជនរបស់យើងនូវការគាំទ្រប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាផងដែរ។

អភិបាលកិច្ចសាជីវកម្ម

ធនាគារ កម្ពុជា អាស៊ី ទទួលស្គាល់ចំពោះសារៈសំខាន់នៃអភិបាលកិច្ចសាជីវកម្ម និងតែងតែអភិវឌ្ឍអភិបាលកិច្ចល្អនៅក្នុងធនាគារ។ ភារកិច្ច និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលគឺត្រូវបានត្រួតពិនិត្យ និងបង្កើតឡើងជាញឹកញាប់ ដើម្បីធានាបាននូវអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រតិបត្តិការធនាគារ និងភារកិច្ចស្នូលសម្រាប់ភាគហ៊ុនិក អតិថិជន និយោជិត និងភាគីពាក់ព័ន្ធផ្សេងៗទៀត។ ធនាគារ កម្ពុជាអាស៊ី មានអភិបាលឯករាជ្យ។ ក្រុមប្រឹក្សាភិបាលមានឱកាស និងការអនុញ្ញាតពេញលេញក្នុងការអនុវត្តការពិភាក្សាសម្រេច និងការប្រព្រឹត្តប្រកបដោយវិជ្ជាជីវៈ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល គឺត្រូវបានជ្រើសតាំងដោយភាគហ៊ុនិក ក្នុងការដើរតួនាទីជាភ្នាក់ងារ។

សមាសភាពក្រុមប្រឹក្សាភិបាល គឺមានដូចខាងក្រោម៖

លោក Va Dalot	ប្រធានក្រុមប្រឹក្សាភិបាល
លោក Wong Tow Fock	អភិបាល និងនាយកប្រតិបត្តិ
លោក Top Ratheanin	អភិបាល
លោក Chan Peng Leong	អភិបាល
លោក Rouer Jerome	អភិបាលឯករាជ្យ

សមិទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល គឺត្រូវត្រួតពិនិត្យជារៀងរាល់ឆ្នាំ។ នៅចុងបញ្ចប់អាណត្តិនីមួយៗ សមាជិកភាពនឹងត្រូវបានបន្ត និងអនុម័តដោយផ្អែកលើសមិទ្ធផលការងាររបស់សមាជិកម្នាក់ៗ។ ភារកិច្ច និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលរួមមាន៖

- រាយការណ៍ជូនក្រុមប្រឹក្សាភិបាលទាំងមូលអំពីលទ្ធផលការងារ និងការរកឃើញនានា ដែលស្ថិតក្នុងវិសាលភាពនៃតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន;
- ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលទាំងមូលអំពីការតែងតាំងសវនករឯករាជ្យ ការកំណត់កម្រៃសវនកម្ម វិសាលភាពនៃសវនកម្ម និងផែនការសវនកម្ម;
- រាយតម្លៃនីតិវិធីសវនកម្មផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្នុង ព្រមទាំងភាពសមស្របរបស់នីតិវិធីទាំងនោះ ក្នុងបរិបទហានិភ័យដែលមានការផ្លាស់ប្តូរជាបន្តបន្ទាប់ (ជាពិសេសការកើនឡើងនៃប្រតិបត្តិការគ្មានក្រដាស) ពិនិត្យលទ្ធផលនៃការអនុវត្ត និងផ្តល់អនុសាសន៍សម្រាប់ការកែលម្អ;
- ស្នើសុំ ទទួល និងពិនិត្យរបាយការណ៍ និងអនុសាសន៍នានាពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង ទាំងក្នុងកិច្ចប្រជុំទៀងទាត់ និងនៅពេលផ្សេងទៀតតាមការចាំបាច់ ដោយធានាថាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងអាចទំនាក់ទំនង និងរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការបានគ្រប់ពេលវេលា លើបញ្ហាណាមួយដែលលោក/លោកស្រីយល់ថាអាចប៉ះពាល់ដល់សុចរិតភាពហិរញ្ញវត្ថុ និងអភិបាលកិច្ចល្អរបស់ធនាគារ;
- ពិគ្រោះយោបល់ជាមួយសវនករឯករាជ្យអំពីភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងពិនិត្យលិខិតជូនដំណឹងពីថ្នាក់គ្រប់គ្រង(Management Letters) ឬរបាយការណ៍លម្អិត (Long Form Reports);
- ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងប្រចាំត្រីមាស;
- ពិនិត្យរបាយការណ៍ត្រួតពិនិត្យពីអាជ្ញាធរនិយតកម្ម;
- ពិនិត្យរបាយការណ៍ និងអនុសាសន៍ពីសវនករឯករាជ្យ និងធានាថាថ្នាក់គ្រប់គ្រងបានអនុវត្តវិធានការកែតម្រូវសមស្រប;
- ពិនិត្យវិភាគពីទិដ្ឋភាពបច្ចេកទេស និងសុចរិតភាព ហើយផ្តល់អនុសាសន៍មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលទាំងមូលដើម្បីពិនិត្យ និងអនុម័ត;
- តែងតាំង និងបញ្ចប់ការងាររបស់ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង;
- រាយតម្លៃគុណភាព និងសមត្ថភាពរបស់បុគ្គលិកសវនកម្ម និងធានាថាពួកគេមានបទពិសោធន៍ និងការបណ្តុះបណ្តាលសមស្រប;
- ផ្តួចផ្តើមការសិក្សា ការត្រួតពិនិត្យ ការវាយតម្លៃ ការស្នងមតិ ឬគម្រោងនានា ទាំងផ្ទៃក្នុង និងក្រៅស្ថាប័ន ដែលពាក់ព័ន្ធដោយផ្ទាល់នឹងតួនាទី និងការទទួលខុសត្រូវខាងលើ ដោយលក្ខខណ្ឌថា ការចំណាយដែលកើតឡើងស្ថិតក្នុងក្របខ័ណ្ឌថវិកាដែលបានអនុម័ត ឬទទួលបានការអនុម័តជាក់លាក់ពីក្រុមប្រឹក្សាភិបាល។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងតិចពីរ(០២)ដងក្នុងមួយឆ្នាំ។ លើសពីនេះ ប្រធាន ក្រុមប្រឹក្សាភិបាលអាចកោះហៅប្រជុំតាមករណីចាំបាច់។ អភិបាលម្នាក់ៗ មានឯករាជ្យភាព ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងចៀសវាងការទទួលបានអត្ថប្រយោជន៍ (រួមបញ្ចូលទាំងសំណូក) ពីតតិយភាគីជាដាច់ខាត។

ក្រុមប្រឹក្សាភិបាល មានគណៈកម្មាធិការគាំទ្រចំនួនបួន៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យគណៈកម្មាធិកា រសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ គណៈកម្មាធិការគ្រប់គ្រងទ្រព្យ សកម្ម និងទ្រព្យអកម្ម ដែលត្រូវបានបង្កើតឡើងដើម្បីដើរតួនាទីជំនួយឱ្យក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យប្រតិបត្តិការសេវាធនាគារ។ គណៈកម្មាធិការទាំងនេះ ទទួលខុសចំពោះការតាមដាន និងត្រួតពិនិត្យហានិភ័យ (ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព និង ហានិភ័យប្រតិបត្តិការ) នៅក្នុងធនាគារ។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យមានសមាជិកចំនួនប្រាំរូប។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យពិនិត្យសកម្មភាពគ្រប់គ្រងហានិភ័យដែលធនាគារអាចជួបប្រទះ ដូចជាហានិភ័យហិរញ្ញវត្ថុ ហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យប្រតិបត្តិការហានិភ័យកេរ្តិ៍ឈ្មោះ និង ហានិភ័យផ្នែកច្បាប់ជាដើម
- ត្រួតពិនិត្យជាទៀងទាត់នូវគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យ ដែលបានកំណត់ និង អនុវត្តដោយគណៈគ្រប់គ្រងជាន់ខ្ពស់
- ត្រួតពិនិត្យមើលគុណវុឌ្ឍិ និងជីវប្រវត្តិលម្អិត របស់មន្ត្រីគ្រប់គ្រងហានិភ័យជាន់ខ្ពស់ និងធានាថា និយោជិតនៃនាយកដ្ឋានគ្រប់គ្រងហានិភ័យមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបំពេញការងារ
- ទទួលខុសចំពោះការវាយតម្លៃហានិភ័យក្នុងស្រុក ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍រួមរបស់ធនាគារ។

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម គឺដឹកនាំដោយអភិបាលឯករាជ្យ និងមានចំនួនបីរូប។គណៈកម្មាធិការ សវនកម្ម ត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធគណនេយ្យព្រមទាំងការរៀបចំ និងត្រួតពិនិត្យហិរញ្ញវត្ថុ ប្រកបដោយភាពស្មោះត្រង់
- ត្រួតពិនិត្យប្រសិទ្ធភាពនៃតួនាទីត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធគ្រប់គ្រងហានិភ័យ
- តែងតាំងសវនករផ្ទៃក្នុង និងត្រួតពិនិត្យជាទៀងទាត់លើតួនាទីរបស់សវនកម្មផ្ទៃក្នុង
- ធ្វើសវនកម្មដោយឯករាជ្យប្រចាំឆ្នាំ លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងផ្តល់អនុសាសន៍ដល់ ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការតែងតាំងសវនករឯករាជ្យ ការវាយតម្លៃសមត្ថភាព ឯករាជ្យភាព និងការអនុវត្តរបស់សវនករឯករាជ្យព្រមទាំង ការកំណត់លាភការនិងរយៈពេលសម្រាប់សវនករឯករាជ្យ
- បង្កើត និងអនុវត្តគោលនយោបាយជាមួយសវនករឯករាជ្យពាក់ព័ន្ធនឹងការផ្តល់ សេវាកម្មផ្សេងៗ ក្រៅពីសវនកម្មឯករាជ្យប្រចាំឆ្នាំ និងរាយការណ៍បញ្ហានេះទៅក្រុមប្រឹក្សាភិបាល និង
- ធានាឱ្យបាននូវអនុលោមភាពទៅតាមច្បាប់ និងបទប្បញ្ញត្តិ រួមទាំងនីតិវិធី និងការត្រួតពិនិត្យលើការ បង្ហាញ ព័ត៌មានហិរញ្ញវត្ថុ។

គណៈកម្មាធិការតែងតាំង និងលាភការ

គណៈកម្មាធិការតែងតាំង និងលាភការគឺដឹកនាំដោយអភិបាលឯករាជ្យនិងមានចំនួនប្រាំរូប។គណៈកម្មាធិការតែងតាំង និងលាភការត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

- កំណត់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ គណៈគ្រប់គ្រងជាន់ខ្ពស់ និងនិយោជិតរបស់ធនាគារ
- វាយតម្លៃបទពិសោធន៍ ចំណេះដឹង និងជំនាញរបស់សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ជាន់ខ្ពស់ព្រមទាំងកំណត់ទំនួលខុសត្រូវ របស់សមាជិកក្រុមប្រឹក្សាភិបាល ដែលត្រូវបានតែងតាំង ដើម្បីបំពេញតួនាទីណាមួយ
- វាយតម្លៃការអនុវត្តភារកិច្ចរបស់គណៈកម្មាធិការទាំងអស់ និងដាក់របាយការណ៍ជូនក្រុម ប្រឹក្សាភិបាល
- បង្កើតផែនការ និងយុទ្ធសាស្ត្រលាភការ ព្រមទាំងផ្តល់ផលប្រយោជន៍ជាច្រើនដល់និយោជិត និង ធានាបាននូវការរក្សានិយោជិតដែលមានគុណវុឌ្ឍិ។

គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រងចំនួនពីរ៖ គណៈកម្មាធិការប្រតិបត្តិការ និងគណៈកម្មាធិការឥណទាន គឺត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់នាយកប្រតិបត្តិ ក្នុងការដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារ និងអនុវត្តការងារផ្សេងៗដែលចាត់តាំងដោយនាយកប្រតិបត្តិ និងរាយការណ៍ជូននាយកប្រតិបត្តិ។

គណៈកម្មាធិការប្រតិបត្តិការ

គណៈកម្មាធិការប្រតិបត្តិការមានសមាជិកចំនួនបីរូប។ គណៈកម្មាធិការប្រតិបត្តិការ ទទួលខុសត្រូវ៖
- ធានាការអនុលោមទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារ
- ធានាថា ធនាគារមានផែនការអាជីវកម្ម និងផែនការថវិកាប្រចាំឆ្នាំ
- ត្រួតពិនិត្យការអនុវត្តសកម្មភាពអាជីវកម្មឱ្យបានទៀងទាត់ស្របតាមផែនការអាជីវកម្ម និងផែនការថវិកាដែលបានកំណត់
- ត្រួតពិនិត្យបញ្ហានានា ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ធនាគារ។

គណៈកម្មាធិការឥណទាន

គណៈកម្មាធិការឥណទាន មានសមាជិកសប្រាំមួយរូប។ គណៈកម្មាធិការឥណទាន ទទួលខុសត្រូវ៖
- អនុម័ត និងផ្តល់ឥណទានដល់អតិថិជន
- អនុវត្តការវិភាគសំខាន់ៗនៅក្នុងការផ្តល់ឥណទានដល់អ្នកខ្ចី ដើម្បីកំណត់សមត្ថភាពទូទាត់សងរបស់អតិថិជនដែលអាចកាត់បន្ថយហានិភ័យឥណទានបាន
- ត្រួតពិនិត្យឥណទានឡើងវិញ និងបង្កើតយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីប្រមូលឥណទានមិនដំណើរការ។

ការត្រួតពិនិត្យផ្ទៃក្នុង

ធនាគារ កម្ពុជា អាស៊ី បានបន្តបង្កើតស្រទាប់ការពារជាច្រើននៅក្នុងធនាគារ ដើម្បីធានាថាគ្រប់សកម្មភាព ដំណើរការ ប្រព័ន្ធ គោលនយោបាយ និងនីតិវិធីទាំងអស់ ដំណើការត្រឹមត្រូវដោយមិនមានការបរាជ័យនៃការត្រួតពិនិត្យផ្ទៃក្នុង ទ្រព្យសកម្មត្រូវបានការពារពី ការប្រើប្រាស់មិនត្រឹមត្រូវ ឬការបាត់បង់ និងការក្លែងបន្លំ ហើយទ្រព្យអកម្មត្រូវបានកំណត់ និងគ្រប់គ្រង។

ធនាគារមានគោលនយោបាយ និងនីតិវិធីត្រឹមត្រូវ និងគ្រប់គ្រាន់ពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារសម្រាប់អនុវត្ត។ ដូចគ្នានេះផងដែរ ធនាគារមានការបែងចែកដាច់ពីគ្នា រវាងមុខងារត្រួតពិនិត្យ និងមុខងារអនុវត្ត។

ក្រុមប្រឹក្សាភិបាលមានកិច្ចប្រជុំជាញឹកញាប់ជាមួយគណៈគ្រប់គ្រង មន្ត្រីប្រតិបត្តិតាម និងសវនករផ្ទៃក្នុង ដើម្បីធានាថា គ្រប់គោលនយោបាយ និងនីតិវិធីទាំងអស់ដែលបានអនុម័ត គឺត្រូវបានអនុវត្តតាមយ៉ាងហ្មត់ចត់ ហើយ ហានិភ័យនានាត្រូវបានកំណត់ និងគ្រប់គ្រង។ គណៈកម្មាធិការសវនកម្ម ក៏ទទួលខុសត្រូវចំពោះការជួយក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យលើសុចរិតភាពនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារនិងប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង។ ក្រៅពីនេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងធ្វើការត្រួតពិនិត្យយ៉ាងទៀងទាត់ថាតើគណៈគ្រប់គ្រងបានកំណត់ និងអនុវត្តនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងបានសមស្របឬទេ ដែលរួមមានការត្រួតពិនិត្យលើប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) និងការអនុវត្តតាមអនុសាសន៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករផ្ទៃក្នុង សវនករឯករាជ្យ និងធនាគារជាតិនៃកម្ពុជា។

កំណត់ត្រា និងដំណើរការទាំងអស់របស់ធនាគារត្រូវបានរក្សាទុកត្រឹមត្រូវ ដែលអនុញ្ញាតឱ្យមានលំហូរព័ត៌មានទាន់ពេលវេលា ពាក់ព័ន្ធ និងទុកចិត្តបានពីក្នុង និងក្រៅធនាគារ។ ធនាគារ កម្ពុជាអាស៊ី ក៏មានមុខងារប្រតិបត្តិតាម ដើម្បីធានាបាននូវអនុលោមភាពទៅតាមគោលនយោបាយផ្ទៃក្នុង ច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការប្រកបអាជីវកម្ម។

ការគ្រប់គ្រងហានិភ័យ

ធនាគារ កម្ពុជា អាស៊ី បានកត់សម្គាល់យ៉ាងច្បាស់ថា ការគ្រប់គ្រងហានិភ័យកាន់តែប្រសើរ ជួយឱ្យធនាគារសម្របរសៃអាប់តៃថាយ (risk appetite) និងយុទ្ធសាស្ត្រ កាត់បន្ថយការខាតបង់ពីប្រតិបត្តិការ និងធ្វើឱ្យល្អប្រសើរឡើងនូវការធ្វើសេចក្តីសម្រេចចិត្តឆ្លើយតបទៅនឹងការគ្រប់គ្រងហានិភ័យ។ បន្ទាប់មក ធនាគារបានបន្តបង្កើតក្របខ័ណ្ឌ និងប្រព័ន្ធគ្រប់គ្រងហានិភ័យដែលមានលក្ខណៈប្រសើរ និងអាចទទួលយកបាន។ ធនាគាររួមបញ្ចូលទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ដែលជាស្ថាប័នកំពូលរបស់ធនាគារ។

ធនាគារ កម្ពុជា អាស៊ី បានបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការកម្រិតប្រតិបត្តិបន្ថែមទៀតដូចជា គណៈកម្មាធិការឥណទាន និងគណៈកម្មាធិការប្រតិបត្តិការ សម្រាប់គ្រប់គ្រងហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព និងហានិភ័យប្រតិបត្តិការ។

ការគ្រប់គ្រងហានិភ័យឥណទាន

ធនាគារ កម្ពុជាអាស៊ី បានបង្កើតគោលនយោបាយ និងនីតិវិធីឥណទាន ដើម្បីកាត់បន្ថយហានិភ័យក្នុងការផ្តល់ឥណទានដល់សាធារណជន និងដើម្បីអនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាផងដែរ។ គោលនយោបាយ និងនីតិវិធីទាំងនេះកំណត់បទដ្ឋានសម្រាប់ការគ្រប់គ្រងឥណទាន និងត្រូវបានធ្វើ បច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្នរបស់ធនាគារ។

ការគ្រប់គ្រងហានិភ័យទីផ្សារ

ហានិភ័យទីផ្សារនេះពាក់ព័ន្ធ នឹងហានិភ័យអត្រាការប្រាក់ និងអត្រាប្តូររូបិយប័ណ្ណបរទេស (FX) ដែលធនាគារបានពិភាក្សានៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ដើម្បីតាមដានអត្រាការប្រាក់ និងអត្រាប្តូររូបិយប័ណ្ណ។ កត្តាសំខាន់ក្នុងការគ្រប់គ្រងហានិភ័យទីផ្សារ រួមមាន ទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលងាយរងឥទ្ធិពលពីអត្រាការប្រាក់។ ដោយសារតែធនាគារ កម្ពុជា អាស៊ី គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេមួយក្នុងការប្តូររូបិយប័ណ្ណបរទេស និងផ្ទេរប្រាក់ ធនាគារបានបង្កើតនូវគោលនយោបាយ និងនីតិវិធីដ៏មានប្រសិទ្ធភាពក្នុងការ គ្រប់គ្រងចាត់ចែងត្រួតពិនិត្យ និងតាមដានហានិភ័យអត្រាប្តូរប្រាក់។

ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

សមាជិកគណៈកម្មាធិការប្រតិបត្តិការ គ្រប់គ្រង និងតាមដានសន្ទនីយភាព និងមានគោលបំណងអនុលោម តាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងដើម្បីរក្សាទំនុកចិត្ត និងការជឿជាក់របស់អតិថិជន។ ធនាគារក៏មានផែនការយថាភាពសម្រាប់គ្រប់គ្រងសន្ទនីយភាព ដើម្បីទប់ទល់នឹងការដួល រលំទីផ្សារនៅក្នុងប្រព័ន្ធធនាគារ និងបញ្ហាផ្សេងៗទៀត ដែលនឹងប៉ះពាល់ដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ធនាគារ កម្ពុជា អាស៊ី បានបង្កើតសៀវភៅណែនាំប្រតិបត្តិការសម្រាប់និយោជិត និងអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលមានគោលបំណងកំណត់ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃ ក៏ដូចជាហានិភ័យប្រព័ន្ធនៅក្នុងធនាគារផងដែរ។

ក្រមប្រតិបត្តិ

ដើម្បីរក្សា និងលើកកម្ពស់សីលធម៌វិជ្ជាជីវៈ ទាំងគណៈគ្រប់គ្រង និងនិយោជិត គឺត្រូវបានតម្រូវឱ្យបំពេញការងាររបស់ខ្លួនប្រកបដោយការយកចិត្តទុកដាក់ ភាពស្មោះត្រង់ តម្លាភាព និងសំខាន់បំផុតនោះគឺការចាត់ទុកការងាររបស់ធនាគារជាការងារអាទិភាព។ គណៈគ្រប់គ្រង និងនិយោជិតបានទទួលស្គាល់ និងអនុវត្តតាមក្រមសីលធម៌របស់ធនាគារ កម្ពុជា អាស៊ី ដែលមានដូចខាងក្រោម៖

- ផ្តល់សេវាកម្មជូនអតិថិជនប្រកបដោយភាពយុត្តិធម៌ ស្មោះត្រង់ មិនលំអៀង និងមិនអនុញ្ញាតឱ្យ ទទួលអំណោយ កម្រៃជើងសារ ឬវត្ថុមានតម្លៃ ណាមួយពីអតិថិជនឡើយ ដោយសារតែអំណោយ ឬការកម្សាន្តអាចជាការគម្រាមកំហែងដល់ចិត្តដែលមានឯករាជ្យភាព។
- បុគ្គលិកមិនត្រូវចូលរួមក្នុងសកម្មភាពអាជីវកម្មណាមួយដែលមានទំនាស់ផលប្រយោជន៍ ជាមួយធនាគារឡើយ។
- បុគ្គលិកមិនត្រូវប្រើមុខតំណែងរបស់ខ្លួននៅក្នុងធនាគារ សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។
- បុគ្គលិកមិនត្រូវប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជន ដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនទេ។

អនុលោមភាព

នាយកដ្ឋានប្រតិបត្តិតាមរបស់ធនាគារដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា ធនាគារ កម្ពុជា អាស៊ី ដំណើរ ការដោយអនុលោមតាមច្បាប់ បទបញ្ជា និងស្តង់ដារអាជីវកម្មដែលពាក់ព័ន្ធទាំងអស់។


នាយកដ្ឋានប្រតិបត្តិតាមនៅ ធនាគារ កម្ពុជាអាស៊ី ទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍អនុវត្ត និងត្រួតពិនិត្យ កម្មវិធី អនុលោមភាពរបស់ធនាគារ។ នេះរួមបញ្ចូលទាំងការធានាថាធនាគារអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដារអាជីវកម្មដែលពាក់ព័ន្ធទាំងអស់ដែលទាក់ទងនឹងការប្រឆាំងការការសម្អាតប្រាក់ (AML) ហិរញ្ញប្បទានភេរវកម្ម (CFT) ការដាក់ទណ្ឌកម្ម និងផ្នែកពាក់ព័ន្ធផ្សេងទៀត។ នាយកដ្ឋានក៏ផ្តល់ការណែនាំ និងការបណ្តុះបណ្តាលដល់ បុគ្គលិកលើបញ្ហាដែលទាក់ទងនឹងការអនុលោមតាមនិងសហការជាមួយនាយក ដ្ឋានផ្សេងទៀតដើម្បីធានាថ ហានិភ័យនៃការអនុលោមតាមត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

ក្នុងឆ្នាំកន្លងទៅ នាយកដ្ឋានប្រតិបត្តិតាមបានបោះជំហានយ៉ាងសំខាន់ក្នុងការពង្រឹងកម្មវិធី អនុលោមភាពរបស់ធនាគារ។

សមិទ្ធិផលសំខាន់ៗមួយចំនួនរួមមាន៖

- ការពង្រឹងក្របខ័ណ្ឌ AML/CFT របស់ធនាគារ៖ នាយកដ្ឋានបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធី AML/CFT របស់ធនាគារ ដើម្បីធានាថាគោលនយោបាយ និងនីតិវិធីទាំងនោះស្របតាមតម្រូវការបច្ចុប្បន្នភាពនៃបទប្បញ្ញត្តិ និងឧត្តមានុវត្តនៅក្នុងអាជីវកម្ម។
- ការអនុវត្តកម្មវិធីអនុលោមតាមការហាមឃាត់៖ នាយកដ្ឋានបានបង្កើត និងអនុវត្តកម្មវិធីអនុលោមតាមការហាមឃាត់ ដើម្បីធានាថាធនាគារអនុលោមតាមបទប្បញ្ញត្តិហាមឃាត់ពាក់ព័ន្ធទាំងអស់។
- ការផ្តល់កម្មវិធីបណ្តុះបណ្តាល និងការយល់ដឹង៖ នាយកដ្ឋានបានរៀបចំកម្មវិធីបណ្តុះបណ្តាល និង ផ្តល់ការយល់ដឹងផ្សេងៗ សម្រាប់បុគ្គលិកលើបញ្ហាដែលទាក់ទងនឹងការអនុលោមតាម រួមទាំង AML/CFT ការហាមឃាត់ និងរក្សាទិន្នន័យឯកជនភាព។
- សហការជាមួយនាយកដ្ឋានផ្សេងទៀត៖ នាយកដ្ឋានបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋាន ផ្សេងទៀតដូចជានាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីធានាថា ហានិភ័យនៃការអនុលោមតាមច្បាប់ត្រូវ បានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។
- ការចូលរួមជាមួយអាជ្ញាធរពាក់ព័ន្ធផ្សេងៗ៖ នាយកដ្ឋានបានរក្សាទំនាក់ទំនងយ៉ាងរឹងមាំជាមួយអាជ្ញាធរពាក់ព័ន្ធផ្សេងៗ និងបានចូលរួមយ៉ាងសកម្មជាមួយពួកគេលើបញ្ហាដែលទាក់ទង នឹងការ អនុលោមភាព។

តារាងរចនាសម្ព័ន្ធធនាគារ



ការអភិវឌ្ឍបុគ្គលិក និងការកសាងសមត្ថភាព

ក្នុងអំឡុងឆ្នាំ ២០២៥ ធនាគារ កម្ពុជា អាស៊ី បានអនុវត្តកម្មវិធីបណ្តុះបណ្តាលផ្នែកក្នុងយ៉ាងទូលំទូលាយ ដែលគ្របដណ្តប់លើប្រធានបទជាង ២០ ផ្នែក ដោយផ្តោតលើវិស័យសំខាន់ៗ រួមមាន ការអនុលោមតាមបទប្បញ្ញត្តិ ការគ្រប់គ្រងហានិភ័យ ប្រតិបត្តិការឥណទាន ប្រសិទ្ធភាពការលក់ សន្តិសុខបច្ចេកវិទ្យាព័ត៌មាន គោលនយោបាយធនធានមនុស្ស និងប្រតិបត្តិការសាខា។ វគ្គបណ្តុះបណ្តាលទាំងនេះត្រូវបានរៀបចំឡើងដោយផ្អែកលើភាពជាក់ស្តែង និងតម្រូវការរបស់ក្រុមបុគ្គលិកគោលដៅ ដូចជា ក្រុមការងារសាខា មន្ត្រីឥណទាន បេឡាករ អ្នកគ្រប់គ្រង និងបុគ្គលិកទាំងអស់ ដើម្បីធានាថាការរៀនសូត្រមានប្រសិទ្ធភាព និងសម្រេចបានគោលបំណងច្បាស់លាស់។

ការបណ្តុះបណ្តាលផ្នែកអនុលោមភាពតាមបទប្បញ្ញត្តិ

សាខា និងការិយាល័យទាំងអស់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពត្រឹមត្រូវនៃទិន្នន័យ ការយល់ដឹងអំពីហានិភ័យនៃការក្លែងបន្លំ និងការរាយការណ៍ប្រតិបត្តិការគួរឱ្យសង្ស័យ (STR) ដើម្បីពង្រឹងគោលជំហរមិនអត់ឱនចំពោះការប្រព្រឹត្តខុសផ្នែកហិរញ្ញវត្ថុ។ បុគ្គលិកក៏បានទទួលការបណ្តុះបណ្តាលជាក់លាក់លើការប្រឆាំងការសម្អាតប្រាក់ (AML) ការទប់ស្កាត់ការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម (CFT) ការទប់ស្កាត់ការផ្តល់ហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ (CPF) និងការរាយការណ៍អំពីសកម្មភាពមិនត្រឹមត្រូវ (Whistleblowing) ដើម្បីធានាថាបុគ្គលិកមានការប្រុងប្រយ័ត្ន និងត្រៀមខ្លួនបានល្អក្នុងបរិបទបទប្បញ្ញត្តិដែលកំពុងវិវត្ត។

មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហានិភ័យ

ធនាគារបានផ្តល់វគ្គណែនាំអំពីការគ្រប់គ្រងហានិភ័យដល់បុគ្គលិកសាខា និងការិយាល័យ រួមទាំងមន្ត្រីឥណទាន អ្នកគ្រប់គ្រង និងអនុប្រធានសាខា ដោយមានការគាំទ្រពីវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ស្តីពីការស្គាល់អតិថិជន ដែលរួមមានការត្រួតពិនិត្យអតិថិជន) ការត្រួតពិនិត្យបន្ថែម និងតម្រូវការស្តីពីម្ចាស់ផលប្រយោជន៍ចុងក្រោយ។

ប្រតិបត្តិការឥណទាន និងចំណេះដឹងផ្នែកច្បាប់

បុគ្គលិកផ្នែកស្តារឥណទាន និងផ្នែកលក់បានទទួលការបណ្តុះបណ្តាលអំពីច្បាប់កិច្ចសន្យា កិច្ចព្រមព្រៀងបញ្ចាំ និងនីតិវិធីតុលាការ ដើម្បីពង្រឹងមូលដ្ឋានសម្រាប់ការផ្តល់ឥណទានប្រកបដោយទំនួលខុសត្រូវ និងការគ្រប់គ្រងឥណទានប្រកបដោយប្រសិទ្ធភាព។ វគ្គសិក្សាអំពីគោលនយោបាយឥណទាន និងសៀវភៅណែនាំប្រតិបត្តិការឥណទានក៏បានជួយធានាថាក្រុមការងារឥណទានអនុវត្តការងារដោយមានភាពច្បាស់លាស់ ស៊ីសង្វាក់ និងវិចារណញ្ញាណល្អ។

ជំនាញលក់ និងឧត្តមភាពក្នុងការបម្រើអតិថិជន

បុគ្គលិកផ្នែកលក់ទាំងផ្នែកប្រាក់បញ្ញើ និងឥណទាន បានចូលរួមវគ្គបណ្តុះបណ្តាលអំពីជំនាញលក់ ទំនាក់ទំនងជាមួយអតិថិជន និងការយល់ដឹងអំពីប្រភេទអតិថិជនផ្សេងៗ។ សិក្ខាសាលាស្តីពីធនាគារសាជីវកម្ម និងការរំលឹកគោលនយោបាយប្រាក់បញ្ញើ បានជួយឱ្យបុគ្គលិកជួរមុខអាចផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ជូនអតិថិជនបានប្រកបដោយវិជ្ជាជីវៈ។

ការដោះស្រាយបញ្ហា និងការលើកទឹកចិត្ត

ដោយទទួលស្គាល់ថាជំនាញបច្ចេកទេសតែមួយមុខមិនគ្រប់គ្រាន់ ធនាគារ កម្ពុជា អាស៊ី បានវិនិយោគលើការអភិវឌ្ឍផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់បុគ្គលិកផ្នែកលក់ តាមរយៈការបណ្តុះបណ្តាលអំពីវិធីសាស្ត្រដោះស្រាយបញ្ហា និងការកសាងផ្នត់គំនិតវិជ្ជមាន ដើម្បីជួយឱ្យក្រុមការងាររក្សាបាននូវភាពធន់ សកម្មភាព និងការផ្តោតលើដំណោះស្រាយក្នុងបរិយាកាសប្រកួតប្រជែង។

ប្រតិបត្តិការ បច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធធនធានមនុស្ស

បុគ្គលិកប្រតិបត្តិការ រួមមាន បេឡាករ មន្ត្រីបម្រើអតិថិជន និងអនុប្រធានសាខា បានចូលរួមវគ្គរំលឹកអំពីលក្ខខណ្ឌសេវាកម្ម នីតិវិធីបើកគណនី និងគោលនយោបាយ និងសេចក្តីណែនាំផ្ទៃក្នុងថ្មីៗ ដើម្បីរក្សាបាននូវភាពត្រឹមត្រូវនៃប្រតិបត្តិការ និងគុណភាពសេវាកម្ម។

បុគ្គលិកទាំងអស់បានបញ្ចប់ការបណ្តុះបណ្តាលផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ដើម្បីពង្រឹងការយល់ដឹងអំពីហានិភ័យសន្តិសុខសាយប័រ និងលើកកម្ពស់ការអនុវត្តឌីជីថលប្រកបដោយសុវត្ថិភាពទូទាំងស្ថាប័ន។

នាយកដ្ឋានធនធានមនុស្សបានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើនស្តីពីគោលនយោបាយ និងនីតិវិធីធនធានមនុស្ស ប្រព័ន្ធចុះវត្តមានបញ្ជាប្រាក់បៀវត្សរ៍ ការធ្វើបច្ចុប្បន្នភាពទិន្នន័យផ្ទាល់ខ្លួន និងការរៀបចំវេនការងារ។

ការបណ្តុះបណ្តាលអំពីការសម្គាល់ក្រដាសប្រាក់ពិត

នាយកដ្ឋានរតនាគារបានផ្តល់ការបណ្តុះបណ្តាលដល់បេឡាករទាំងអស់ អំពីការសម្គាល់ក្រដាសប្រាក់ពិត ដើម្បីបំពាក់ជំនាញដល់បុគ្គលិកជួរមុខក្នុងការរកឃើញ និងទប់ស្កាត់ក្រដាសប្រាក់ក្លែងក្លាយ ការពារទាំងអតិថិជន និងសុចរិតភាពនៃប្រតិបត្តិការរបស់ធនាគារ។

ទំនួលខុសត្រូវសង្គម

នៅធនាគារ កម្ពុជា អាស៊ី ទំនួលខុសត្រូវសង្គមមិនមែនគ្រាន់តែជាកម្មវិធីមួយនោះទេ ប៉ុន្តែជាគោលការណ៍ដ៏សំខាន់មួយក្នុងការប្រតិបត្តិអាជីវកម្ម។ ដោយផ្អែកលើតម្លៃស្នូលរបស់យើងរួមមាន សុចរិតភាព សហគមន៍ និងវឌ្ឍនភាពរួម យើងបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះសុខុមាលភាពរបស់ប្រជាជនដែលយើងបម្រើ និងសង្គមដែលយើងជាផ្នែកមួយ។ ក្នុងអំឡុងឆ្នាំ ២០២៥ ក្រុមការងាររបស់យើងបានចូលរួមក្នុងសកម្មភាពជាច្រើន ដែលគ្របដណ្តប់លើវិស័យសុខាភិបាល ការអប់រំ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការគាំទ្រវប្បធម៌ និងការផ្តល់ជំនួយមនុស្សធម៌ ដែលសកម្មភាពនីមួយៗបានឆ្លុះបញ្ចាំងពីជំនឿដ៏មុតមាំរបស់យើងថាតួនាទីរបស់ធនាគារលាតសន្ធឹងហួសពីតុល្យការហិរញ្ញវត្ថុទៅទៀត។

ថ្ងៃទី ៧ ខែមីនា ឆ្នាំ ២០២៥
ការបរិច្ចាគឈាម



ធនាគារ កម្ពុជា អាស៊ី បានចូលរួមក្នុងកម្មវិធីបរិច្ចាគឈាមដែលសហការរៀបចំដោយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាដោយប្រមូលផ្តុំបុគ្គលិកពីស្ថាប័នហិរញ្ញវត្ថុនានាឱ្យចូលរួមក្នុងសកម្មភាពមនុស្សធម៌ប្រកបដោយសុច្ឆន្ទៈ។ ការចូលរួមនេះបានបង្ហាញថានៅពេលស្ថាប័ននានារួមគ្នាដើម្បីបុព្វហេតុមនុស្សធម៌រួមផលប៉ះពាល់វិជ្ជមានអាចកើនឡើងយ៉ាងច្រើន។ ការចូលរួមរបស់យើងឆ្លុះបញ្ចាំងពីជំនឿថា ទំនួលខុសត្រូវសង្គមមានអត្ថន័យខ្លាំងបំផុតដើម្បីប្រយោជន៍រួមរបស់សង្គម។



ថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០២៥
គាំទ្រកីឡាសហគមន៍

ឧបត្ថម្ភការប្រកួតបាល់ទះ Volleyball League 2025ធនាគារ កម្ពុជា អាស៊ី មានមោទនភាពក្នុងការឧបត្ថម្ភការប្រកួតបាល់ទះ One-Day Volleyball League 2025 ដែលរៀបចំឡើងដោយសហគមន៍ហ្វីលីពីននៅកម្ពុជា។ ព្រឹត្តិការណ៍កីឡាដ៏រស់រវើកនេះបានប្រមូលផ្តុំកីឡាករ និងអ្នកគាំទ្រពីមជ្ឈដ្ឋានផ្សេងៗគ្នា ដើម្បីអបអរសាទរស្មារតីក្រុម មិត្តភាព និងសាមគ្គីភាពក្នុងសហគមន៍។ ការឧបត្ថម្ភនេះបានបង្ហាញពីជំនឿរបស់យើងថា សហគមន៍រឹងមាំមិនត្រឹមតែកើតចេញពីវឌ្ឍនភាពសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកើតចេញពីបទពិសោធន៍រួម និងការផ្លាស់ប្តូរវប្បធម៌ផងដែរ។

ថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០២៥
កម្មវិធីលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិបាត់ដំបងជាផ្នែកមួយនៃការប្តេជ្ញាចិត្តជាបន្តបន្ទាប់ក្នុងការលើកកម្ពស់សមត្ថភាពរបស់យុវជនជំនាន់ក្រោយ ធនាគារ កម្ពុជា អាស៊ី បានរៀបចំស្តង់ផ្សព្វផ្សាយនៅសាកលវិទ្យាល័យជាតិបាត់ដំបង។ ក្រុមការងាររបស់យើងបានជួបប្រាស្រ័យដោយផ្ទាល់ជាមួយនិស្សិតដោយ ផ្តល់សេវាបើកគណនី និងចែករំលែកចំណេះដឹងលើប្រធានបទហិរញ្ញវត្ថុសំខាន់ៗ។ តាមរយៈការសន្ទនាបើកចំហ និងការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល និស្សិតមានឱកាសសាកសួរ និងទទួលបានចំណេះដឹងជាក់ស្តែងអំពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន ដែលជាជំហានដ៏មានន័យក្នុងការកសាងសហគមន៍ដែលមានចំណេះដឹងផ្នែកហិរញ្ញវត្ថុកាន់តែប្រសើរ។



ថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២៥
កម្មវិធីផ្សព្វផ្សាយនៅសាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង

ធនាគារ កម្ពុជា អាស៊ី បានពង្រីកវត្តមានរបស់ខ្លួនទៅកាន់សាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង។ និស្សិតអាចបើកគណនីនៅនឹងកន្លែងបានយ៉ាងងាយស្រួល និងចូលរួមពិភាក្សាអំពីសេវាធនាគារ និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ក្រុមការងាររបស់យើងបានឆ្លើយសំណួរ និងពន្យល់អំពីគោលគំនិតហិរញ្ញវត្ថុសំខាន់ៗ ដោយបន្តពង្រឹងការប្តេជ្ញាចិត្តក្នុងការកសាងទំនុកចិត្តផ្នែកហិរញ្ញវត្ថុក្នុងចំណោមយុវជនកម្ពុជា។





ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០២៥
ចូលរួមពិព័រណ៍ការងារជាមួយសាកលវិទ្យាល័យ De Montfort

ធនាគារ កម្ពុជា អាស៊ី បានចូលរួមក្នុងពិព័រណ៍ការងារដែលរៀបចំឡើងដោយសាកលវិទ្យាល័យ De Montfort ក្នុងគោលបំណងភ្ជាប់និស្សិតដែលត្រៀមបញ្ចប់ការសិក្សាជាមួយឱកាសការងារប្រកបដោយអត្ថន័យ។ ការចូលរួមនេះបានបញ្ជាក់ពីតួនាទីរបស់យើងមិនត្រឹមតែជាស្ថាប័នហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាអ្នករួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍកម្លាំងពលកម្មរបស់កម្ពុជាផងដែរ។

ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២៥
ចូលរួមយុទ្ធនាការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក របស់ធនាគារជាតិនៃ កម្ពុជា

ធនាគារ កម្ពុជា អាស៊ី មានកិត្តិយសក្នុងការចូលរួមយុទ្ធនាការដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា នៅវត្តនរា ខេត្តបាត់ដំបង។ កម្មវិធីនេះបានផ្តល់ឱកាសដល់សាធារណជនក្នុងការប្តូរក្រដាសប្រាក់រៀលចាស់ ឬខូចដោយមិនគិតថ្លៃ ដោយទឹកប្រាក់ដែលបានប្តូរត្រូវបានបញ្ចូលដោយផ្ទាល់ទៅក្នុងគណនីធនាគារ កម្ពុជា អាស៊ី របស់អតិថិជន។ ការចូលរួមនេះបានបង្ហាញពីការប្តេជ្ញាចិត្តរួមក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការផ្តល់សេវាធនាគារដែលអាចប្រជាពលរដ្ឋកម្ពុជាទាំងអស់អាចប្រើប្រាស់បាន។



ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២៥
កម្មវិធីបរិច្ចាគឈាមរបស់បុគ្គលិកនៅមជ្ឈមណ្ឌលជាតិផ្តល់ឈាម



ដោយឈរលើស្មារតីមេត្តាធម៌ និងទំនួលខុសត្រូវចំពោះសង្គម ធនាគារ កម្ពុជា អាស៊ី បានរៀបចំសកម្មភាពបរិច្ចាគឈាមសម្រាប់បុគ្គលិកនៅមជ្ឈមណ្ឌលជាតិផ្តល់ឈាម។ បុគ្គលិកបានស្ម័គ្រចិត្តចំណាយពេលវេលា និងចូលរួមបរិច្ចាគឈាមដោយសប្បុរស ដើម្បីគាំទ្រដល់អ្នកជំងឺដែលត្រូវការឈាមនៅទូទាំងប្រទេស។ សកម្មភាពនេះបានឆ្លុះបញ្ចាំងពីតម្លៃដែលត្រូវបានបណ្តុះបណ្តាលនៅទូទាំងស្ថាប័នថា ការចូលរួមចំណែកដល់សង្គមមិនត្រឹមតែជាការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការបង្ហាញពីក្តីមេត្តា ការយកចិត្តទុកដាក់ និងសាមគ្គីភាពរវាងមនុស្សផងដែរ។



ថ្ងៃទី ១ ខែសីហា ឆ្នាំ ២០២៥
ការលើកលែងបំណុលជូនយោធិនដែលបានពលីជីវិត

ដោយសេចក្តីគោរពដ៏ជ្រាលជ្រៅចំពោះឯកភាពជាតិ និងចំណងសាមគ្គីភាពដែលភ្ជាប់ប្រជាជនកម្ពុជាទាំងអស់ជាមួយគ្នា ធនាគារ កម្ពុជា អាស៊ី បានប្រកាសជាផ្លូវការនូវការលើកលែងកាតព្វកិច្ចសងបំណុលដែលនៅសេសសល់ទាំងអស់ សម្រាប់យោធិនដែលបានបូជាជីវិតក្នុងអំឡុងពេលជម្លោះតាមព្រំដែនកម្ពុជា–ថៃ។ ការសម្រេចចិត្តនេះត្រូវបានធ្វើឡើងក្នុងន័យជាការគោរព និងរំឭកដល់វីរភាពរបស់អ្នកដែលបានបំពេញកាតព្វកិច្ចបម្រើជាតិដោយកិត្តិយស។ ធនាគារយើងខ្ញុំឈររួមជាមួយក្រុមគ្រួសាររបស់ពួកគេក្នុងគ្រាដ៏សោកសៅនេះ និងបន្តប្តេជ្ញាចិត្តក្នុងការគាំទ្រសហគមន៍ដែលបានចូលរួមការពារអធិបតេយ្យភាព និងសន្តិភាពរបស់ព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២៥
ការឧបត្ថម្ភកម្រិតប្រាក់សម្រាប់ពិព័រណ៍ការងារ ឆ្នាំ ២០២៥



នាមជាអ្នកឧបត្ថម្ភកម្រិតប្រាក់ (Silver Sponsor) នៃពិព័រណ៍ការងារ ឆ្នាំ ២០២៥ ធនាគារ កម្ពុជា អាស៊ី បានបន្តបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការលើកកម្ពស់ និងអភិវឌ្ឍធនធានមនុស្ស ព្រមទាំងពង្រីកឱកាសការងារសម្រាប់កម្លាំងពលកម្មនៅកម្ពុជា។ ព្រឹត្តិការណ៍នេះបានដើរតួនាទីជារេទិកាដ៏សំខាន់មួយក្នុងការភ្ជាប់អ្នកស្វែងរកការងារជាមួយនិយោជកដែលមានសក្តានុពល ហើយការចូលរួមរបស់យើងបានផ្តល់ឱកាសដល់អ្នកចូលរួមក្នុងការស្វែងយល់អំពីឱកាសអាជីពដ៏ទូលំទូលាយនៅក្នុងវិស័យធនាគារ។ យើងជឿជាក់ថា ការវិនិយោគលើមនុស្សគឺជាការរួមចំណែកដ៏មានអត្ថន័យ និងឥទ្ធិពលបំផុតមួយ ដែលស្ថាប័នហិរញ្ញវត្ថុអាចផ្តល់ជូនសម្រាប់ការអភិវឌ្ឍជាតិប្រកបដោយចីរភាពក្នុងរយៈពេលវែង។

របាយការណ៍ក្រុមប្រឹក្សាភិបាល

មាតិការបាយការណ៍ក្រុមប្រឹក្សាភិបាល

- របាយការណ៍ហិរញ្ញវត្ថុ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលលម្អិត
- របាយការណ៍បម្រែបម្រួលមូលធន
- របាយការណ៍លំហូរសាច់ប្រាក់
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍សវនករឯករាជ្យ

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួនដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ ធនាគារ កម្ពុជា អាស៊ី ចំកាត់ (ហៅកាត់ថា “ធនាគារ”) សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025។

សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគាររួមមានការធ្វើប្រតិបត្តិការជាអាជីវកម្មធនាគារ និងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ពុំមានការផ្លាស់ប្តូរជាសារវន្តនៃសកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ ក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

លទ្ធផលហិរញ្ញវត្ថុ

ខាតសម្រាប់ការិយបរិច្ឆេទ	2025	
	ដុល្លារអាមេរិក	៣ន់រៀល
	2,637,336	10,578,355

ភាគលាភ

ពុំមានការប្រកាសភាគលាភ ហើយក្រុមប្រឹក្សាភិបាលពុំបានណែនាំឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2025 នេះទេ។

ដើមទុន

ព័ត៌មានលម្អិតនៃដើមទុន និងរចនាសម្ព័ន្ធភាគទុនិកត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 16 នៃរបាយការណ៍ហិរញ្ញវត្ថុ។

ទុនបម្រុង និងសំវិធានធន

ការផ្ទេរទៅ ឬមកពីទុនបម្រុង និងសំវិធានធនក្នុងការិយបរិច្ឆេទត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 17 នៃរបាយការណ៍ហិរញ្ញវត្ថុ។

បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលនៃបំណុលពិបាកទារ និងការធ្វើសំវិធានធនលើបំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់បំណុលពិបាកទារត្រូវបានលុបចោល ហើយបានធ្វើសំវិធានធនគ្រប់គ្រាន់លើបំណុលជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចនឹងបណ្តាលឱ្យតម្លៃនៃបំណុលពិបាកទារដែលបានលុបចោល ឬតម្លៃនៃសំវិធានធនលើបំណុលជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានភាពមិនគ្រប់គ្រាន់ជាសារវន្តឡើយ ។

ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មដែលប្រហែលជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតារួមទាំងតម្លៃដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយមកត្រឹមតម្លៃដែលរំពឹងថានឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចនឹងបណ្តាលឱ្យតម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានភាពមិនត្រឹមត្រូវឡើយ។

វិធីសាស្ត្រក្នុងការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើត ដែលអាចនឹងបណ្តាលឱ្យការអនុវត្តវិធីសាស្ត្របច្ចុប្បន្នក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលរបស់ធនាគារមានភាពមិនត្រឹមត្រូវ ឬមិនសមស្របឡើយ។

បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(1) ការដាក់បន្ទុកលើទ្រព្យសកម្មណាមួយរបស់ធនាគារ ដែលកើតមានឡើងចាប់តាំងពីចុងការិយបរិច្ឆេទដើម្បីធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ និង

(2) បំណុលយថាហេតុណាមួយចំពោះធនាគារ ដែលកើតមានឡើងចាប់តាំងពីចុងការិយបរិច្ឆេទ ក្រៅពីដំណើរការធម្មតា នៃអាជីវកម្មធនាគារឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារដែលត្រូវទាមទារឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេលដប់ពីរខែ បន្ទាប់ពីចុងការិយបរិច្ឆេទដែលនឹង ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការទូទាត់បំណុលរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ។

ការផ្លាស់ប្តូរនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ លុះត្រាតែបានបង្ហាញនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលឱ្យតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវឡើយ។

ប្រតិបត្តិការជាសារវន្ត និងមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល៖

(1) លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ក្នុងការិយបរិច្ឆេទនេះមិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ និង

(2) ពុំមានកត្តា ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីបានកើតឡើងនោះទេក្នុងចន្លោះពេលរវាងចុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះត្រូវបានរៀបចំឡើងទេ។

ការបោះផ្សាយភាគហ៊ុន និងប័ណ្ណបំណុល

នៅក្នុងអំឡុងការិយបរិច្ឆេទនេះ ពុំមានការបោះផ្សាយភាគហ៊ុន និងប័ណ្ណបំណុលថ្មីដោយធនាគារនោះទេ។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងអំឡុងការិយបរិច្ឆេទ និងអំឡុងពេលចាប់ពីចុងការិយបរិច្ឆេទដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

លោក វ៉ា ដាឡុត	ប្រធានក្រុមប្រឹក្សាភិបាល
លោក Wong Tow Fock	អភិបាល និងប្រធាននាយកប្រតិបត្តិ
លោក តុប រ័ត្នធានិន	អភិបាល
លោក Chan Peng Leong	អភិបាលឯករាជ្យ
លោក Rouer Jerome	អភិបាលឯករាជ្យ

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ចាប់តាំងពីចុងការិយបរិច្ឆេទមុន ពុំមានក្រុមប្រឹក្សាភិបាលរបស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈ ការចុះកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬក្រុមហ៊ុនសាជីវកម្មពាក់ព័ន្ធណាមួយជាមួយក្រុមប្រឹក្សាភិបាល ឬក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ធ្វើឡើងជាមួយធនាគារណាមួយ ដែលអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអត្ថប្រយោជន៍ដែលចាត់ទុកថាបានកើតឡើងដោយគុណធម៌ នៃប្រតិបត្តិការដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ 25 នៃរបាយការណ៍ហិរញ្ញវត្ថុ។

ទាំងនៅក្នុងអំឡុងពេល ឬនៅចុងបញ្ចប់នៃការិយបរិច្ឆេទ គឺធនាគារមិនដែលជាភាគីនៃការរៀបចំក្នុងគោលបំណងដើម្បីអនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលទទួលបានអត្ថប្រយោជន៍តាមរយៈនៃការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬ ក្រុមហ៊ុនសាជីវកម្មផ្សេងទៀតទេ។

ក្រុមហ៊ុនមេ

ក្រុមប្រឹក្សាភិបាលបានចាត់ទុកក្រុមហ៊ុន Selvione Limited ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅ British Virgin Islands និងក្រុមហ៊ុន Quantum Symbol Sdn Bhd ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងប្រទេសម៉ាឡេស៊ីជាក្រុមហ៊ុនមេកាន់កាប់ចុងក្រោយ និងក្រុមហ៊ុនមេកាន់កាប់ដោយផ្ទាល់។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ព័ត៌មានលម្អិតនៃក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 9 នៃរបាយការណ៍ហិរញ្ញវត្ថុ។ ពុំមានការធ្វើសវនកម្មលើគណនីរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះទេ ដោយសារក្រុមហ៊ុនបុត្រសម្ព័ន្ធក្លាយជាក្រុមហ៊ុនអសកម្ម។

ព្រឹត្តិការណ៍សំខាន់បន្ទាប់ពីចុងការិយបរិច្ឆេទ

ព័ត៌មានលម្អិតនៃព្រឹត្តិការណ៍សំខាន់បន្ទាប់ពីចុងការិយបរិច្ឆេទត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 30 នៃរបាយការណ៍ហិរញ្ញវត្ថុ។

ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ធនាគារ មានភារៈទទួលខុសត្រូវលើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារចាំបាច់ត្រូវ៖

(1) អនុវត្តគោលការណ៍គណនេយ្យសមស្រប ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា “ស.រ.ទ.ហ.អ.ក”) ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនោះឱ្យមានសង្គតភាព។

(2) អនុលោមតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានតាម ស.រ.ទ.ហ.អ.ក ហើយប្រសិនបើមានការប្រាសចាកណាមួយ ពីស្តង់ដាទាំងនេះ ក្នុងការបង្ហាញនូវភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបាន បង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(3) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីធនាគារអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនស្របតាម ស.រ.ទ.ហ.អ.ក និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព។

(4) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម លុះត្រាតែវាមានភាពមិនត្រឹមត្រូវក្នុងការ សន្មតថាធនាគារនឹងបន្តប្រតិបត្តិការរបស់ខ្លួននាពេលអនាគត និង

(5) គ្រប់គ្រង និងដឹកនាំធនាគារឱ្យមានប្រសិទ្ធិភាព ហើយចូលរួមក្នុងការសម្រេចចិត្តជាសារវន្តទាំងអស់ដែលអាចប៉ះពាល់ ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ធនាគារ ហើយត្រូវប្រាកដថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្ត ទាំងអស់ដោយអនុលោមទៅតាមស.រ.ទ.ហ.អ.ក។

ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាល

Wong Tow Fock
អភិបាល និងប្រធាននាយកប្រតិបត្តិ

តុប រ័ត្នធានិន
អភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 30 MAR 2026

		2025		2024	
	កំណត់សម្គាល់	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក (ដូចបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់ 31)	៣ន់រៀល (ដូចបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់ 31)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	5	59,372,297	238,261,028	64,272,873	258,698,314
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	6	61,263,740	245,851,389	75,545,735	304,071,583
សមតុល្យនៅធនាគារជាតិ ("NBC")	7	10,752,018	43,147,848	9,011,057	36,269,504
តណាទានផ្តល់ដល់អតិថិជន - សុទ្ធ	8	77,224,571	309,902,203	80,732,706	324,949,142
ការវិនិយោគ	9	4,557,090	18,287,602	1,524,714	6,136,974
ទ្រព្យសកម្មផ្សេងៗ	10	2,625,275	10,535,229	3,991,510	16,065,828
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	11	21,297,413	85,466,518	19,648,772	79,086,307
ទ្រព្យសកម្មអរូបី	12	1,949,011	7,821,381	1,968,636	7,923,760
ទ្រព្យសម្បត្តិ និងបរិក្ខារ	13	597,515	2,397,828	723,152	2,910,687
សិទ្ធប្រើប្រាស់លើទ្រព្យសកម្ម		860,950	3,454,992	626,106	2,520,077
ទ្រព្យសកម្មសរុប		**240,499,880**	**965,126,018**	**258,045,261**	**1,038,632,176**
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើពីអតិថិជន	14	155,633,362	624,556,682	170,147,965	684,845,559
បំណុលផ្សេងៗ		609,492	2,445,892	1,242,986	5,003,019
បំណុលភតិសន្យា		900,586	3,614,052	660,534	2,658,649
បំណុលពន្ធពន្យារ - សុទ្ធ	15(ខ)	372,374	1,494,337	372,374	1,498,805
បំណុលសរុប		**157,515,814**	**632,110,963**	**172,423,859**	**694,006,032**
មូលធន					
ដើមទុន	16	75,000,000	299,625,000	75,000,000	299,625,000
ទុនបម្រុងតាមបទប្បញ្ញត្តិ	17	5,635,412	22,614,908	4,593,088	18,487,179
ចំណេញរក្សាទុក		2,348,654	9,754,567	6,028,314	24,513,684
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	1,020,580	-	2,000,281
មូលធនសរុប		**82,984,066**	**333,015,055**	**85,621,402**	**344,626,144**
បំណុល និងមូលធនសរុប		**240,499,880**	**965,126,018**	**258,045,261**	**1,038,632,176**

កំណត់សម្គាល់ដែលមានភ្ជាប់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

		2025		2024	
	កំណត់សម្គាល់	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ចំណូលការប្រាក់	18	11,794,786	47,308,887	10,844,629	44,148,485
ចំណាយការប្រាក់	19	(9,264,435)	(37,159,649)	(8,204,424)	(33,400,210)
ចំណូលការប្រាក់សុទ្ធ		**2,530,351**	**10,149,238**	**2,640,205**	**10,748,275**
ចំណូលមិនមែនជាការប្រាក់ - សុទ្ធ	20	3,190,289	12,796,249	3,168,278	12,898,060
ចំណូលប្រតិបត្តិការសរុប		**5,720,640**	**22,945,487**	**5,808,483**	**23,646,335**
ចំណាយលើបុគ្គលិក	21	(3,700,054)	(14,840,917)	(3,802,954)	(15,481,826)
ចំណាយប្រតិបត្តិការផ្សេងៗ	22	(2,637,699)	(10,579,811)	(3,388,424)	(13,794,274)
ចំណាយរំលស់	23	(866,381)	(3,475,054)	(796,117)	(3,240,992)
ចំណាយពន្ធអប្បបរមា	15(ក)	(163,812)	(657,050)	(146,802)	(590,878)
ខាតប្រតិបត្តិការមុនការខាតបង់ឥនភាពតម្លៃ		**(1,647,306)**	**(6,607,345)**	**(2,325,814)**	**(9,461,635)**
ឥនភាពតម្លៃ	24	(990,030)	(3,971,010)	95,545	388,964
ខាតមុនបង់ពន្ធ		**(2,637,336)**	**(10,578,355)**	**(2,230,269)**	**(9,072,671)**
ចំណាយពន្ធលើប្រាក់ចំណូល	15(ក)	-	-	(252,478)	(1,027,838)
ខាតសម្រាប់ការិយបរិច្ឆេទ		(2,637,336)	(10,578,355)	(2,482,747)	(10,107,263)
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(979,701)	-	(4,888,782)
លទ្ធផលខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		**(2,637,336)**	**(11,558,056)**	**(2,482,747)**	**(14,996,045)**

កំណត់សម្គាល់ដែលមានភ្ជាប់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

	កំណត់សម្គាល់	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ	សរុប	
		ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
នាថ្ងៃទី1 ខែមករា ឆ្នាំ2024		75,000,000	299,625,000	2,160,910	8,869,042	10,943,239	44,522,344	6,889,063	88,104,149	359,905,449
លទ្ធផលខាត លម្អិត										
ខាតសម្រាប់ការិយបរិច្ឆេទ		-	-	-	-	(2,482,747)	(10,107,263)	-	(2,482,747)	(10,107,263)
លទ្ធផលខាតលម្អិតផ្សេងៗ		-	-	-	-	-	-	(4,888,782)	-	(4,888,782)
លទ្ធផលខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		-	-	-	-	(2,482,747)	(10,107,263)	(4,888,782)	(2,482,747)	(14,996,045)
ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន										
ផ្ទេរពីចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ		-	-	2,432,178	9,901,397	(2,432,178)	(9,901,397)	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	-	(283,260)	-	-	-	-	(283,260)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024		**75,000,000**	**299,625,000**	**4,593,088**	**18,487,179**	**6,028,314**	**24,513,684**	**2,000,281**	**85,621,402**	**344,626,144**
នាថ្ងៃទី1 ខែមករា ឆ្នាំ2025		75,000,000	299,625,000	4,593,088	18,487,179	6,028,314	24,513,684	2,000,281	85,621,402	344,626,144
លទ្ធផលខាត លម្អិត										
ខាតសម្រាប់ការិយបរិច្ឆេទ		-	-	-	-	(2,637,336)	(10,578,355)	-	(2,637,336)	(10,578,355)
លទ្ធផលខាតលម្អិតផ្សេងៗ		-	-	-	-	-	-	(979,701)	-	(979,701)
លទ្ធផលខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		-	-	-	-	(2,637,336)	(10,578,355)	(979,701)	(2,637,336)	(11,558,056)
ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន										
ផ្ទេរពីចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ		-	-	1,042,324	4,180,762	(1,042,324)	(4,180,762)	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	-	(53,033)	-	-	-	-	(53,033)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		**75,000,000**	**299,625,000**	**5,635,412**	**22,614,908**	**2,348,654**	**9,754,567**	**1,020,580**	**82,984,066**	**333,015,055**

កំណត់សម្គាល់ដែលមានភ្ជាប់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

	កំណត់សម្គាល់	2025 ដុល្លារអាមេរិក	2025 ៣ន់រៀល	2024 ដុល្លារអាមេរិក (ដូចបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់ 31)	2024 ៣ន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ខាតមុនបង់ពន្ធ		(2,637,336)	(10,578,355)	(2,230,269)	(9,072,671)
និយ័តកម្មលើ៖					
ចំណាយរំលស់	23	866,381	3,475,054	796,117	3,240,992
ការខាតបង់/(កត់ត្រាបញ្ច្រាស់)ឱនភាពតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ	24	990,030	3,971,010	(95,545)	(388,964)
ការលុបចោលទ្រព្យសម្បត្តិ និងបរិក្ខារ		123	493	63,797	259,718
ចំណូលការប្រាក់	18	(11,794,786)	(47,308,887)	(10,844,629)	(44,148,485)
ចំណាយការប្រាក់	19	9,264,435	37,159,649	8,204,424	33,400,210
ខាតប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល		(3,311,153)	(13,281,036)	(4,106,105)	(16,709,200)
បម្រែបម្រួលទុនបង្វិល៖					
តណទានផ្តល់ដល់អតិថិជន - សុទ្ធ		3,276,928	13,143,758	1,962,196	7,988,100
ទ្រព្យសកម្មផ្សេងៗ		1,366,235	5,479,969	(185,155)	(753,766)
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ		(1,698,034)	(6,810,814)	(1,048,706)	(4,269,282)
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា		(14,531,342)	(58,285,213)	35,947,041	146,340,404
បំណុលផ្សេងៗ		(633,493)	(2,540,940)	113,358	461,480
សាច់ប្រាក់(ប្រើប្រាស់ក្នុង)/ប្រតិបត្តិការ		**(15,530,859)**	**(62,294,276)**	**32,682,629**	**133,057,736**
ចំណូលការប្រាក់ដែលបានទទួល		11,143,974	44,698,480	9,933,094	40,437,626
ចំណាយការប្រាក់ដែលបានបង់		(9,189,483)	(36,859,016)	(5,475,055)	(22,288,949)
ហូរសាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីសកម្មភាពប្រតិបត្តិការ		**(13,576,368)**	**(54,454,812)**	**37,140,668**	**151,206,413**
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ការដាក់ប្រាក់តម្កល់មានកាលកំណត់		(8,022,115)	(32,176,703)	(11,050,609)	(44,987,029)
ការទិញទ្រព្យសកម្មអរូបី	12	(206,260)	(827,309)	(320,015)	(1,302,781)
ការទិញទ្រព្យសម្បត្តិ	13	(132,185)	(530,194)	(134,140)	(546,084)
ការទិញមូលបត្របំណុល		(2,990,282)	(11,994,021)	-	-
លំហូរសាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ		**(11,350,842)**	**(45,528,227)**	**(11,504,764)**	**(46,835,894)**

	កំណត់សម្គាល់	2025 ដុល្លារអាមេរិក	2025 ៣ន់រៀល	2024 ដុល្លារអាមេរិក (ដូចបានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់ 31)	2024 ៣ន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
ការទូទាត់បំណុលភតិសន្យាតំណាងឱ្យសាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាព		(435,802)	(1,748,002)	(411,945)	(1,677,028)
(តំហយ)/កំណើនសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល		(25,363,012)	(101,731,041)	25,223,959	102,693,491
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ		112,281,287	451,932,180	87,057,328	355,629,183
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(1,398,102)	-	(6,390,494)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ	26	**86,918,275**	**348,803,037**	**112,281,287**	**451,932,180**

កំណត់សម្គាល់ដែលមានភ្ជាប់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

1. ព័ត៌មានអំពីធនាគារ

ធនាគារ កម្ពុជា អាស៊ី ចំកាត់ (ហៅកាត់ថា “ធនាគារ”) ត្រូវបានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី7 ខែឧសភា ឆ្នាំ1996 ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ 00029165 ចេញដោយក្រសួងពាណិជ្ជកម្ម និងចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួនក្រោយទទួលបានអាជ្ញាប័ណ្ណពី NBC។

ការិយាល័យចុះបញ្ជី និងទីស្នាក់ការកណ្តាល របស់ធនាគារមានទីតាំងបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ 75C 036 មហាវិថីព្រះសីហនុ សង្កាត់រាលវង់ ខណ្ឌប្រាំពីរមករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ននេះ ធនាគារមានសាខាចំនួន 8 កន្លែង ដែលសាខាចំនួន 3 មានទីតាំងនៅរាជធានីភ្នំពេញ និងមួយសាខានៅតាមបណ្តាខេត្តនានាដូចជាខេត្តសៀមរាប ក្រុងព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកំពត និងខេត្តកំពង់ចាម។

សកម្មភាពចម្បងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការជាអាជីវកម្មធនាគារ និងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តនៃសកម្មភាពអាជីវកម្មចម្បងរបស់ ធនាគារក្នុងកំឡុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុឡើយ។

2. មូលដ្ឋាននៃការរៀបចំ

2.1 របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “ស.រ.ទ.ហ.អ.ក”)។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងជារបាយការណ៍ហិរញ្ញវត្ថុដោយឡែក។ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ មិនត្រូវបានរួមបញ្ចូលជាមួយគ្នានោះទេ។

2.2 មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ បានរៀបចំតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានការបង្ហាញផ្សេងពីនេះនៅក្នុងកំណត់សម្គាល់ 3 នៃរបាយការណ៍ហិរញ្ញវត្ថុ។

2.3 ការអនុវត្ត ស.រ.ទ.ហ.អ.ក ថ្មី និងការធ្វើវិសោធនកម្ម ឬការកែសម្រួល ស.រ.ទ.ហ.អ.ក

(ក) វិសោធនកម្ម/ការកែសម្រួលស្តង់ដាដែលបានអនុវត្តក្នុងការិយបរិច្ឆេទវិសោធនកម្ម ឬការកែសម្រួលស្តង់ដាខាងក្រោមនេះ ត្រូវបានអនុវត្តដោយធនាគារ ប៉ុន្តែមិនមានផលប៉ះពាល់ជាសារវន្តទៅលើការិយបរិច្ឆេទបច្ចុប្បន្ន ឬលើការិយបរិច្ឆេទមុនៗ ហើយក៏មិនមានផលប៉ះពាល់ដល់ការិយបរិច្ឆេទនាពេលអនាគតឡើយ។

- កង្វះខាតនៃភាពដែលអាចផ្លាស់ប្តូរបាន - វិសោធនកម្មទៅលើ ស.គ.អ.ក 21

2.3 ការអនុវត្ត ស.រ.ទ.ហ.អ.ក ថ្មី និងការធ្វើវិសោធនកម្ម ឬការកែសម្រួល ស.រ.ទ.ហ.អ.ក (ត)

(ខ) ស្តង់ដា និងវិសោធនកម្ម/ការកែសម្រួលដែលបានចេញផ្សាយតែមិនទាន់ចូលជាធរមាន

	ថ្ងៃចូលជាធរមាន សម្រាប់ការិយបរិច្ឆេទ ចាប់ផ្តើម ឬបន្ទាប់
ស្តង់ដាថ្មី	
ស.រ.ហ.អ.ក 18 ការបង្ហាញ និងការលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ	ថ្ងៃទី1 ខែមករា ឆ្នាំ2027
វិសោធនកម្ម/ការកែសម្រួល	
ស.រ ហ.អ.ក 7 និង ស.រ ហ.អ.ក 9 វិសោធនកម្មលើការចាត់ថ្នាក់ និងវាស់វែងឧបករណ៍ហិរញ្ញវត្ថុ	ថ្ងៃទី1 ខែមករា ឆ្នាំ2026

ធនាគារនៅមិនទាន់បានអនុវត្តនូវស្តង់ដា និងវិសោធនកម្មថ្មីនេះ មុនកាលកំណត់នៅឡើយទេ។ បច្ចុប្បន្ននេះ ធនាគារកំពុងធ្វើការវាយតម្លៃពីផលប៉ះពាល់ ថាតើស្តង់ដាទាំងនេះនឹងមានឥទ្ធិពលលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែរឬទេ។ ដោយឡែកលើវិសាលភាពនៃ ស.រ.ហ.អ.ក 18 វាត្រូវបានរំពឹងថា មានផលប៉ះពាល់ជាសារវន្តទៅលើការបង្ហាញ និងការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ចំណេញ ឬខាតនាពេលអនាគត។

2.4 រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណជាតិនៃប្រទេសកម្ពុជា គឺប្រាក់រៀល។ ប៉ុន្តែដោយសារតែធនាគារមានប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ ត្រាបញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ក្រុមប្រឹក្សាភិបាលបានកំណត់ដុល្លារអាមេរិកជារូបិយប័ណ្ណ គោលរបស់ធនាគារ ក្នុងការវាស់វែង និងបង្ហាញដែលឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានភាពរបស់ធនាគារ។

ការប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយ អនុលោមតាមបទប្បញ្ញត្តិស្តីពីគណនេយ្យនិងសវនកម្ម ហើយបានប្រើប្រាស់អត្រាប្តូរប្រាក់បិទប្រចាំឆ្នាំ និងអត្រាប្តូរប្រាក់មធ្យមផ្លូវការដោយ 1ដុល្លារអាមេរិក ស្មើនឹង 4,013រៀល និង 1ដុល្លារអាមេរិក ស្មើនឹង 4,011រៀល រៀងគ្នា សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 (ឆ្នាំ2024៖ 4,025រៀល និង 4,071រៀល) ដូចដែលបានប្រកាសដោយ NBC។ លម្អៀងពីការប្តូររូបិយប័ណ្ណ ដែលកើតឡើងពីការប្តូរនេះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ការប្តូរប្រាក់នេះ មិនគួរត្រូវបានប្រើប្រាស់ជាតំណាងឱ្យចំនួនទឹកប្រាក់ដុល្លារអាមេរិកដែលត្រូវបាន ឬអាចត្រូវបាន ឬនឹងប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ដទៃទៀតឡើយ។

3. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត

3.1 ឧបករណ៍ហិរញ្ញវត្ថុ

(ក) ការវាស់វែងដំបូង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់នៅពេលដែលធនាគារក្លាយជាភាគីនៃសំវិធានធនកិច្ចសន្យា នៃឧបករណ៍ហិរញ្ញវត្ថុ។

ក្នុងការទទួលស្គាល់ដំបូង ធនាគារបានវាស់វែង ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្របបូកនឹងថ្លៃដើមប្រតិបត្តិការ ដែលបណ្តាលមកពីការទិញ ឬបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានបូកបន្ថែម ឬកាត់បន្ថយពីតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ តាមភាពសមស្រប។

(ខ) ការធ្វើចំណាត់ថ្នាក់

ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាមថ្លៃដើមរំលស់ ឬតម្លៃសមស្របតាមលទ្ធផលលម្អិតផ្សេងៗ (“FVOCI”)។

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់តាម FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុក ដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”)។

ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មដែលនៅក្នុងកម្រិតផលប័ត្រនីមួយៗព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅគណៈគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលការណ៍ និងគោលបំណងដែលបានបញ្ជាក់សម្រាប់ផលប័ត្រ និងអនុវត្តនូវគោលការណ៍ទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវ ទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឱ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃផលប័ត្រ និងវិធីរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងម៉ូឌែលអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពី សកម្មភាពលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានគិតដាច់ ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅអំពីរបៀបដែលធ្វើឱ្យសម្រេចបាននូវគោល បំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ។

ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”)

ចំពោះគោលបំណងនៃការវាយតម្លៃនេះ “ប្រាក់ដើម” ត្រូវបានកំណត់ថាជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង។ “ការប្រាក់” ត្រូវបានកំណត់ថាជាតម្លៃតបស្នងមួយសម្រាប់តម្លៃពេលវេលា និងសម្រាប់ហានិភ័យឥណទានដែលពាក់ព័ន្ធនឹងចំនួនប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ហានិភ័យផ្តល់កម្ចី និងចំណាយជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាព និងចំណាយ
រដ្ឋបាល) រួមទាំងកម្រិតប្រាក់ចំណេញ។

ដើម្បីវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺ សម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ធនាគារត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលមិនអាចបំពេញលក្ខខណ្ឌនេះ។
ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរសាច់ប្រាក់

- លក្ខខណ្ឌអានុភាព
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតធនាគារ ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃពេលវេលានៃសាច់ប្រាក់ (ឧទាហរណ៍៖ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)។

ឥណទានដែលមិនអាចប្រមូលមកវិញបាន

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយធនាគារដែលត្រូវបានធានាដោយទ្រព្យសកម្មរបស់អតិថិជន ដាក់កំហិត ធនាគារក្នុងការទាមទារសាច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន)។ ក្នុងករណីនេះ ធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះអាចបំពេញលក្ខខណ្ឌ SPPI ដែរទេ។ ជាទូទៅធនាគារ ពិចារណាលើព័ត៌មានខាងក្រោម ក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងឥណទាន ដែរឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជនក្នុងការទូទាត់សងតាមកិច្ចសន្យាទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារក្នុងការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលមិនមានទ្រព្យបញ្ចាំ
- ថាតើទ្រព្យដាក់ធានា គឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬជាផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើធនាគារទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ដែរឬទេ។

ការធ្វើចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុង អំឡុងពេលដែលធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

បំណុលហិរញ្ញវត្ថុ

ធនាគារ បានធ្វើចំណាត់ថ្នាក់បំណុលហិរញ្ញវត្ថុ ក្រៅពីការធានាហិរញ្ញវត្ថុ និងកាតព្វកិច្ចផ្តល់ឥណទាន ទៅតាមថ្លៃដើមរំលស់ ឬតាមតម្លៃសមស្របតាមចំណេញនិងខាត (FVPL)។ គិតត្រឹមការិយបរិច្ឆេទរបាយការណ៍ ធនាគារមិនមានបំណុលហិរញ្ញវត្ថុណាមួយដែលត្រូវបានចាត់ថ្នាក់ជា FVPL ទេ។

(គ) ការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារ ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពី ទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យ ទាំងអស់ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាម្ចាស់កម្មសិទ្ធិហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជា ចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងតម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលបានសន្មត) និងចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។

បំណុលហិរញ្ញវត្ថុ

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតកំណត់។

(ឃ) ការកែប្រែឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យ សកម្មដែលបានកែប្រែនោះមានភាពខុសគ្នាខ្លាំង ដែឬទេ។ ធនាគារ ពិចារណាក្នុងចំណោមកត្តាផ្សេងទៀត៖

- ប្រសិនបើអតិថិជនមានផលវិបាកផ្នែកហិរញ្ញវត្ថុ នោះថាតើការកែប្រែនឹងកាត់បន្ថយលំហូរសាច់ប្រាក់តាមកិច្ចសន្យាធៀបទៅនឹងចំនួនទឹកប្រាក់ដែលរំពឹងថាអតិថិជន អាចនឹងមានលទ្ធភាពទូទាត់សង។
- ថាតើមានលក្ខខណ្ឌថ្មីណាមួយដែលត្រូវបានបង្ហាញដែលអាច នឹងមានផលប៉ះពាល់ទៅដល់ប្រភេទហានិភ័យនៃឥណទាន ដែរឬទេ។
- ការពន្យាររយៈពេលនៃឥណទានជាសារវន្ត នៅពេលដែលអតិថិជនមិនមានផលវិបាកផ្នែកហិរញ្ញវត្ថុ
- ការប្រែប្រួលនៃអត្រាការប្រាក់ជាសារវន្ត
- ការប្តូររូបិយប័ណ្ណនៃប្រាក់កម្ចីត្រូវបានកំណត់ និង/ឬ
- ការដាក់នូវទ្រព្យបញ្ចាំ ការធានាផ្សេងៗ ឬការពង្រឹងឥណទានដែលនឹងមានផលប៉ះពាល់ដល់ហានិភ័យ ឥណទានជាសារវន្ត ពាក់ព័ន្ធនឹងប្រាក់កម្ចី

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាពីទ្រព្យសកម្ម ហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាផុតកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើលចំណុច(គ)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការ។

ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

- ថ្លៃសេវា ដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលទទួលបានមក វិញលើថ្លៃចំណាយប្រតិបត្តិការដែលកើតឡើង ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ចំណេញ និងខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើទ្រព្យសកម្ម ដែលឈប់ទទួលស្គាល់។

ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែ នៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃ ការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មី ដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ ទ្រព្យសកម្មនោះ ត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ដែរឬទេ (សូមមើលខាងក្រោមសម្រាប់គោលការណ៍នៃការលុបចេញពីបញ្ជី)។ វិធីសាស្ត្រនេះជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យជាទូទៅមិនអាចអនុវត្តបាននោះទេ។

ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានរាស់វែងតាមរំលស់ថ្លៃដើម មិនបណ្តាលឱ្យមានការឈប់ទទួល ស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេ នោះធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលពីការកែតម្រូវ ជាចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាប្រែប្រួល អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើប្រាស់ដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែ ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបាន ដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។

ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃ។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរសាច់ប្រាក់ពីបំណុលដែលបានកែតម្រូវនោះ មានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុ ដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នងដែលចបានបង់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។ តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុល រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះ មិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុលត្រូវ គណនាឡើងវិញ ដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាការប្រាក់ប្រែប្រួល អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវត្រូវបានកែប្រែ ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមានត្រូវបានទទួលស្គាល់ជា ការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុ ដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញ លើឧបករណ៍ហិរញ្ញវត្ថុ។

(ង) ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុអាចបានត្រូវកាត់កងគ្នា និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែធនាគារមានសិទ្ធិតាមបទប្បញ្ញត្តិដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

(ច) ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច។

ធនាគារ វាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើតម្លៃដកស្រង់នៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬ បំណុល កើតឡើងជាញឹកញាប់

ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យ ដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើសត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារ នឹងពិចារណានៅក្នុងការកំណត់តម្លៃ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃតម្លៃតបស្នងដែលបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះ ពុំមានភស្តុតាងមកបញ្ជាក់តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្ម ចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបាន ពាក់ព័ន្ធនឹងការវាស់វែងត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្របដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្រប នៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះ គឺត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្របមានតម្លៃលក់ និងតម្លៃទិញនោះ ធនាគារ វាស់វែងទ្រព្យសកម្មនិងស្ថានភាពវែងតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ។សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានប្រឈមនឹងហានិភ័យទីផ្សារ និងហានិភ័យឥណទានដែលត្រូវបានចាត់ចែងដោយធនាគារ ផ្អែកតាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទានត្រូវបានវាស់វែងតាមមូលដ្ឋាននៃតម្លៃ ដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមានស្ថានភាពវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមានស្ថានភាពខ្លី) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវត្រឹមកម្រិតសំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថា ការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទានដែលឆ្លុះបញ្ចាំងពីការ វាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធ គឺត្រូវបានបែងចែកតាមទ្រព្យសកម្ម និងបំណុលនីមួយៗ តាមមូលដ្ឋានការកែតម្រូវ ហានិភ័យដែលពាក់ព័ន្ធនៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗនៃទ្រព្យសកម្ម និងបំណុលនោះ នៅក្នុងសំណុំទ្រព្យនោះ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍៖ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាច ត្រូវបានបង់។ ធនាគារទទួលស្គាល់ការផ្ទេរវាងកម្រិតនៃហានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទរាយការណ៍អំឡុងពេល ដែលការផ្លាស់ប្តូរបានកើតឡើង។

(ឆ) ឱនភាពតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារ ទទួលស្គាល់សំវិធានធនលើការខាតបង់តណទានរំពឹងទុក (“ECL”) ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាឧបករណ៍បំណុល
- តណទាន និង បុរេប្រទាន និង
- កិច្ចសន្យាតណទានដែលបានបោះផ្សាយ។

ពុំមានការខាតបង់លើឱនភាពតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ។ ធនាគារ វាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹងការខាតបង់តណទានរំពឹងទុកពេញមួយអាយុកាល លើកលែងគណនីខាងក្រោមដែលត្រូវវាស់វែងតាមការខាតបង់តណទានរំពឹងទុករយៈពេល 12ខែ៖

- ការវិនិយោគលើមូលបត្របំណុលដែលត្រូវបានកំណត់ថា មានហានិភ័យតណទានទាប នាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យតណទានមិនបានកើនឡើងជា សារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

ការខាតបង់តណទានរំពឹងទុក 12ខែ ECL នឹងត្រូវបានគណនា សម្រាប់ដំណាក់កាលទី 1 ខណៈដែល ECL ពេញមួយអាយុកាលនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី 2 និងដំណាក់កាលទី 3។

ការខាតបង់តណទានរំពឹងទុក 12ខែ គឺជាផ្នែកនៃការរំពឹងទុកលើការខាតបង់តណទាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល12 ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបាន ទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់តណទាន 12ខែ ត្រូវបានចាត់ទុកជា “ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី 1”។

ការខាតបង់តណទានរំពឹងទុកពេញមួយអាយុកាល (Life-time ECL) គឺជាការខាតបង់តណទានរំពឹងទុក ដែលអាច បណ្តាលមកពីព្រឹត្តិការណ៍នៃការខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការខាតបង់តណទានរំពឹងទុកពេញមួយអាយុកាល ប៉ុន្តែមិនមែនជាតណទាន ដែលមានឱនភាពតម្លៃត្រូវបានចាត់ទុកជា “ឧបករណ៍ហិរញ្ញវត្ថុស្ថិតនៅក្នុងដំណាក់កាលទី 2”។

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថា តើហានិភ័យតណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើង ជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូងដែរឬទេ។ នៅពេលហានិភ័យតណទានកើតឡើងជាសារវន្ត តាំងពី ពេលទទួលស្គាល់ដំបូង សំវិធានធននៃការខាតបង់ ត្រូវបានវាស់វែងស្មើនឹង ការខាតបង់តណទានរំពឹងទុកពេញមួយអាយុកាល។ពេលកំណត់ថាតើហានិភ័យតណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ លើកដំបូង និងនៅពេលប៉ាន់ស្មានលើការខាតបង់តណទានរំពឹងទុកនោះធនាគារពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រដែលពាក់ព័ន្ធ និងអាចរកបានដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្ពស់។ ព័ត៌មានទាំងនេះរួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគដោយផ្អែកលើបទពិសោធន៍របស់ធនាគារ និងការវាយតម្លៃតណទានដែលមានស្រាប់ព្រមទាំងរួមបញ្ចូលនូវព័ត៌មានពេលអនាគត។

ប្រសិនបើហានិភ័យតណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើគុណភាពតណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើង ដែលមិនបណ្តាលឱ្យមានការកើនឡើងជាសារវន្តនៃហានិភ័យតណទានចាប់តាំងពីការទទួលស្គាល់លើកដំបូង នោះសំវិធានធនលើការបាត់បង់ ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងការខាតបង់តណទានរំពឹងទុករយៈពេល 12ខែ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មានលើការខាតបង់តណទានដែលរំពឹងទុក គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលធនាគារប្រឈមនឹងហានិភ័យតណទាន។

ការកំណត់ថាតើហានិភ័យឥណទានបានកើនឡើងជាសារវន្ត ដែរឬទេ

ធនាគារវាយតម្លៃថាតើហានិភ័យឥណទានបានកើនឡើងជាសារវន្ត ដែរឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូង នៅកាលបរិច្ឆេទរាយការណ៍។ ការកំណត់ពីការកើនឡើងនៃហានិភ័យឥណទានផ្អែកជាសំខាន់លើចរិតលក្ខណៈនៃ ឧបករណ៍ហិរញ្ញវត្ថុ និងអតិថិជន និងតំបន់ភូមិសាស្ត្រ។

ធនាគារពិចារណាថាការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត បានកើនឡើងជាសារវន្តនៅពេលទ្រព្យសកម្មនោះមានការយឺតយ៉ាវក្នុងការសងមិនតិចជាងរយៈពេល 30ថ្ងៃ។ ចំនួនថ្ងៃយឺតយ៉ាវក្នុងការសងត្រូវបានកំណត់ដោយរាប់ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ នៅពេលដែលការទូទាត់ទាំងស្រុងនៅមិនទាន់បានទទួលដោយធនាគារនៅឡើយ។ កាលបរិច្ឆេទផុតកំណត់សង ត្រូវបានកំណត់ដោយមិនពិចារណាទៅលើរយៈពេលអនុគ្រោះណាមួយដែលអាចមានសម្រាប់អតិថិជននោះឡើយ។

ប្រសិនបើ មានភស្តុតាងបញ្ជាក់ថាមិនមានការកើនឡើងលើហានិភ័យឥណទានជាសារវន្ត ទាក់ទងនឹងការទទួលស្គាល់លើកដំបូងទេ នោះសំវិធានធននៃការបាត់បង់លើឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវរាស់វែងតាមការខាតបង់ឥណទានរំពឹងទុក 12ខែ។

និយមន័យនៃការខកខានសង

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចី មិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- អ្នកខ្ចីមានថ្ងៃដែលហួសការកំណត់សងលើសពីឬស្មើនឹង 90ថ្ងៃ សម្រាប់កម្ចីរយៈពេលវែង ឬមានថ្ងៃដែលហួស កាលកំណត់សងលើសពី ឬស្មើនឹង 31ថ្ងៃ សម្រាប់កម្ចីរយៈពេលខ្លីទៅលើកាតព្វកិច្ចជាសារវន្តណាមួយចំពោះ ធនាគារ ឬ
- នៅពេលអ្នកខ្ចី និងរៀបចំឡើងវិញនូវទ្រព្យសកម្ម ដែលជាលទ្ធផលនៃការក្ស័យធន ដោយសារតែអសមត្ថភាពសងក្នុងកាតព្វកិច្ចឥណទាន។

ការវាស់វែងការខាតបង់ឥណទានរំពឹងទុក

ការខាតបង់ឥណទានរំពឹងទុក គឺជាការប៉ាន់ស្មានលទ្ធភាពនៃការបាត់បង់ឥណទាន។ ការខាតបង់ឥណទានរំពឹងទុកត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ឧទាហរណ៍៖ គឺភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ធនាគារស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន)
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និង តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគត
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែល ជំពាក់ធនាគារ ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរសាច់ប្រាក់ដែល ធនាគារពឹងទុកថានឹងទទួលបាន។

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ

សមាសធាតុសំខាន់ៗ ក្នុងការវាស់វែងលើការខាតបង់តណទានរំពឹងទុកគឺបានមកពីអថេរដូចខាងក្រោម៖
- ប្រូបាប៊ីលីតេនៃតណទានខូច (“PD”);
- ការខាតបង់ដែលបានកើតមាន (“LGD”) និង
- ទំហំនៃការខាតបង់ពេលតណទានខូច (“EAD”)

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី 1 ត្រូវបានគណនាដោយផលគុណនៃ PD 12ខែ ដោយ LGD និង EAD។ ECL ពេញមួយអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញមួយអាយុកាលដោយ LGD និង EAD។

PD ផ្តល់នូវការប៉ាន់ស្មានអំពីលទ្ធភាពដែលអតិថិជននឹងមិនអាចបំពេញកាតព្វកិច្ចលើតណទានរបស់ខ្លួន ឬខកខានមិនបានសងឱ្យបានទាន់ពេលវេលាជាក់លាក់ណាមួយ។ ទ្រព្យសកម្មហិរញ្ញវត្ថុក្រោមវិធីសាស្ត្រទូទៅ តម្រូវឱ្យមានការធ្វើតាមដំណាក់កាលសម្រាប់ការប៉ាន់ស្មាន PD រយៈពេល 12ខែ និងការប៉ាន់ស្មាន PD ពេញមួយអាយុកាល ដោយយោងទៅតាមទិន្នន័យប្រវត្តិសាស្ត្រដោយប្រើវិធីសាស្ត្របំប្លែងទិន្នន័យ ឬវិធីសាស្ត្រវាយតម្លៃតណទានខាងក្រៅ។

LGD គឺជាតរិយាបទនៃភាពអាចបាត់បង់ ប្រសិនបើមានការខកខានសង។ ធនាគារប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិនៃអត្រា ការប្រមូលត្រឡប់ពីអតិថិជនខកខានសង។ គំរូ LGD ត្រូវបានពិចារណាលើរចនាសម្ព័ន្ធអាទិភាពនៃការទាមទារ សំណងវិស័យដែលអតិថិជនស្ថិតនៅចំណាយលើការប្រមូលពីទ្រព្យបញ្ចាំ ដែលជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្រាប់តណទានដែលការពារដោយទ្រព្យអនុបាតតណទានធៀបនឹងតម្លៃទ្រព្យបញ្ចាំ (“LTV”) គឺជាលក្ខខណ្ឌមួយក្នុងការកំណត់ LGD។ ការប៉ាន់ស្មាន LGD ត្រូវបានវាស់វែងសម្រាប់វិស័យផ្សេងៗគ្នា ហើយសម្រាប់តណទានគេហដ្ឋាន គឺអាស្រ័យលើការប្រែប្រួលតម្លៃអចលនទ្រព្យ។ តម្លៃទាំងនោះនឹងត្រូវបានគណនាដោយអប្បហារដោយផ្អែកលើអត្រាការប្រាក់ប្រសិទ្ធភាព។

EAD តំណាងឱ្យតម្លៃសមតុល្យនៅពេលមានការខកខានសង។ ធនាគារទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់ អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការ បង់រំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុគឺ តម្លៃយោងដុលនៅពេលមានការខកខានសង។ សម្រាប់កាតព្វកិច្ចឱ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និង ការព្យាករណ៍នាពេលខាងមុខ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែល អាចកើតឡើងនៅពេលវេលាផ្សេងគ្នាដោយប្រើបច្ចេកទេសស្ថិតិ។

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD 12ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី 1 ធនាគារវាស់វែងការរំពឹងទុកលើការខាតបង់តណទាន ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេលពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យារប្រសិនបើមាន) ដែលមានហានិភ័យលើតណទាន ទោះបី ជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យតណទានក៏ដោយ ធនាគារពិចារណាលើរយៈពេលដែលវែងជាង។ រយៈពេលដែលវែងបំផុតគឺ គិតត្រឹមថ្ងៃដែលធនាគារមានសិទ្ធិ ដើម្បីទាមទារការសងត្រឡប់នៃតណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់តណទាន ឬការធានា។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបាន ជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជននោះ ការវាយតម្លៃត្រូវ បានធ្វើឡើងដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ឬទេហើយ ECL ត្រូវបានវាស់វែង ដូចខាងក្រោម៖
- ប្រសិនបើការរៀបចំឡើងវិញ មិននាំឱ្យឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរសាច់ប្រាក់ ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកែតម្រូវត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ នាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្រប រំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុ បច្ចុប្បន្ននៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះ ត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

នៅថ្ងៃទី28 ខែធ្នូ ឆ្នាំ2021 ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំលេខ ធ7-021-2314 ស្តីពីការធ្វើចំណាត់ ថ្នាក់ និងការធ្វើសំវិធានធនតណទានរៀបចំឡើងវិញ។ នៅថ្ងៃទី18 ខែមករា ឆ្នាំ2022 សិក្ខាសាលាមួយរវាងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ (“BFIs”) ត្រូវបានប្រារព្ធឡើងក្រោមសមាគមធនាគារនៅកម្ពុជា និងធនាគារជាតិនៃកម្ពុជា ដើម្បីជួយដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ក្នុងការអនុវត្តសារាចររបស់ពួកគេ និងដើម្បីពិភាក្សាអំពីបញ្ហាជាក់ស្តែងពាក់ព័ន្ធផ្សេងទៀត។ បន្ទាប់ពី

សិក្ខាសាលានេះ ធនាគារជាតិនៃកម្ពុជាបានជូនដំណឹងដល់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ តាមរយៈលិខិតលេខ ធ7-022-167។ ចុះថ្ងៃទី20 ខែមករា ឆ្នាំ2022 ស្តីពីការពន្យាររយៈពេលនៃការបញ្ជូនរបាយការណ៍ប្រចាំខែរហូតដល់ថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ2022 និងការផ្លាស់ប្តូរទិន្នន័យហិរញ្ញវត្ថុដែលត្រូវប្រើនៅ ខែមករា ឆ្នាំ2022 ក្នុងចំណោមផ្សេងទៀត។ នៅថ្ងៃទី 29 ខែសីហា ឆ្នាំ 2024 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំលេខ ប7.024.001 ស្តីពីការរៀបចំតណាទានឡើងវិញ ដោយអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចរៀបចំតណាទានឡើងវិញសម្រាប់អតិថិជនរហូតដល់ពីរដង ដោយរក្សាចំណាត់ថ្នាក់តណាទានដដែល និងមិនតម្រូវឱ្យផ្តល់សំវិធានធនបន្ថែម។

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគាររាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមថ្លៃដើម បានរំលស់ និងបំណុលទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកត់ត្រាតាម “FVOCI” មានឱនភាពឥណទាន (សំដៅដល់ “ទ្រព្យសកម្មហិរញ្ញវត្ថុកម្រិតទី3”)។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពតម្លៃ នៅពេលព្រឹត្តិការណ៍មួយ ឬច្រើនមានផលប៉ះពាល់យ៉ាងខ្លាំងលើលំហូរសាច់ប្រាក់នាពេលអនាគតរបស់ទ្រព្យសកម្ម ហិរញ្ញវត្ថុបានកើតឡើង។ ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អ្នកខ្ចី ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់តណាទាន ឬបុរេប្រទាន ដែលធនាគារមិនយល់ព្រម
- អ្នកខ្ចីទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

តណាទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អ្នកខ្ចី ត្រូវបានចាត់ទុកជាតណាទានមានឱនភាពតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថា ហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានការចង្អុលបង្ហាញផ្សេងទៀតដែលនាំឱ្យមានឱនភាពតម្លៃ។ បន្ថែមលើនេះ តណាទានដែលហួសកាលកំណត់សង 90ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកជាតណាទានមានឱនភាពតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសំវិធានធនការខាតបង់តណាទានរំពឹងទុក ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលរាស់វែងតាមរំលស់ថ្លៃដើម ដោយធ្វើការកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្ម។

ការលុបចោល ទ្រព្យសកម្មហិរញ្ញវត្ថុ

តណាទាន និងបុរេប្រទានផ្តល់ដល់អតិថិជនត្រូវបានលុបចេញពីបញ្ជី (មួយផ្នែកឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះ មានជាទូទៅនៅពេលធនាគារ កំណត់ថា អ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សង នូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញពីចំនួនដែលបានលុបចេញពីបញ្ជីពីគ្រាមុនត្រូវបញ្ចូលទៅក្នុង “ការខាតបង់ឱនភាពតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ” នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជីនៅតែតម្រូវឱ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់ធនាគារក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់។

3.2 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃការបង្ហាញ ក្នុងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់នៅក្នុងដៃ សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុ និងសមតុល្យនៅធនាគារជាតិនៃកម្ពុជា និងការវិនិយោគរយៈពេលខ្លីដែលមានសន្ទនីយភាពខ្ពស់ ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ និងមានកាលវសានៅពេលតម្កល់ដំបូងមានរយៈពេល 3ខែ គិតចាប់ពីថ្ងៃទទួលបាន។

3.3 ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពតម្លៃប្រសិនបើមាន។

3.4 ប្រាក់តម្កល់តាមបទប្បញ្ញត្តិ

ប្រាក់តម្កល់តាមបទប្បញ្ញត្តិ តំណាងឱ្យទុនបម្រុងកាតព្វកិច្ច និងសាច់ប្រាក់ដែលត្រូវបានរក្សាទុកនៅធនាគារជាតិនៃ កម្ពុជា ស្របតាមបទប្បញ្ញត្តិ ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា (“LBFI”) និងមិនត្រូវបានប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារឡើយ ហេតុដូច្នេះវាមិនត្រូវបានចាត់ទុកជាចំណែកនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលស ម្រាប់គោលបំណងក្នុងរបាយការណ៍លំហូរសាច់ប្រាក់នោះទេ។

3.5 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមអាជ្ញាប័ណ្ណកុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រា តាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពតម្លៃបង្គរ ប្រសិនបើមាន។ អាជ្ញាបណ្ណកុំព្យូទ័រដែលបាន ទិញត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីកុំព្យូទ័រជាក់លាក់នោះមកប្រើប្រាស់។

ទ្រព្យសកម្មអរូបី ត្រូវបានធ្វើការរំលស់លើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វារយៈពេល 10ឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមពាក់ព័ន្ធនឹងការបង្កើត ឬថែទាំកម្មវិធីកុំព្យូទ័រសូហ្វវែរត្រូវបានទទួលស្គាល់ ជាចំណាយក្នុងរបាយការណ៍ចំណេញ ឬខាតនៅពេលកើតឡើង។

3.6 ទ្រព្យសម្បត្តិ និងបរិក្ខារ

គ្រប់សមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារទាំងអស់ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃដើម និងបន្ទាប់មកតាមតម្លៃដើមដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។ ថ្លៃដើមរបស់ទ្រព្យសម្បត្តិ និងបរិក្ខារដែលត្រូវបានទទួលស្គាល់ដំបូងរួមបញ្ចូលទាំងតម្លៃទិញចូលនៃទ្រព្យសម្បត្តិ និង ថ្លៃដើមពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការនាំយក ទ្រព្យសកម្មទៅកាន់ទីតាំង និងនៅក្នុងលក្ខខណ្ឌសមស្របសម្រាប់ការធ្វើប្រតិបត្តិការអាជីវកម្មតាមការកំណត់របស់ គណៈគ្រប់គ្រង។

ទ្រព្យសកម្ម ដែលស្ថិតនៅក្រោមការសាងសង់រួមមាន ទ្រព្យសម្បត្តិ និងបរិក្ខារ គឺមិនត្រូវបានធ្វើរំលស់នោះទេ ដោយសារតែទ្រព្យសកម្មទាំងនោះនៅមិនទាន់រួចរាល់សម្រាប់ការប្រើប្រាស់។

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានធ្វើការរំលស់តាមវិធីសាស្ត្ររំលស់ថេរ ដោយធ្វើការបែងចែកតាមតម្លៃដែលអាចរំលស់បានលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានដែលនៅសល់ដូចខាងក្រោម៖

	អាយុកាលប្រើប្រាស់
ការកែលម្អទ្រព្យជួល	20ឆ្នាំ
ម៉ាស៊ីនដក និងដាក់ប្រាក់ស្វ័យប្រវត្តិ	8ឆ្នាំ
យានយន្ត	5ឆ្នាំ
បរិក្ខារការិយាល័យ គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់	4ឆ្នាំ
កុំព្យូទ័រ និងបរិក្ខារព័ត៌មានវិទ្យា	4ឆ្នាំ

តម្លៃសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើ និយ័តកម្មតាមការសមស្រប នៅរៀងរាល់ចុងកាលបរិច្ឆេទរាយការណ៍នីមួយៗ។ ផលប៉ះពាល់នៃការកែតម្រូវ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតនៅពេលការផ្លាស់ប្តូរបានកើតមានឡើង។

3.7 ឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលបានរំលស់ ត្រូវបានកំណត់ឡើងវិញនៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានការចង្អុលបង្ហាញពីឱនភាពតម្លៃដែរ ឬទេ។ ប្រសិនបើមានការចង្អុលបង្ហាញបែបនេះ ទ្រព្យសកម្មត្រូវបានធ្វើឱនភាពតម្លៃ និងតម្លៃយោងនៃទ្រព្យសកម្ម (ឬឯកតាបង្កើតសាច់ប្រាក់ “CGU” ដែលទ្រព្យសកម្មត្រូវបានបែងចែក) ត្រូវបានធ្វើតេស្តឱនភាពតម្លៃ។

ការខាតបង់លើឱនភាពតម្លៃនឹងត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មធំជាងតម្លៃ ដែលអាចទទួលបានមកវិញបាន។ តម្លៃដែលអាចទទួលបានមកវិញបានគឺភាពធំជាងនៃតម្លៃសមស្របដកតម្លៃដែលត្រូវលក់ និងតម្លៃដែលត្រូវប្រើប្រាស់របស់ទ្រព្យសកម្ម (ឬ “CGU”)។ សម្រាប់គោលបំណងនៃការវាយតម្លៃឱនភាពតម្លៃទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុតដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលមានឱនភាពត្រូវតម្លៃបានត្រួតពិនិត្យ សម្រាប់ការកត់ត្រាបញ្ច្រាសដែលអាចមាននៅការិយបរិច្ឆេទនៃរាយការណ៍នីមួយៗ។

3.8 ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃសំវិធានធនរវាងឱនភាពតម្លៃនៃឥណទានដោយ អនុលោមតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនស្របតាមបទប្បញ្ញត្តិ ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំលេខ ធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។

យោងតាមប្រកាសនេះ ធនាគារគួរធ្វើការប្រៀបធៀបសំវិធានធនដែលបានគណនាដោយអនុលោមតាមតម្រូវការខាងលើ និងការកត់ត្រារបស់ធនាគារស្របតាម ស.រ.ទ.ហ.អ.ក ៖

ក. ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ទាបជាងសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក ធនាគារធ្វើ ការកត់ត្រាសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក និង

ខ. ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ខ្ពស់ជាងសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក ធនាគារធ្វើការកត់ត្រាសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក ហើយផ្ទេរតម្លៃដែលខុសគ្នា ពីចំណេញរក្សាទុក ឬខាតបង្គរ ទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងគណនីមូលធនរបស់ម្ចាស់ធនាគារក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនផ្នាល់សុទ្ធរបស់ធនាគារឡើយ។

3.9 ចំណូលការប្រាក់សុទ្ធ

ចំណូល និងចំណាយការប្រាក់ទាក់ទងនឹងឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាតបង់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព (EIR)។ EIR គឺជាអត្រាដែលធានានូវការបញ្ចុះតម្លៃនៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលបានប៉ាន់ស្មានតាមរយៈអាយុកាលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ការវាស់វែង EIR គួរតែរួមបញ្ចូលថ្លៃសេវា និងកម្រៃជើងសារទាំងអស់ដែលទទួលបាន ឬបានបង់ ប្រសិនបើចំនួនច្រើនដែលជាផ្នែកសំខាន់នៃ EIR នៃកិច្ចសន្យានិងថ្លៃដើមប្រតិបត្តិការ។

ចំណូលការប្រាក់ ត្រូវបានគណនាដោយអនុវត្តអត្រាការប្រាក់ប្រសិទ្ធិភាព ទៅនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមែនឱនភាពនៃតម្លៃ (ឧទាហរណ៍៖ លើថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុមុនពេលធ្វើការ កែសម្រួលលើការខាតបង់តណទានរំពឹងទុក) លើកលែងតែ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពតម្លៃតណទាន ឬបានទិញ (“POCI”) ដែល EIR កែតម្រូវតណទានត្រូវបានអនុវត្តចំពោះការរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមែនជា POCI ប៉ុន្តែក្រោយមកមានឱនភាពតម្លៃ (ឬដំណាក់កាលទី 3) ដែលចំណូលការប្រាក់ត្រូវបានគណនា ដោយអនុវត្ត EIR ចំពោះការរំលស់របស់ពួកគេ (ឧទាហរណ៍៖ តម្លៃយោងដុលដកការបាត់បង់តណទានរំពឹងទុក)។

ចំណាយការប្រាក់ ត្រូវបានទទួលស្គាល់ដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធិភាព ធៀបនឹងតម្លៃយោងដុលនៃបំណុលហិរញ្ញវត្ថុ។

3.10 សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយការធ្វើអប្បហារលើលំហូរសាច់ប្រាក់ដែលរំពឹងថា នឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌ ទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ អប្បហារដែលនៅសល់ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

3.11 កិច្ចសន្យាតណទានផ្សេងៗ

នៅក្នុងដំណើរការអាជីវកម្មធម្មតា ធនាគារបានចុះកិច្ចសន្យាតណទានផ្សេងៗ រួមមានកិច្ចសន្យាតណទាន លិខិតតណទាន និងការធានា។ គោលការណ៍គណនេយ្យ និងសំវិធានធនស្របតាមបទប្បញ្ញត្តិត្រូវបានអនុវត្តតាមប្រកាស លេខ ធ7-017-344 របស់ធនាគារជាតិនៃកម្ពុជា និងសារាចរលេខ ធ7-018-001 នៃកំណត់សម្គាល់ 3.8 ខាងលើ។

4. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាម ស.រ.ទ.ហ.អ.ក តម្រូវឱ្យប្រើការប៉ាន់ស្មាន និងការសន្មតគណនេយ្យជាក់លាក់មួយចំនួនដែលជះឥទ្ធិពលដល់ចំនួនទឹកប្រាក់ ដែលត្រូវបានរាយការណ៍នៃទ្រព្យសកម្ម និងបំណុល និងការបង្ហាញពីទ្រព្យសកម្ម និងបំណុលយថាហេតុនាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងទឹកប្រាក់ដែលត្រូវបានរាយការណ៍នៃចំណូល និងចំណាយក្នុងការិយបរិច្ឆេទរាយការណ៍។ ក្រុមប្រឹក្សាភិបាលក៏ត្រូវធ្វើការវិនិច្ឆ័យក្នុងការអនុវត្តគោលការណ៍គណនេយ្យនេះផងដែរ។ ទោះបីជាការប៉ាន់ស្មាន និងការវិនិច្ឆ័យ ដោយផ្អែកលើចំណេះដឹង និងព្រឹត្តិការណ៍នាពេលបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលក៏ដោយក៏លទ្ធផលជាក់ស្តែងអាចនឹងមានខុសគ្នា។

ផ្នែកសំខាន់នៃការប៉ាន់ស្មាន ភាពមិនច្បាស់លាស់ និងការវិនិច្ឆ័យសំខាន់ក្នុងការអនុវត្តតាមគោលការណ៍គណនេយ្យ ដែលមានផលប៉ះពាល់ជាសារវន្តក្នុងការកំណត់ចំនួន ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

4.1 ការវាស់វែងពន្ធលើប្រាក់ចំណូល

ការវិនិច្ឆ័យសំខាន់គឺ ចាំបាច់ក្នុងការកំណត់ការប៉ាន់ស្មានពន្ធក្នុងគ្រា និងពន្ធពន្យារ ព្រោះបំណុលពន្ធចុងក្រោយសម្រាប់ធនាគារមិនមានភាពច្បាស់លាស់។ នៅពេលដែលលទ្ធផលចុងក្រោយនៃពន្ធ ដែលត្រូវបានកំណត់ដោយអាជ្ញាធរពន្ធដារ ទឹកប្រាក់បង់ពន្ធនេះ អាចខុសគ្នាពីការប៉ាន់ស្មានដំបូងនៃប្រាក់ពន្ធដែលត្រូវបង់។ ចំនួនដែលខុសគ្នានោះ អាចមានផលប៉ះពាល់លើពន្ធក្នុងគ្រា និងពន្ធពន្យារ ក្នុងគ្រាដែលបានកំណត់។ ធនាគារនឹងធ្វើនិយ័តកម្មពន្ធក្នុងគ្រា ឬពន្ធពន្យារដែលពាក់ព័ន្ធនឹងឆ្នាំមុនក្នុងគ្រាបច្ចុប្បន្នលើភាពខុសគ្នាទាំងនោះ។

ចំណាយពន្ធលើប្រាក់ចំណូលរបស់ធនាគារ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 15 នៃរបាយការណ៍ហិរញ្ញវត្ថុ។

4.2 ការខាតបង់តណាទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមរំលស់

ការខាតបង់តណាទានរំពឹងទុក សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមរំលស់ តម្រូវឱ្យមានការប្រើប្រាស់គំរូស្មុគស្មាញ និងការសន្មតសំខាន់ៗ អំពីស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត និងលក្ខណៈតណាទាន(ឧទាហរណ៍៖ លទ្ធភាពអតិថិជនៃការខកខានបង់ និងការខាតបង់ជាលទ្ធផល)។

ការវិនិច្ឆ័យសំខាន់មួយចំនួនក៏ត្រូវបានតម្រូវនៅក្នុងការអនុវត្តតម្រូវការគណនេយ្យសម្រាប់ការវាស់វែង ECL ផងដែរ ដូចជា៖
- ការកំណត់លក្ខណៈវិនិច្ឆ័យចំពោះកំណើនហានិភ័យតណាទានជាសារវន្ត
- ជ្រើសរើសគំរូ និងការសន្មតសមស្រប សម្រាប់ការវាស់វែង ECL
- ការបង្កើតចំនួនសេណារីយ៉ូ និងការថ្លឹងពាក់ព័ន្ធសម្រាប់ពេលអនាគត ចំពោះប្រភេទនៃផលិតផល/ទីផ្សារនីមួយៗ និង ECL ដែលពាក់ព័ន្ធ
- ការបង្កើតក្រុមទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈស្រដៀងគ្នា ក្នុងគោលបំណងដើម្បីវាស់វែង ECL។

ផលប៉ះពាល់ទៅលើសំរិទ្ធានធនទៅលើតណាទានរបស់ធនាគារផ្តល់ដល់អតិថិជន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 8 នៃរបាយរាយណ៍ហិរញ្ញវត្ថុ។

5. សាច់ប្រាក់ក្នុងដៃ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ប្រាក់ដុល្លារអាមេរិក	58,712,340	235,612,620	63,341,482	254,949,465
ប្រាក់រៀល	538,949	2,162,802	703,640	2,832,151
ផ្សេងៗ	121,008	485,606	227,751	916,698
សរុប	**59,372,297**	**238,261,028**	**64,272,873**	**258,698,314**

6. សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ក្នុងព្រះរាជាណាចក្រកម្ពុជា៖				
ប្រាក់បញ្ញើមានកាលកំណត់	55,495,576	222,703,746	57,473,461	231,330,681
គណនីចរន្ត	1,469,933	5,898,841	6,879,407	27,689,613
គណនីសន្សំ	371,098	1,489,216	526,019	2,117,226
សរុប	**57,336,607**	**230,091,803**	**64,878,887**	**261,137,520**
ក្រៅព្រះរាជាណាចក្រកម្ពុជា៖				
គណនីចរន្ត	2,953,225	11,851,292	9,592,092	38,608,170
សមតុល្យដុលនៅគ្រឹះស្ថាន	60,289,832	241,943,095	74,470,979	299,745,690
បូក៖ បង្គរការប្រាក់ដែលត្រូវទទួលបាន	1,062,542	4,263,981	1,076,652	4,333,524
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុវាស់វែងតាមតម្លៃដើមរំលស់	61,352,374	246,207,076	75,547,631	304,079,214
ដក៖ សំវិធានធនសម្រាប់ការខាតបង់ឱនភាពតម្លៃ	(88,634)	(355,687)	(1,896)	(7,631)
សរុប	**61,263,740**	**245,851,389**	**75,545,735**	**304,071,583**

បម្រែបម្រួលនៃសំវិធានធនសម្រាប់ការខាតបង់ឱនភាពតម្លៃ មានដូចខាងក្រោម៖

	ECL រយៈពេល 12ខែ (ដំណាក់កាលទី 1)	
ក្នុងព្រះរាជាណាចក្រកម្ពុជា៖	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី1 ខែមករា ឆ្នាំ2024	(2,130)	(8,702)
ការវាស់វែងឡើងវិញនៃសំវិធានធនសុទ្ធ (កំណត់សម្គាល់ 24)	234	953
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	118
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024/ថ្ងៃទី1 ខែមករា ឆ្នាំ2025	**(1,896)**	**(7,631)**
ការវាស់វែងឡើងវិញនៃសំវិធានធនសុទ្ធ (កំណត់សម្គាល់ 24)	(86,738)	(347,906)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(150)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**(88,634)**	**(355,687)**

សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបានវិភាគដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ក. តាមកាលកំណត់៖				
ក្នុងអំឡុងពេល 1ខែ	4,794,256	19,239,349	16,997,518	68,415,010
លើសពី 1ខែ ទៅ 3ខែ	12,000,000	48,156,000	22,000,000	88,550,000
លើសពី 3ខែ ទៅ 12ខែ	43,495,576	174,547,746	35,473,461	142,780,680
	60,289,832	**241,943,095**	**74,470,979**	**299,745,690**
ខ. តាមរូបិយប័ណ្ណ៖				
ប្រាក់ដុល្លារអាមេរិក	59,866,832	240,245,597	70,587,581	284,115,014
ប្រាក់រៀល	207,696	833,484	3,533,001	14,220,329
ផ្សេងៗ	215,304	864,014	350,397	1,410,347
	60,289,832	**241,943,095**	**74,470,979**	**299,745,690**

គ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖

គណនីសន្សំ	0% ទៅ 1%	0% ទៅ 1%
បញ្ជើមានកាលកំណត់	1.5% ទៅ 6.75%	1.5% ទៅ 7.5%

7. សមតុល្យនៅធនាគារជាតិនៃកម្ពុជា (“NBC”)

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណនីចរន្ត	10,201,884	40,940,160	8,636,362	34,761,357
មូលបត្រអាចជួញដូរបាន (“NCD”)	549,838	2,206,500	374,534	1,507,499
បង្គរការប្រាក់ដែលត្រូវទទួលបាន	296	1,188	161	648
	10,752,018	**43,147,848**	**9,011,057**	**36,269,504**

នៅក្នុងអំឡុងការិយបរិច្ឆេទ ធនាគារបានដាក់មូលបត្រអាចជួញដូរបាន ដែលមានទឹកប្រាក់ចំនួន 549,838ដុល្លារ អាមេរិក (2024៖ 374,534ដុល្លារអាមេរិក) ជាមួយធនាគារជាតិនៃកម្ពុជា ជាទ្រព្យបញ្ចាំសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(“LPCO”)។ មូលបត្រអាចជួញដូរបានមានកាលកំណត់រយៈពេល 3ខែ និងទទួលបានការប្រាក់ក្នុងអត្រាចាប់ពី 0.30% ទៅ 1.00% (2024៖ 1.05% ទៅ 1.33%) ក្នុងមួយឆ្នាំ។

8. តណទានផ្តល់ដល់អតិថិជន - សុទ្ធ

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ដំណាក់កាលទី 1	67,687,838	271,631,294	75,852,564	305,306,570
ដំណាក់កាលទី 2	2,616,272	10,499,100	1,131,760	4,555,334
ដំណាក់កាលទី 3	8,242,155	33,075,768	4,838,869	19,476,448
តណទានដុលផ្តល់ដល់អតិថិជន	**78,546,265**	**315,206,162**	**81,823,193**	**329,338,352**
បូក៖ បង្គរការប្រាក់ដែលត្រូវទទួលបាន	1,865,020	7,484,325	1,204,720	4,848,998
តណទានផ្តល់ដល់អតិថិជនរាស់វែង តាមរំលស់ថ្លៃដើម	80,411,285	322,690,487	83,027,913	334,187,350
ដក៖ សំវិធានធនសម្រាប់ការខាតបង់ ឱនភាពតម្លៃ	(3,186,714)	(12,788,284)	(2,295,207)	(9,238,208)
តណទានផ្តល់ដល់អតិថិជនសុទ្ធ	**77,224,571**	**309,902,203**	**80,732,706**	**324,949,142**

ការផ្ទៀងផ្ទាត់បង្គរការប្រាក់ដែលត្រូវទទួលបាន មានដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី1 ខែមករា	1,204,720	4,848,998	580,494	2,371,318
បូក៖ ចំណូលការប្រាក់ (កំណត់សម្គាល់ 18)	7,781,990	31,213,562	7,894,328	32,137,809
ដក៖ ការប្រាក់ដែលទទួលបាន	(7,121,690)	(28,565,099)	(7,270,102)	(29,596,585)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(13,136)	-	(63,544)
នាថ្ងៃទី31 ខែធ្នូ	**1,865,020**	**7,484,325**	**1,204,720**	**4,848,998**

បម្រែបម្រួលនៃសំវិធានធនសម្រាប់ការខាតឱនភាពតម្លៃនៃតណទានផ្តល់ដល់អតិថិជនមានដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី1 ខែមករា	2,295,207	9,238,208	2,691,392	10,978,692
សំវិធានធន/(ការកត់ត្រាបញ្ច្រាស់) អំឡុងការិយបរិច្ឆេទ (កំណត់សម្គាល់ 24)	891,507	3,575,835	(396,185)	(1,612,869)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(25,759)	-	(127,615)
នាថ្ងៃទី31 ខែធ្នូ	**3,186,714**	**12,788,284**	**2,295,207**	**9,238,208**

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ក. តាមសម្ព័ន្ធភាព៖				
អតិថិជនខាងក្រៅ	77,938,778	312,768,316	80,979,320	325,941,763
ឥណទានបុគ្គលិក	607,487	2,437,846	843,873	3,396,589
	78,546,265	**315,206,162**	**81,823,193**	**329,338,352**
ខ. តាមកាលកំណត់៖				
1 ទៅ 3ខែ	11,259,467	45,184,241	24,111,662	97,049,440
3 ទៅ 6ខែ	1,071,373	4,299,420	375,840	1,512,756
6 ទៅ 12ខែ	5,996,127	24,062,458	10,997,028	44,263,038
1 ទៅ 3ឆ្នាំ	29,039,583	116,535,847	19,410,090	78,125,612
3 ទៅ 5ឆ្នាំ	2,220,614	8,911,324	2,218,248	8,928,448
លើសពី 5ឆ្នាំ	28,959,101	116,212,872	24,710,325	99,459,058
	78,546,265	**315,206,162**	**81,823,193**	**329,338,352**
គ. តាមស្ថានភាពឥណទាន៖				
ដំណើរការធម្មតា	67,283,484	270,008,621	75,056,601	302,102,819
ក្រោមដំណើរការ	2,657,747	10,665,539	1,244,565	5,009,374
មិនដំណើរការ	8,605,034	34,532,002	5,522,027	22,226,159
	78,546,265	**315,206,162**	**81,823,193**	**329,338,352**
ឃ. តាមឥណទានមានការធានា៖				
	ដុល្លារអាមេរិក	ភាគរយ (%)	ដុល្លារអាមេរិក	ភាគរយ (%)
មានការធានា	77,306,515	98.42	80,732,395	98.67
មិនមានការធានា	1,239,750	1.58	1,090,798	1.33
	78,546,265	**100**	**81,823,193**	**100**

ឥណទានមានការធានាត្រូវមានទ្រព្យបញ្ចាំដោយទ្រព្យសម្បត្តិពិត ដូចជាដី អគារដែលមានប្លង់រឹង ឬប្លង់ទន់។ ប្លង់ទន់ មិនត្រូវបានចេញដោយក្រសួងដែនដីនោះទេ។

សម្រាប់ការវិភាគបន្ថែមពីឥណទានផ្តល់ដល់អតិថិជន សូមមើលកំណត់សម្គាល់ 27 (ខ)។

9. ការវិនិយោគ

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មូលបត្របំណុល (ប័ណ្ណបំណុលរដ្ឋាភិបាល)	2,990,282	12,000,000	-	-
ក្រុមហ៊ុនបុត្រសម្ព័ន្ធ	1,800,000	7,223,400	1,800,000	7,245,000
ការវិនិយោគក្នុងមូលប័ត្រកម្មសិទ្ធ	25,588	102,685	25,588	102,992
	4,815,870	**19,326,085**	**1,825,588**	**7,347,992**
បូក៖ បង្គរការប្រាក់ដែលត្រូវទទួលបាន	53,879	216,216	-	-
ដក៖ សំវិធានធនសម្រាប់ការខាតបង់ឱនភាពតម្លៃ	(312,659)	(1,254,699)	(300,874)	(1,211,018)
	4,557,090	**18,287,602**	**1,524,714**	**6,136,974**

បម្រៃបម្រួលនៃសំវិធានធនសម្រាប់ការខាតបង់ឱនភាពតម្លៃលើការវិនិយោគ មានដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី1 ខែមករា	300,874	1,211,018	-	-
សំវិធានធនក្នុងអំឡុងការិយបរិច្ឆេទ (កំណត់សម្គាល់ 24)	11,785	47,269	300,874	1,224,858
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(3,588)	-	(13,840)
នាថ្ងៃទី31 ខែធ្នូ	**312,659**	**1,254,699**	**300,874**	**1,211,018**

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ធនាគារមានការវិនិយោគទៅលើមូលបត្របំណុលរដ្ឋាភិបាល ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។ ការវិនិយោគនេះ រួមមានប័ណ្ណបំណុលរដ្ឋាភិបាលដែលមានអត្រាថេរ ដោយមានតម្លៃចារឹក 12,000,000,000រៀល (សមមូលនឹង 2,990,282ដុល្លារអាមេរិក) ហើយទទួលបានការប្រាក់តាមអត្រា 3.50% ក្នុងមួយឆ្នាំ និងត្រូវទូទាត់សងវិញរៀងរាល់ឆមាស។ មូលបត្របំណុលនេះនឹងដល់កាលកំណត់នៅថ្ងៃទី27 ខែមិថុនា ឆ្នាំ2028។

ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺតំណាងឱ្យ 100% នៃការវិនិយោគមូលធននៅក្នុងក្រុមហ៊ុន ខេប ស៊ីឃ្យូរីធី លីមីធីត ដែលសកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺទាក់ទងទៅនឹងអាជីវកម្មឈ្មួញជើងសារមូលបត្រ។ ក្រុមហ៊ុន ខេប ស៊ីឃ្យូរីធី លីមីធីត ទទួលបានអាជ្ញាប័ណ្ណពីនិយ័តករមូលបត្រកម្ពុជា (“ន.ម.ក”)។ ក្នុងឆ្នាំ2024 ធនាគារបានធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រដើម្បីបញ្ឈប់ប្រតិបត្តិការរបស់ក្រុមហ៊ុន ខេប ស៊ីឃ្យូរីធី លីមីធីត។ ហេតុដូច្នេះ ធនាគារបានផ្តួចផ្តើមទូបង្កើតវិនិធីចាំបាច់ដើម្បីរំសាយក្រុមហ៊ុនបុត្រសម្ព័ន្ធ រួមទាំងការជូនដំណឹងដែលស្របតាមបទប្បញ្ញត្តិ ការទូទាត់កាតព្វកិច្ចដែលនៅសេសសល់ និងការបំពេញតម្រូវការផ្នែកច្បាប់ និងហិរញ្ញវត្ថុ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុនបុត្រសម្ព័ន្ធបានទទួលការអនុម័តពី ន.ម.ក រួចហើយ ប៉ុន្តែនៅរង់ចាំការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារ (“អ.ព.ដ”) និងក្រសួងពាណិជ្ជកម្ម (“ព.ណ”)។

ការវិនិយោគក្នុងមូលធន គឺតំណាងឱ្យ 1% នៃការវិនិយោគមូលធននៅក្នុងក្រុមហ៊ុន ក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី ដើម្បីបង្កើតការិយាល័យតំណាងឯកជននៅកម្ពុជា។ ធនាគារចាត់ទុកការវិនិយោគនេះ តាមមូលបត្រភាគហ៊ុនដោយតម្លៃសមស្របតាមលទ្ធផលលម្អិតផ្សេងៗ។

10. ទ្រព្យសកម្មផ្សេងៗ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
គណនីកាតតំណាងត្រូវទទួល	804,733	3,229,394	1,941,064	7,812,782
បុរេប្រទានទូទាត់	672,397	2,698,329	1,040,307	4,187,236
ចំណាយបង់មុន	529,488	2,124,835	451,285	1,816,422
ប្រាក់កក់សម្រាប់ការជួល	364,370	1,462,217	392,870	1,581,302
ផ្ទេរចូលតាមរ៉ែស្ទឺនយូញ៉ៀន	153,222	614,880	49,980	201,170
គណនីត្រូវទទួលផ្សេងៗ	101,065	405,574	116,004	466,916
	2,625,275	**10,535,229**	**3,991,510**	**16,065,828**

11. ប្រាក់តម្កល់តាមបទប្បញ្ញត្តិ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់ ដុល្លារអាមេរិក	13,540,000	54,336,020	12,000,000	48,300,000
ប្រាក់តម្កល់ធានាដើមទុន	7,500,000	30,097,500	7,500,000	30,187,500
ទុនបបម្រុងកាតព្វកិច្ចជាប្រាក់រៀល	257,413	1,032,998	99,379	400,000
បង្គរការប្រាក់ដែលត្រូវទទួលបាន	-	-	49,393	198,807
	21,297,413	**85,466,518**	**19,648,772**	**79,086,307**

ទុនបម្រុងកាតព្វកិច្ច ត្រូវបានតម្រូវដោយ NBC យោងតាមប្រកាស លេខ ធ7-023-005 ចុះថ្ងៃទី9 ខែមករា ឆ្នាំ2023 ដែលតម្រូវឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវរក្សាទុនបម្រុងកាតព្វកិច្ចតាមកាលបរិច្ឆេទ និងអត្រាដូចខាងក្រោម៖

- ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2023 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ទុនបម្រុងកាតព្វកិច្ចជារូបិយបណ្ណបរទេសត្រូវរក្សា តាមអត្រា 9%។
- ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2024 តទៅ ប្រាទុនបម្រុងកាតព្វកិច្ចជារូបិយបណ្ណបរទេសត្រូវរក្សាតាមអត្រា 12.5%។
- គ្រប់គ្រឹះស្ថានហិរញ្ញវត្ថុត្រូវរក្សាទុនបម្រុងកាតព្វកិច្ចជារូបិយវត្ថុជាតិ (ខ្មែររៀល) តាមអត្រា 7%។

ប៉ុន្តែ ដោយយោងតាមលិខិតលេខ ធ7-023-2621 ចុះថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2023 ចែងថា ទុនបម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសត្រូវប្តូរមកនៅត្រឹមអត្រា 7% រហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។ បន្ទប់មកទុនបម្រុងកាតព្វកិច្ចត្រូវបានតម្រូវដោយធនាគារជាតិនៃកម្ពុជា យោងតាមប្រកាស លេខ ធ7-024-1718 ចុះថ្ងៃទី21 ខែសីហា ឆ្នាំ2024 ដែលតម្រូវឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវរក្សាទុកទុនបម្រុងកាតព្វកិច្ចតាមអត្រា 7% រហូតដល់ថ្ងៃ31 ខែធ្នូ ឆ្នាំ2025។

ប្រាក់តម្កល់ធានាដើមទុនត្រូវបានតម្រូវដោយ NBC យោងតាមប្រកាស ធ7-01-136 ចុះថ្ងៃទី15 ខែតុលា ឆ្នាំ2001 ដែលតម្រូវឱ្យធនាគាររក្សាប្រាក់តម្កល់តាមបទប្បញ្ញត្តិស្មើនឹង 10% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះ មិនអាច យកមកប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារនោះទេ ប៉ុន្តែអាចទទួលបានវិញនៅពេលដែលធនាគារបញ្ឈប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដោយស្ម័គ្រចិត្ត។ ប្រាក់តម្កល់ធានាដើមទុនទទួលបានការប្រាក់ក្នុងអត្រា 0.08% ទៅ 1.33% ក្នុងមួយឆ្នាំ។

12. ទ្រព្យសកម្មអរូបី

	អាជ្ញាប័ណ្ណកម្មវិធី ដុល្លារអាមេរិក	ទ្រព្យកំពុងបង្កើត ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	ពាន់រៀល
2025				
ថ្លៃដើម				
នាថ្ងៃទី1 ខែមករា ឆ្នាំ2025	1,541,595	908,993	2,450,588	9,863,617
ការទិញបន្ថែម	1,237	205,023	206,260	827,309
ការផ្ទេរ	843,518	(843,518)	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(28,995)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**2,386,350**	**270,498**	**2,656,848**	**10,661,931**
រំលស់បង្គរ				
នាថ្ងៃទី1 ខែមករា ឆ្នាំ2025	481,952	-	481,952	1,939,857
ចំណាយរំលស់ (កំណត់សម្គាល់ 23)	225,885	-	225,885	906,024
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(5,331)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**707,837**	**-**	**707,837**	**2,840,550**
តម្លៃយោង				
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**1,678,513**	**270,498**	**1,949,011**	**7,821,381**

	អាជ្ញាប័ណ្ណកម្មវិធី ដុល្លារអាមេរិក	ទ្រព្យកំពុងបង្កើត ដុល្លារអាមេរិក	សរុប	
			ដុល្លារអាមេរិក	៣ន់រៀល (ដែលបានចាត់ថ្នាក់ឡើងវិញ- កំណត់សម្គាល់ 31)
2024				
ថ្លៃដើម				
នាថ្ងៃទី1 ខែមករា ឆ្នាំ2024	1,532,207	598,366	2,130,573	8,703,391
ការទិញបន្ថែម	9,388	310,627	320,015	1,302,781
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(142,555)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	**1,541,595**	**908,993**	**2,450,588**	**9,863,617**
រំលស់បង្គរ				
នាថ្ងៃទី1 ខែមករា ឆ្នាំ2024	333,843	-	333,843	1,363,749
ចំណាយរំលស់ (កំណត់សម្គាល់ 23)	148,109	-	148,109	602,951
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(26,843)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	**481,952**	**-**	**481,952**	**1,939,857**
តម្លៃយោង				
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	**1,059,643**	**908,993**	**1,968,636**	**7,923,760**

13. ទ្រព្យសម្បត្តិ និងបរិក្ខារ

	កុំព្យូទ័រ និងបរិក្ខារ ព័ត៌មានវិទ្យា ដុល្លារអាមេរិក	បរិក្ខារការិយាល័យ, គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ ដុល្លារអាមេរិក	ម៉ាស៊ីនដក និងដាក់ ប្រាក់ស្វ័យប្រវត្តិ ដុល្លារអាមេរិក	យានយន្ត ដុល្លារអាមេរិក	ការកែលម្អ ទ្រព្យជួស ដុល្លារអាមេរិក	ទ្រព្យ កំពុងបង្កើត ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	៣ន់រៀល
2025								
ថ្លៃដើម								
នាថ្ងៃទី1 ខែមករា ឆ្នាំ2025	733,947	314,363	673,984	275,400	257,644	49,121	2,304,459	9,275,447
ការទិញបន្ថែម	1,942	27,026	-	-	-	103,217	132,185	530,194
ការផ្ទេរ	76,725	-	29,920	-	1,829	(108,474)	-	-
ការលុបចេញពីបញ្ជី	(45,602)	(23,037)	-	-	-	-	(68,639)	(275,311)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(27,526)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**767,012**	**318,352**	**703,904**	**275,400**	**259,473**	**43,864**	**2,368,005**	**9,502,804**
រំលស់បង្គរ								
នាថ្ងៃទី1 ខែមករា ឆ្នាំ2025	568,630	271,889	548,536	164,070	28,182	-	1,581,307	6,364,760
រំលស់ (កំណត់សម្គាល់ 23)	137,304	28,355	51,926	27,230	12,884	-	257,699	1,033,631
ការលុបចេញពីបញ្ជី	(45,595)	(22,921)	-	-	-	-	(68,516)	(274,818)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(18,597)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**660,339**	**277,323**	**600,462**	**191,300**	**41,066**	**-**	**1,770,490**	**7,104,976**
តម្លៃយោង								
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**106,673**	**41,029**	**103,442**	**84,100**	**218,407**	**43,864**	**597,515**	**2,397,828**

	កុំព្យូទ័រ និងបរិក្ខារ ព័ត៌មានវិទ្យា	បរិក្ខារការិយាល័យ, គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់	ម៉ាស៊ីនដក និងដាក់ ប្រាក់ស្វ័យប្រវត្តិ	យានយន្ត	ការកែលម្អ ទ្រព្យជួស	ទ្រព្យ កំពុងបង្កើត	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	៣ន់រៀល
2024								
ថ្លៃដើម								
នាថ្ងៃទី1 ខែមករា ឆ្នាំ2024	713,386	310,570	673,984	189,250	329,347	36,560	2,253,097	9,203,901
ការទិញបន្ថែម	24,698	10,731	-	86,150	-	12,561	134,140	546,084
ការលុបចេញពីបញ្ជី	(4,137)	(6,938)	-	-	(71,703)	-	(82,778)	(336,989)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(137,549)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	**733,947**	**314,363**	**673,984**	**275,400**	**257,644**	**49,121**	**2,304,459**	**9,275,447**
រំលស់បង្គរ								
នាថ្ងៃទី1 ខែមករា ឆ្នាំ2024	434,835	248,990	480,989	133,093	20,663	-	1,318,570	5,386,358
រំលស់ (កំណត់សម្គាល់ 23)	137,872	29,751	67,547	30,977	15,571	-	281,718	1,146,874
ការលុបចេញពីបញ្ជី	(4,077)	(6,852)	-	-	(8,052)	-	(18,981)	(77,272)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(91,200)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	**568,630**	**271,889**	**548,536**	**164,070**	**28,182**	**-**	**1,581,307**	**6,364,760**
តម្លៃយោង								
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	**165,317**	**42,474**	**125,448**	**111,330**	**229,462**	**49,121**	**723,152**	**2,910,687**

14. ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
អតិថិជន៖				
គណនីចរន្ត	26,316,800	105,609,318	25,988,621	104,604,200
គណនីសន្សំ	10,741,755	43,106,663	8,495,442	34,194,154
ប្រាក់បញ្ញើមានកាលកំណត់	102,689,037	412,091,105	107,053,449	430,890,132
	139,747,592	**560,807,086**	**141,537,512**	**569,688,486**
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងសាជីវកម្ម៖				
គណនីចរន្ត	183,244	735,358	293,291	1,180,496
គណនីសន្សំ	-	-	9	36
បញ្ញើមានកាលកំណត់	10,000,000	40,130,000	22,631,366	91,091,248
	10,183,244	**40,865,358**	**22,924,666**	**92,271,780**
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុដុល	149,930,836	601,672,444	164,462,178	661,960,266
បូក៖ បង្គរការប្រាក់ដែលត្រូវបង់	5,702,526	22,884,238	5,685,787	22,885,293
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុសុទ្ធ	**155,633,362**	**624,556,682**	**170,147,965**	**684,845,559**

ការផ្លៀងផ្ទាត់នៃបង្គរការប្រាក់ដែលត្រូវបង់ មានដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
នាថ្ងៃទី1 ខែមករា	5,685,787	22,885,293	3,005,663	12,278,133
បូក៖ ចំណាយការប្រាក់ (កំណត់សម្គាល់ 19)	9,206,222	36,926,156	8,155,179	33,199,734
ដក៖ ការប្រាក់ដែលបានបង់	(9,189,483)	(36,859,016)	(5,475,055)	(22,288,949)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(68,195)	-	(303,625)
នាថ្ងៃទី31 ខែធ្នូ	**5,702,526**	**22,884,238**	**5,685,787**	**22,885,293**

ប្រាក់បញ្ញើដុលពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបានវិភាគដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ក. តាមកាលកំណត់៖				
ក្នុងអំឡុងពេល 1ខែ	46,107,000	185,027,391	46,433,209	186,893,666
ពី 1ខែទៅ 3ខែ	14,985,589	60,137,169	8,861,585	35,667,880
ពី 3ខែទៅ 12ខែ	47,521,919	190,705,461	55,600,910	223,793,663
ពី 1ឆ្នាំទៅ 2ឆ្នាំ	18,884,849	75,784,899	29,234,982	117,670,802
លើសពី 2ឆ្នាំ	22,431,479	90,017,524	24,331,492	97,934,255
	149,930,836	**601,672,444**	**164,462,178**	**661,960,266**
ខ. តាមរូបិយប័ណ្ណ៖				
ប្រាក់ដុល្លារអាមេរិក	146,330,093	587,222,663	158,654,553	638,584,576
ប្រាក់រៀល	3,600,743	14,449,781	5,807,625	23,375,690
	149,930,836	**601,672,444**	**164,462,178**	**661,960,266**
គ.តាមសម្ព័ន្ធភាព៖				
ភាគីពាក់ព័ន្ធ	1,240,651	4,978,732	1,252,448	5,041,101
មិនមែនភាគីពាក់ព័ន្ធ	148,690,185	596,693,712	163,209,730	656,919,165
	149,930,836	**601,672,444**	**164,462,178**	**661,960,266**
ឃ.តាមនិវាសនដ្ឋាន៖				
និវាសនជន	148,540,610	596,093,468	164,209,276	660,942,336
អនិវាសនជន	1,390,226	5,578,976	252,902	1,017,930
	149,930,836	**601,672,444**	**164,462,178**	**661,960,266**

15. ពន្ធលើប្រាក់ចំណូល

(ក) ចំណាយពន្ធលើប្រាក់ចំណូល/ពន្ធអប្បបរមា

ដោយអនុលោមតាមច្បាប់ស្តីពីសារពើពន្ធនៃប្រទេសកម្ពុជា ធនាគារមានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណូលតាមអត្រា 20% នៃប្រាក់ចំណូលដែលជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាតាមអត្រា 1% នៃចំណូលដុលដោយយកតម្លៃណាមួយដែលខ្ពស់ជាង។

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ចំណាយពន្ធអប្បបរមា	163,812	657,050	146,802	590,878
ពន្ធពន្យារ	-	-	252,478	1,027,838
ចំណាយពន្ធលើប្រាក់ចំណូល	-	-	252,478	1,027,838

ការផ្សៀងផ្គាត់ពន្ធលើប្រាក់ចំណូលដែលត្រូវបានគណនាតាមអត្រាពន្ធផ្លូវការ ធៀបនឹងចំណាយពន្ធលើប្រាក់ចំណូល របស់ធនាគារមានដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ខាតមុនបង់ពន្ធ	(2,637,336)	(10,578,355)	(2,230,269)	(9,072,671)
ពន្ធដែលបានគណនាតាមអត្រាពន្ធ 20%	(527,467)	(2,115,670)	(446,054)	(1,815,886)
ផលប៉ះពាល់ពីភាពលម្អៀងបណ្តោះអាសន្ន និងអចិន្ត្រៃយ៍	(90,131)	(361,516)	(50,827)	(206,917)
ពន្ធពន្យារដែលបានមិនបានទទួលស្គាល់ សម្រាប់ការខាតបង់ពន្ធក្នុងការិយបរិច្ឆេទ	617,598	2,477,186	496,881	2,022,803
សំវិធានធនខ្ជះនៃពន្ធពន្យារ	-	-	252,478	1,027,838
ចំណាយពន្ធលើប្រាក់ចំណូល	-	-	252,478	1,027,838

(ខ) បំណុលពន្ធពន្យារ - សុទ្ធ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ទ្រព្យសកម្មពន្ធពន្យារ	192,282	771,628	192,282	773,935
បំណុលពន្ធពន្យារ	(564,656)	(2,265,965)	(564,656)	(2,272,740)
បំណុលពន្ធពន្យារ - សុទ្ធ	**(372,374)**	**(1,494,337)**	**(372,374)**	**(1,498,805)**

ពន្ធពន្យាររួមមានគណនីដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	**ពាន់រៀល**	**ដុល្លារអាមេរិក**	**ពាន់រៀល**
បំណុលពន្ធពន្យារ៖				
សំវិធានធនសម្រាប់ការខាតបង់ ឥនភាពតម្លៃ	(422,814)	(1,696,753)	(422,814)	(1,701,825)
សិទ្ធប្រើប្រាស់លើទ្រព្យសកម្ម	(125,221)	(502,512)	(125,221)	(504,015)
រំលស់	(16,621)	(66,700)	(16,621)	(66,900)
	(564,656)	**(2,265,965)**	**(564,656)**	**(2,272,740)**
ទ្រព្យសកម្មពន្ធពន្យារ៖				
បំណុលភតិសន្យា	132,107	530,145	132,107	531,731
ឥនភាពតម្លៃលើការវិនិយោគ	60,175	241,483	60,175	242,204
	192,282	771,628	192,282	773,935
បំណុលពន្ធពន្យារ - សុទ្ធ	**(372,374)**	**(1,494,337)**	**(372,374)**	**(1,498,805)**

បម្រែបម្រួលនៃបំណុលពន្ធពន្យារសុទ្ធ មានដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	**ពាន់រៀល**	**ដុល្លារអាមេរិក**	**ពាន់រៀល**
នាថ្ងៃទី1 ខែមករា	(372,374)	(1,498,805)	(119,896)	(489,775)
ទទួលស្គាល់ក្នុងរបាយការណ៍ ចំណេញ ឬខាត	-	-	(252,478)	(1,027,838)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	4,468	-	18,808
នាថ្ងៃទី31 ខែធ្នូ	**(372,374)**	**(1,494,337)**	**(372,374)**	**(1,498,805)**

ធនាគារមិនបានទទួលស្គាល់បម្រែបម្រួលនៃបំណុលពន្ធពន្យារក្នុងអំឡុងការិយបរិច្ឆេទនេះទេ ដោយសារធនាគារបានពិចារណាថា ចំនួនទឹកប្រាក់មិនមានភាពសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុ។

16. ដើមទុន

	2025 និង 2024	
ភាគហ៊ុនធម្មតា បានបោះផ្សាយ និងបានបង់គ្រប់ចំនួន៖	ដុល្លារអាមេរិក	៣ន់រៀល
នាថ្ងៃទី1 ខែមករា/ថ្ងៃទី31 ខែធ្នូ	75,000,000	299,625,000

ព័ត៌មានលម្អិតនៃរចនាសម្ព័ន្ធរបស់ភាគទុនិកមានដូចខាងក្រោម៖

	ដើមទុនដែលបានចុះបញ្ជី និងអនុម័តចេញផ្សាយដែលមានតម្លៃចរឹក 100ដុល្លារអាមេរិក ក្នុង 1ភាគហ៊ុន ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និង ឆ្នាំ2024		
ភាគទុនិក	ចំនួនភាគហ៊ុន	ចំនួនទឹកប្រាក់ដុល្លារអាមេរិក	%
Selvione Limited	450,000	45,000,000	60
Quantum Symbol Sdn Bhd	300,000	30,000,000	40
	750,000	75,000,000	100

17. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិសំដៅលើភាពខុសគ្នារវាងសំវិធានធនលើឱនភាពតម្លៃស្របតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
នាថ្ងៃទី1 ខែមករា	4,593,088	18,487,179	2,160,910	8,869,042
ផ្ទេរចេញពីចំណេញរក្សាទុក	1,042,324	4,180,762	2,432,178	9,901,397
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(53,033)	-	(283,260)
នាថ្ងៃទី31 ខែធ្នូ	5,635,412	22,614,908	4,593,088	18,487,179

ការផ្ទេរពីចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ គឺពាក់ព័ន្ធទៅនឹងសំវិធានធនលើឱនភាពតម្លៃក្នុងអំឡុងការិយបរិច្ឆេទ នៅពេលដែលសំវិធានធនត្រូវបានតម្រូវដោយធនាគារជាតិនៃកម្ពុជា ខ្ពស់ជាង ស.រ.ទ.ហ.អ.ក។

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ឱនភាពតម្លៃលើតណទានតម្រូវដោយធនាគារជាតិនៃកម្ពុជា	8,910,875	35,759,341	6,890,191	27,733,019
ការខាតបង់ឱនភាពតម្លៃលើឧបករណ៍ហិរញ្ញវត្ថុតាម ស.រ.ទ.ហ.អ.ក	(3,275,463)	(13,144,433)	(2,297,103)	(9,245,840)
នាថ្ងៃទី31 ខែធ្នូ	**5,635,412**	**22,614,908**	**4,593,088**	**18,487,179**
នាថ្ងៃទី1 ខែមករា	4,593,088	18,487,179	2,160,910	8,869,042
ផ្ទេរពីប្រាក់ចំណេញរក្សាទុក	1,042,324	4,180,762	2,432,178	9,901,397

យោងតាមប្រការ 73 នៃប្រកាសលេខ ធ7-017-344 ប្រ.ក ស្តីពីចំណាត់ថ្នាក់ហានិភ័យតណទាន និងសំវិធានធន លើឱនភាពតម្លៃក្នុងករណីដែលកម្រិតសំវិធានធនដែលគណនាស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាស ខ្ពស់ជាងកម្រិតសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក នោះធនាគារត្រូវកត់ត្រាសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក ហើយត្រូវផ្ទេរចំនួនខុសគ្នា ពីចំណេញរក្សាទុក ឬខាតបង្គរទៅទុនបម្រុងស្របតាមបទប្បញ្ញត្តិនៅក្នុងគណនីមូលធនរបស់ម្ចាស់ធនាគារក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

18. ចំណូលការប្រាក់

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
តណទានផ្តល់ដល់អតិថិជន (កំណត់សម្គាល់ 8)	7,781,990	31,213,562	7,894,328	32,137,809
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	3,869,082	15,518,888	2,843,220	11,574,749
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	89,840	360,348	107,081	435,927
មូលបត្របំណុល (ប័ណ្ណបំណុលរដ្ឋាភិបាល)	53,874	216,089	-	-
	11,794,786	**47,308,887**	**10,844,629**	**44,148,485**

19. ចំណាយការប្រាក់

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា (កំណត់សម្គាល់ 14)	9,206,222	36,926,156	8,155,179	33,199,734
បំណុលភតិសន្យា	58,213	233,493	49,245	200,476
	9,264,435	**37,159,649**	**8,204,424**	**33,400,210**

20. ចំណូលមិនមែនជាការប្រាក់ - សុទ្ធ

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលមិនមែនជាការប្រាក់				
ចំណូលពីកម្រៃ និងជើងសារ	1,724,978	6,918,887	1,944,842	7,917,453
ចំណេញពីការប្តូររូបិយប័ណ្ណបរទេស	1,470,086	5,896,515	1,849,880	7,530,862
ការទទួលបានមកវិញនូវតណទាន ដែលបានលុបចោលពីមុន	1,007,992	4,043,056	-	-
ចំណូលពីភាគលាភ	49,173	197,233	48,179	196,137
ចំណូលផ្សេងៗ	408,040	1,636,648	651,962	2,654,136
	4,660,269	**18,692,339**	**4,494,863**	**18,298,588**
ចំណាយមិនមែនជាការប្រាក់				
ចំណាយពីកម្រៃ និងជើងសារ	(1,001,188)	(4,015,765)	(915,024)	(3,725,063)
ចំណាយផ្សេងៗ	(468,792)	(1,880,325)	(411,561)	(1,675,465)
	(1,469,980)	(5,896,090)	(1,326,585)	(5,400,528)
ចំណូលមិនមែនជាការប្រាក់ - សុទ្ធ	**3,190,289**	**12,796,249**	**3,168,278**	**12,898,060**

ចំណូលពីកម្រៃ និងជើងសារក្នុងអំឡុងការិយបរិច្ឆេទ រាប់បញ្ចូលទាំងចំណូលដែលទទួលបានពីបញ្ជូរអាកាសយានដ្ឋានថ្មីខេត្តសៀមរាប មានចំនួន 255,876ដុល្លារអាមេរិក (2024៖ 304,785ដុល្លារអាមេរិក)។

21. ចំណាយលើបុគ្គលិក

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណាយប្រាក់បៀវត្ស និងប្រាក់ឈ្នួល	3,192,849	12,806,517	3,286,755	13,380,380
ចំណាយអត្ថប្រយោជន៍បុគ្គលិកផ្សេងៗ	507,205	2,034,400	516,199	2,101,446
	3,700,054	**14,840,917**	**3,802,954**	**15,481,826**

22. ចំណាយប្រតិបត្តិការផ្សេងៗ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ចំណាយកម្រៃសួយសារ	498,502	1,999,492	1,022,381	4,162,113
ចំណាយកម្រៃអាជ្ញាប័ណ្ណ និងប័ណ្ណប៉ាតង់	401,648	1,611,010	405,242	1,649,740
ចំណាយជួសជុល និងថែទាំ	381,946	1,531,985	383,000	1,559,193
ចំណាយលើការជួល	308,881	1,238,922	392,699	1,598,678
ចំណាយទីផ្សារ និងការផ្សព្វផ្សាយ	224,053	898,677	248,165	1,010,280
ចំណាយសម្ភារៈការិយាល័យ	133,212	534,313	150,167	611,330
ចំណាយថ្លៃទឹកភ្លើង	132,940	533,222	136,025	553,758
ចំណាយលើទំនាក់ទំនង	85,915	344,605	91,401	372,093
ចំណាយកម្រៃរបស់ក្រុមប្រឹក្សាភិបាល	52,895	212,162	53,470	217,676
ចំណាយបុគ្គលិកផ្សេងៗ	41,359	165,891	59,378	241,728
ចំណាយលើការប្រើប្រាស់យានយន្ត	34,230	137,297	40,593	165,254
ចំណាយកម្រៃសេវាផ្នែកច្បាប់ និងវិជ្ជាជីវៈ	33,417	134,036	36,715	149,467
ចំណាយពន្ធដារ និងការពិន័យ	22,867	91,720	104,200	424,198
ចំណាយផ្សេងៗ	285,834	1,146,479	264,988	1,078,766
	2,637,699	**10,579,811**	**3,388,424**	**13,794,274**

23. ចំណាយរំលស់

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ចំណាយរំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	382,797	1,535,399	366,290	1,491,167
ចំណាយរំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ 13	257,699	1,033,631	281,718	1,146,874
ចំណាយរំលស់លើទ្រព្យសកម្មអរូបី (កំណត់សម្គាល់ 12)	225,885	906,024	148,109	602,951
	866,381	**3,475,054**	**796,117**	**3,240,992**

24. ការខាតបង់ឥនភាពលើតម្លៃ/(ការកត់ត្រាបញ្ច្រាស់) នៃឧបករណ៍ហិរញ្ញវត្ថុ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ការខាតបង់សំវិធានធន (ការកត់ត្រាបញ្ច្រាស់) សម្រាប់ ECL				
តណទានផ្តល់ដល់អតិថិជន (កំណត់សម្គាល់ 8)	891,507	3,575,835	(396,185)	(1,612,869)
ការវិនិយោគ (កំណត់សម្គាល់ 9)	11,785	47,269	300,874	1,224,858
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា (កំណត់សម្គាល់ 6)	86,738	347,906	(234)	(953)
	990,030	**3,971,010**	**(95,545)**	**(388,964)**

25. ភាគីពាក់ព័ន្ធ

(ក) សមតុល្យរបស់ភាគីពាក់ព័ន្ធ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ក្រុមហ៊ុនបុត្រសម្ព័ន្ធ - ខេប ស៊ីយ្យរីធីលីមីធីត៖				
គណនីចរន្ត និងបញ្ញើមានកាលកំណត់	1,240,651	4,978,732	1,252,448	5,041,101

(ខ) ប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធ

បន្ថែមទៅលើការបង្ហាញអំពីភាគីពាក់ព័ន្ធដែលបានពណ៌នានៅកន្លែងផ្សេងទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ប្រតិបត្តិការ ភាគីពាក់ព័ន្ធសំខាន់ៗដ៏ទៃទៀត ត្រូវបានបង្ហាញដូចខាងក្រោម។

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ក្រុមហ៊ុនបុត្រសម្ព័ន្ធ - ខេប ស៊ីយ្យរីធីលីមីធីត៖				
ចំណូលពីការជួល	-	-	7,500	30,533
ចំណាយការប្រាក់	**38,020**	**152,497**	**97,226**	**395,807**

(គ) លាភការរបស់គណៈគ្រប់គ្រងសំខាន់ៗ

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និង អត្ថប្រយោជន៍ផ្សេងៗ	356,790	1,431,085	418,939	1,705,502

គណៈគ្រប់គ្រងសំខាន់ៗរបស់ធនាគារ សំដៅទៅលើក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់មួយចំនួនដែលមានសិទ្ធិអំណាច និងការទទួលខុសត្រូវសម្រាប់ការធ្វើផែនការ ដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ធនាគារដោយផ្ទាល់ ឬដោយប្រយោល។

26. ព័ត៌មានលំហូរសាច់ប្រាក់

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

	2025		2024	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
សាច់ប្រាក់ក្នុងដៃ (កំណត់សម្គាល់ 5)	59,372,297	238,261,028	64,272,873	258,698,314
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា (កំណត់សម្គាល់ 6)	60,289,832	241,943,095	74,470,979	299,745,690
សមតុល្យនៅធនាគារជាតិនៃកម្ពុជា (កំណត់សម្គាល់ 7)	10,751,722	43,146,660	9,010,896	36,268,856
	130,413,851	**523,350,783**	**147,754,748**	**594,712,860**
ដក៖ ប្រាក់បញ្ញើមានកាលវិសាន្ត ច្រើនជាង 3ខែ	(43,495,576)	(174,547,746)	(35,473,461)	(142,780,680)
នាថ្ងៃទី31 ខែធ្នូ	**86,918,275**	**348,803,037**	**112,281,287**	**451,932,180**

27. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

ក. សេចក្តីផ្តើម និងទស្សនៈទូទៅ

ធនាគារប្រឈមមុខនឹងហានិភ័យឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖
- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ និង
- ហានិភ័យសន្ទនីយភាព

កំណត់សម្គាល់នេះ បង្ហាញពីព័ត៌មានស្តីពីហានិភ័យនីមួយៗខាងលើរបស់ធនាគារ គោលដៅ គោលការណ៍ណែនាំ និងវិធានការណ៍របស់ធនាគារដើម្បីវាស់វែង និងគ្រប់គ្រងនូវហានិភ័យដែលកើតឡើង និងការគ្រប់គ្រងដើមទុនរបស់ធនាគារ។

ខ. ហានិភ័យឥណទាន

ធនាគារប្រឈមនឹងហានិភ័យឥណទាន ដែលជាហានិភ័យ ដែលធ្វើឱ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុដល់ធនាគារប្រសិនបើអតិថិជន ឬភាគីម្ខាងទៀតមិនមានលទ្ធភាពបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យា។ ហានិភ័យឥណទាន គឺជាហានិភ័យដែលមានសារៈសំខាន់ជាងគេបំផុតរបស់ធនាគារ។ ភាគច្រើនហានិភ័យឥណទានកើតឡើងពីសកម្មភាពនៃការផ្តល់ឥណទានដល់អតិថិជន និងសមតុល្យនៅធនាគារផ្សេងៗ។ ឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការក៏មាន ហានិភ័យឥណទានដែរដូចជាកិច្ចសន្យាឥណទាន។ ការគ្រប់គ្រងហានិភ័យឥណទាន ត្រូវបានធ្វើឡើងដោយគណៈ កម្មាធិការឥណទានរបស់ធនាគារ។

សកម្មភាពនៃការផ្តល់ឥណទាន ត្រូវបានធ្វើឡើងដោយស្របទៅតាមគោលការណ៍ឥណទានរបស់ធនាគារ ដើម្បីធានាការសម្រេចបាននូវគោលបំណង ជាទូទៅនៅក្នុងផ្នែកកម្ចីមានន័យថា ត្រូវសម្រេចបាននូវផលប័ត្រឥណទានល្អ និងរឹងមាំហើយអាចកាត់បន្ថយ និងគ្រប់គ្រងហានិភ័យឥណទានបាន។ គោលការណ៍ឥណទានរួមមាន គោលការណ៍ក្នុងការផ្តល់ឥណទាន គោលការណ៍ស្តីពីវត្ថុបញ្ចាំ ព្រមទាំងដំណើរការ និងនីតិវិធីអនុម័តឥណទាន ដើម្បីធានានូវអនុលោមភាពតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ អតិថិជនដែលមានលើសគណនីពីមួយ ត្រូវមានការត្រួតពិនិត្យ និងវាយតម្លៃហ្មត់ចត់។ ធនាគារតាមដានយ៉ាងយកចិត្តទុកដាក់អំពីការប្រមូលផ្តុំហានិភ័យ តណទានទៅតាមប្រភេទអាជីវកម្ម។ លក្ខណៈវិនិច្ឆ័យបន្ថែមទៀត ក្នុងការអនុម័តឥណទានឱ្យអតិថិជនក៏ត្រូវបានដាក់ឱ្យអនុវត្ត ចំពោះផ្នែកដែលមានហានិភ័យជាក់លាក់ផងដែរ។

(1) ការវាស់ហានិភ័យឥណទាន

ធនាគារវាយតម្លៃលទ្ធភាពនៃការខកខាន មិនបានសងបំណុលរបស់អ្នកខ្ចីជាឯកត្តជន ដោយផ្តោតលើការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់របស់អ្នកខ្ចី។ គណៈកម្មាធិការឥណទានទទួលខុសត្រូវ ក្នុងការអនុម័តផ្តល់ឥណទានដល់អតិថិជន។

(2) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ

ធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទានដល់ឯកត្តជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារគ្រប់គ្រងកម្រិត និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាននៅពេលដែលវាត្រូវបានរកឃើញ។

ធនាគារប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ គោលការណ៍ដែល ត្រូវបានអនុវត្តទូទៅក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយដាក់ទ្រព្យបញ្ចាំចំពោះឥណទាន អតិថិជន។ធនាគារធ្វើការវាយតម្លៃអំពីលំហូរសាច់ប្រាក់របស់អតិថិជនម្តាក់ៗ ដើម្បីធានាបាននូវសមត្ថភាពក្នុងការសងប្រាក់របស់ពួកគេ។

(3) ការប្រមូលផ្តុំហានិភ័យ

ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការឥណទានធនាគារសម្រាប់ត្រួតពិនិត្យហានិភ័យឥណទាន។ នាយកដ្ឋាន ឥណទានដោយឡែក ត្រូវរាយការណ៍ជូនគណៈកម្មាធិការឥណទានដែលទទួលខុសត្រូវ ក្នុងការគ្រប់គ្រងហានិភ័យឥណទាន រួមមានដូចខាងក្រោម។

តារាងខាងក្រោមបង្ហាញពី ការប្រឈមអតិបរមានលើហានិភ័យឥណទានរបស់ធនាគារ លើឧបករណ៍ហិរញ្ញវត្ថុក្នុងតារាងតុល្យការ និងក្រៅតារាងតុល្យការដោយមិនគិតពីទ្រព្យបញ្ចាំ ឬការពង្រឹងឥណទានដទៃទៀត។ សម្រាប់ទ្រព្យសកម្មក្នុងតារាងតុល្យការ ការប្រឈមនឹងហានិភ័យឥណទានស្មើនឹងតម្លៃយោងរបស់វា។ ចំពោះកិច្ចសន្យាឥណទាន ការប្រឈមអតិបរិមាលើហានិភ័យឥណទានគឺចំនួនទឹកប្រាក់ទាំងស្រុងនៃឥណទាន ដែលមិនទាន់ដកប្រើប្រាស់ដោយអតិថិជន។

ប្រភេទនៃទំហំហានិភ័យឥណទាន

	តម្លៃយោង				
	ទំហំហានិភ័យឥណទានអតិបរមា ដុល្លារអាមេរិក	ទំហំហានិភ័យឥណទានអតិបរមា ៣ទន់រៀល	ការដាក់ទ្រព្យបញ្ចាំ/ ការពង្រឹងឥណទាន %	ផ្នែកខ្លះពីទ្រព្យបញ្ចាំ/ ការពង្រឹងឥណទាន %	មិនមានការធានា និង គ្មានទ្រព្យបញ្ចាំ/ ការពង្រឹងឥណទាន %
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025					
ធាតុនានាក្នុងតារាងតុល្យការ					
សាច់ប្រាក់ក្នុងដៃ	59,372,297	238,261,028	-	-	100
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	61,352,374	246,207,076	-	-	100
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	10,752,018	43,147,848	-	-	100
ឥណទានផ្តល់ដល់អតិថិជន	80,411,285	322,690,487	98.42	-	1.58
ការវិនិយោគ	25,588	102,685	-	-	100
ទ្រព្យសកម្មផ្សេងៗ	1,059,020	4,249,848	-	-	100
ប្រាក់តម្កល់តាមបទប្បញ្ញតិ	21,297,413	85,466,518	-	-	100
សរុប	**234,269,995**	**940,125,490**			
ធាតុនានាក្រៅតារាងតុល្យការ					
កិច្ចសន្យា	3,622,588	14,537,446	100	-	-

កាប្រមូលផ្តុំហានិភ័យ វិភាគតាមប្រភេទអាជីវកម្ម

កាប្រមូលផ្តុំហានិភ័យវិភាគតាមប្រភេទអាជីវកម្មត្រូវបានវិភាគដោយប្រើប្រាស់សមតុល្យដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុមានដូចខាងក្រោម៖

	តម្លៃយោង				
	ទំហំហានិភ័យឥណទានអតិបរមា ដុល្លារអាមេរិក	ទំហំហានិភ័យឥណទានអតិបរមា ៣ន់រៀល	ការដាក់ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន %	ផ្នែកខ្លះពីទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន %	មិនមានការធានា និងគ្មានទ្រព្យបញ្ចាំ/ការ... %
ទាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024					
ធាតុនានាក្នុងតារាងតុល្យការ					
សាច់ប្រាក់ក្នុងដៃ	64,272,873	258,698,314	-	-	100
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	75,547,631	304,079,214	-	-	100
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	9,011,057	36,269,504	-	-	100
ឥណទានផ្តល់ដល់អតិថិជន	83,027,913	334,187,350	98.67	-	1.33
ការវិនិយោគ	25,588	102,992	-	-	100
ទ្រព្យសកម្មផ្សេងៗ	2,107,048	8,480,868	-	-	100
ប្រាក់តម្កល់តាមបទប្បញ្ញតិ	19,648,772	79,086,307	-	-	100
សរុប	**253,640,882**	**1,020,904,549**			
ធាតុនានាក្រៅតារាងតុល្យការ					-
កិច្ចសន្យា	4,019,856	16,179,920	100	-	

ការប្រមូលផ្តុំហានិភ័យ វិភាគតាមប្រភេទអាជីវកម្ម

ការប្រមូលផ្តុំហានិភ័យវិភាគតាមប្រភេទអាជីវកម្មត្រូវបានវិភាគដោយប្រើប្រាស់សមតុល្យដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុមានដូចខាងក្រោម៖

	សាច់ប្រាក់នៅក្នុងដៃ ដុល្លារអាមេរិក	សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុ ដុល្លារអាមេរិក	សមតុល្យនៅធនគារជាតិនៃកម្ពុជា ដុល្លារអាមេរិក	ប្រាក់តម្កល់តាមបទប្បញ្ញត្តិ ដុល្លារអាមេរិក	តណទានផ្តល់ដល់អតិថិជន ដុល្លារអាមេរិក	ការវិនិយោគ ដុល្លារអាមេរិក	ទ្រព្យសកម្មផ្សេងៗ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025								
ពាណិជ្ជកម្មលក់រាយ	-	-	-	-	34,324,132	-	-	34,324,132
ពាណិជ្ជកម្មលក់ដុំ	-	-	-	-	8,556,006	-	-	8,556,006
សំណង់	-	-	-	-	11,303,244	-	-	11,303,244
តណទានឯកជន	-	-	-	-	7,817,709	-	-	7,817,709
តណទានគេហដ្ឋាន	-	-	-	-	3,677,917	-	-	3,677,917
ការជួល និងតតិសន្យាប្រតិបត្តិការ	-	-	-	-	2,497,979	-	-	2,497,979
អចលនទ្រព្យ	-	-	-	-	1,235,319	-	-	1,235,319
តោជនីយដ្ឋាន	-	-	-	-	2,213,936	-	-	2,213,936
ដឹកជញ្ជូន	-	-	-	-	2,175,889	-	-	2,175,889
សណ្ឋាគារ	-	-	-	-	1,554,871	-	-	1,554,871
វិស័យសុខាភិបាល និងកិច្ចការងារសង្គម	-	-	-	-	65,422	-	-	65,422
កសិកម្ម	-	-	-	-	1,396,914	-	-	1,396,914
គ្រឿងម៉ាស៊ីន	-	-	-	-	2,541,357	-	-	2,541,357
សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ	-	-	-	-	1,050,590	-	-	1,050,590
ធនាគារ	-	61,352,374	10,752,018	21,297,413	-	-	-	93,401,805
ប្រភេទផ្សេងៗ	59,372,297	-	-	-	-	25,588	1,059,020	60,456,905
សរុប (ដុល្លារអាមេរិក)	**59,372,297**	**61,352,374**	**10,752,018**	**21,297,413**	**80,411,285**	**25,588**	**1,059,020**	**234,269,995**
សរុប (៣ទំរៀល)	**238,261,028**	**246,207,076**	**43,147,848**	**85,466,518**	**322,690,487**	**102,685**	**4,249,848**	**940,125,490**

ការប្រមូលផ្តុំហានិភ័យ វិភាគតាមប្រភេទអាជីវកម្ម

ការប្រមូលផ្តុំហានិភ័យវិភាគតាមប្រភេទអាជីវកម្មត្រូវបានវិភាគដោយប្រើប្រាស់សមតុល្យដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុមានដូចខាងក្រោម៖

	សាច់ប្រាក់នៅក្នុងដៃ ដុល្លារអាមេរិក	សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុ ដុល្លារអាមេរិក	សមតុល្យនៅធនាគារជាតិនៃកម្ពុជា ដុល្លារអាមេរិក	ប្រាក់តម្កល់តាមបទប្បញ្ញត្តិ ដុល្លារអាមេរិក	ឥណទានផ្តល់ដល់អតិថិជន ដុល្លារអាមេរិក	ការវិនិយោគ ដុល្លារអាមេរិក	ទ្រព្យសកម្មផ្សេងៗ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024								
ពាណិជ្ជកម្មលក់រាយ	-	-	-	-	35,248,942	-	-	35,248,942
ពាណិជ្ជកម្មលក់ដុំ	-	-	-	-	15,346,215	-	-	15,346,215
សំណង់	-	-	-	-	11,762,273	-	-	11,762,273
ឥណទានឯកជន	-	-	-	-	7,255,258	-	-	7,255,258
ឥណទានគេហដ្ឋាន	-	-	-	-	3,113,993	-	-	3,113,993
ការជួល និងភតិសន្យាប្រតិបត្តិការ	-	-	-	-	1,626,162	-	-	1,626,162
អចលនទ្រព្យ	-	-	-	-	2,369,992	-	-	2,369,992
ភោជនីយដ្ឋាន	-	-	-	-	1,572,557	-	-	1,572,557
ដឹកជញ្ជូន	-	-	-	-	2,037,349	-	-	2,037,349
សណ្ឋាគារ	-	-	-	-	1,274,789	-	-	1,274,789
វិស័យសុខាភិបាលនិងកិច្ចការងារសង្គម	-	-	-	-	71,175	-	-	71,175
កសិកម្ម	-	-	-	-	162,702	-	-	162,702
គ្រឿងម៉ាស៊ីន	-	-	-	-	656,945	-	-	656,945
សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ	-	-	-	-	529,561	-	-	529,561
ធនាគារ	-	75,547,631	9,011,057	19,648,772	-	-	-	104,207,460
ប្រភេទផ្សេងៗ	64,272,873	-	-	-	-	25,588	2,107,048	66,405,509
សរុប (ដុល្លារអាមេរិក)	**64,272,873**	**75,547,631**	**9,011,057**	**19,648,772**	**83,027,913**	**25,588**	**2,107,048**	**253,640,882**
សរុប (៣ន់រៀល)	**258,698,314**	**304,079,214**	**36,269,504**	**79,086,307**	**334,187,350**	**102,992**	**8,480,868**	**1,020,904,549**

ការប្រមូលផ្តុំហានិភ័យវិភាគតាមរូបិយប័ណ្ណ និវាសដ្ឋាន ទំហំហានិភ័យ និងស្ថានភាពនៃតណទានផ្តល់ដល់អតិថិជន៖

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
តាមរូបិយប័ណ្ណ៖				
ប្រាក់ដុល្លារអាមេរិក	71,280,172	286,047,330	74,824,774	301,169,716
ប្រាក់រៀល	9,131,113	36,643,157	8,203,139	33,017,634
	80,411,285	322,690,487	83,027,913	334,187,350
តាមនិវាសនដ្ឋាន៖				
និវាសនជន	80,411,285	322,690,487	83,027,913	334,187,350
តាមទំហំហានិភ័យ៖				
មិនមែនជាហានិភ័យទំហំធំៗ	80,411,285	322,690,487	83,027,913	334,187,350
តាមស្ថានភាពតណទាន៖				
មិនបានរៀបចំឡើងវិញ	72,731,747	291,872,501	74,855,670	301,294,072
បានរៀបចំឡើងវិញ	7,679,538	30,817,986	8,172,243	32,893,278
	80,411,285	**322,690,487**	**83,027,913**	**334,187,350**

រូបិយប័ណ្ណ

នៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2016 NBC បានចេញប្រកាសលេខ ធ7-016-334 ស្តីពីការផ្តល់តណទានជារូបិយប័ណ្ណជាតិ សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដោយតម្រូវឱ្យគ្រឹះស្ថានទាំងអស់រក្សាប្រាក់កម្ចីជារូបិយប័ណ្ណជាតិ (ខ្មែររៀល) យ៉ាងហោចណាស់ 10% នៃសំណុំតណទានសរុប។

ទំហំហានិភ័យ

ហានិភ័យទំហំធំ ត្រូវបានកំណត់និយមន័យ ដោយប្រកាសនៃធនាគារជាតិនៃកម្ពុជា ថាជាទំហំហានិភ័យសរុបនៃ សមតុល្យតណទាន និងបុរេប្រទានសរុបជាមួយអតិថិជនតែមួយ ដែលមានចំនួនលើសពីដប់ភាគរយ (10%) នៃទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ។ ទំហំហានិភ័យ គឺជាចំនួនខ្ពស់ជាងរវាងតណទាន ឬកិច្ចសន្យាដែលនៅសល់ និងតណទាន ឬកិច្ចសន្យាដែលបានអនុម័ត។

(4) ទ្រព្យបញ្ចាំ

ខណៈពេលដែលការប្រឈមអតិបរមារបស់ធនាគារលើហានិភ័យឥណទាន គឺជាតម្លៃយោងរបស់ទ្រព្យសកម្ម ឬក្នុងករណីឧបករណ៍ហិរញ្ញវត្ថុនៅក្រៅតារាងតុល្យការ គឺចំនួនទឹកប្រាក់ដែលបានធានា ការសន្យាផ្តល់ឱ្យ ការទទួលយក ឬការយល់ព្រម ហានិភ័យដែលទំនងជាអាចកើតឡើងប្រហែលជាស្ថិតក្នុងកម្រិតទាបជាងមុន ដោយសារតែការ កាត់កងលើទ្រព្យបញ្ចាំ ឥណទានដែលបានធានា និងសកម្មភាពផ្សេងទៀតដែលត្រូវបានធ្វើឡើង ដើម្បីកាត់បន្ថយហានិភ័យ។

ការពិពណ៌នាអំពីទ្រព្យបញ្ចាំសម្រាប់ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ ត្រូវបានបង្ហាញដូចខាងក្រោម៖

សាច់ប្រាក់និងសាច់ប្រាក់សមមូល សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា សមតុល្យនៅ NBC ការវិនិយោគ និងទ្រព្យសកម្មផ្សេងៗ

ជាទូទៅ ការដាក់ទ្រព្យបញ្ចាំគឺមិនចាំបាច់សម្រាប់ទ្រព្យសកម្មទាំងនេះ។

ឥណទានផ្តល់ដល់អតិថិជន បំណុលយថាភាព និងកិច្ចសន្យា

ឥណទានផ្តល់ដល់អតិថិជន បំណុលយថាភាព និងកិច្ចសន្យា ជាធម្មតាត្រូវមានដាក់ជាទ្រព្យបញ្ចាំក្នុងកម្រិតណាមួយ។ ជាពិសេសហានិភ័យលើឥណទានគេហដ្ឋាន ជាទូទៅត្រូវបានធានាពេញលេញដោយទ្រព្យលំនៅដ្ឋាន។

តារាងខាងក្រោមនេះសង្ខេបអំពីការធានាលើទ្រព្យសកម្មហិរញ្ញវត្ថុរបស់ធនាគារ៖

	មានទ្រព្យបញ្ចាំ ដុល្លារអាមេរិក	ហានិភ័យឥណទាន ពុំមានការធានា ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025			
ឥណទានផ្តល់ដល់អតិថិជន	79,171,320	1,239,965	80,411,285
កិច្ចសន្យា	3,238,626	383,962	3,622,588
	82,409,946	**1,623,927**	**84,033,873**
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024			
ឥណទានផ្តល់ដល់អតិថិជន	81,936,762	1,091,151	83,027,913
កិច្ចសន្យា	3,425,499	594,357	4,019,856
	85,362,261	**1,685,508**	**87,047,769**

	មានទ្រព្យបញ្ចាំ ៣ន់រៀល	ហានិភ័យឥណទានពុំមានការធានា ៣ន់រៀល	សរុប ៣ន់រៀល
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025			
ឥណទានផ្តល់ដល់អតិថិជន	317,714,507	4,975,980	322,690,487
កិច្ចសន្យា	12,996,606	1,540,840	14,537,446
	330,711,113	6,516,820	337,227,933
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024			
ឥណទានផ្តល់ដល់អតិថិជន	329,795,467	4,391,883	334,187,350
កិច្ចសន្យា	13,787,633	2,392,287	16,179,920
	343,583,100	**6,784,170**	**350,367,270**

(5) គុណភាពឥណទានដុលផ្តល់ដល់អតិថិជន

ដោយអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចំណាត់ថ្នាក់ឥណទានមួយៗ យោងទៅតាមគុណភាពឥណទានដូចខងក្រោម៖

ឥណទានធម្មតា

ឥណទានដែលនៅសល់ ត្រូវបានទូទាត់សងទាន់ពេលវេលា និងមិនជាប់សង្ស័យសម្រាប់ការទូទាត់សងនាពេលអនាគត។ ការទូទាត់សងត្រូវបានធ្វើឡើងតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយអតិថិជនមិនបានបង្ហាញពីភាពទន់ខ្សោយលើលទ្ធភាពក្នុងការទូទាត់សងអាជីវកម្ម លំហូរសាច់ប្រាក់ និងស្ថានភាពហិរញ្ញវត្ថុនោះឡើយ។

ឥណទានឃ្លាំមើល

ឥណទានដែលស្ថិតនៅក្នុងចំណាត់ថ្នាក់នេះ ត្រូវបានការពារនាពេលបច្ចុប្បន្ន ហើយប្រហែលជាមិនអាចហួសកាលកំណត់ទេ ប៉ុន្តែវាបានបង្ហាញពីភាពទន់ខ្សោយដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការទូទាត់សងរបស់អតិថិជនក្នុងពេលអនាគតប្រសិនបើមិនបានកែតម្រូវឱ្យបានទាន់ពេលវេលានិងការយកចិត្តទុកដាក់ពីគ្រឹះស្ថាន។

ភាពទន់ខ្សោយនេះ រាប់បញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់ចំពោះនិន្នាការថយចុះនៃប្រតិបត្តិការអាជីវកម្មរបស់សមភាគី ឬស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន និងស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌទីផ្សារដែលអាចប៉ះពាល់ដល់ប្រាក់ចំណេញ និងលទ្ធភាពទូទាត់សងនាពេលអនាគតរបស់ខ្លួន ឬស្ថានភាពកាន់តែយ៉ាប់យ៉ឺននៃទ្រព្យបញ្ចាំ។ ចំណាត់ថ្នាក់នេះមាន សនិទានភាពផ្ទាល់ខ្លួនយ៉ាងច្បាស់លាស់ ហើយមិនគួរប្រើជាការសម្របសម្រួលរវាងឥណទានធម្មតានិងឥណទានក្រោមស្តង់ដារទេ។

ឥណទានក្រោមស្តង់ដា

ឥណទានដែលបានចាត់ថ្នាក់នៅក្នុងចំណាត់ថ្នាក់នេះ បានបង្ហាញពីភាពទន់ខ្សោយគួរឱ្យកត់សម្គាល់ ហើយមិនត្រូវបានទ្រទ្រង់ឱ្យគ្រប់គ្រាន់ពីអាជីវកម្មបច្ចុប្បន្ន ឬស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់អតិថិជនទេ។ និយាយឱ្យចំ ប្រភពចំណូលចម្បងសម្រាប់សងបំណុល គឺមិនគ្រប់គ្រាន់ក្នុងការទូទាត់បំណុលនោះទេ ដោយមិនគិតពីប្រាក់ចំណូលដែលបានមកពីប្រភពបន្ទាប់បន្សំដូចជាលក់ទ្រព្យបញ្ចាំជាដើម។

កត្តាដែលនាំឱ្យមានចំណាត់ថ្នាក់តណទានក្រោមស្តង់ដាររួមមាន៖

- អតិថិជនគ្មានលទ្ធភាព ដើម្បីបំពេញតាមលក្ខខណ្ឌនៃការទូទាត់សងប្រាក់តាមកិច្ចសន្យា
- ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារមិនអំណោយផលដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ដល់អាជីវកម្ម និងប្រាក់ចំណេញរបស់ដៃគូរភាគីនាពេលអនាគត
- ស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយ និង/ឬ អសមត្ថភាពរបស់សមភាគី ដើម្បីបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីបំពេញការទូទាត់សង
- ភាពលំបាកដែលបានជួបប្រទះដោយសមភាគីក្នុងការទូទាត់សងតណទានផ្សេងទៀត ដែលផ្តល់ដោយគ្រឹះស្ថានឬដោយគ្រឹះស្ថានផ្សេងៗទៀត នៅពេលមានព័ត៌មានអាចប្រើប្រាស់បាន និង
- ការបំពានលើកិច្ចព្រមព្រៀងហិរញ្ញវត្ថុដោយអតិថិជន។

តណទានជាប់សង្ស័យ

តណទានដែលបានចាត់ថ្នាក់នៅក្នុងប្រភេទនេះ បង្ហាញពីភាពទន់ខ្សោយធ្ងន់ធ្ងរជាងចំណាត់ថ្នាក់តណទានក្រោម ស្តង់ដារដែលការប្រមូលបានមកវិញគ្រប់ចំនួន ផ្អែកលើមូលដ្ឋាននៃដំណើរហេតុដែលមានស្រាប់ លក្ខខណ្ឌ ឬតម្លៃនៃទ្រព្យបញ្ចាំមានការសង្ស័យខ្ពស់ ឬមិនអាចអាចប្រមូលបានវិញ។ ការរំពឹងទុកថានឹងបាត់បង់គឺខ្ពស់ ទោះបីជាចំនួនពិតប្រាកដនៅមិនទាន់បានកំណត់សម្រាប់ពេលនេះក៏ដោយ។

តណទានខាតបង់

តណទានដែលត្រូវបានចាត់ថ្នាក់ ថាជាការបាត់បង់គឺនៅពេលដែលវាមិនអាចប្រមូលបានមកវិញ ហើយការទូទាត់សងវិញអាចមានចំនួនតិចតួច ឬប្រមូលមិនបានសោះ។

ការទទួលស្គាល់ការខាតបង់តណទានរំពឹងទុក

ធនាគារអនុវត្តវិធីសាស្ត្រ 3 ដំណាក់កាល ដោយផ្អែកលើការផ្លាស់ប្តូរគុណភាពតណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង៖

វិធីសាស្ត្រ 3 ដំណាក់កាល	ដំណាក់កាលទី 1	ដំណាក់កាលទី 2	ដំណាក់កាលទី 3
	ដំណើរការ	ក្រោមដំណើរការ	មិនដំណើរការ
ការទទួលស្គាល់ការខាតបង់តណទានរំពឹងទុក	រំពឹងថានឹងបាត់បង់ រយៈពេល 12ខែ	រំពឹងថានឹងបាត់បង់ ពេញមួយអាយុកាល	រំពឹងថានឹងបាត់បង់ ពេញមួយអាយុកាល
លក្ខណៈវិនិច្ឆ័យ	មិនមានការកើនឡើងជាសារវន្ត លើហានិភ័យតណទាន	ហានិភ័យតណទានបានកើនឡើងជាសារវន្ត	តណទានដែលមានឱនភាពតម្លៃ
មូលដ្ឋាននៃការគណនាចំណូលជាប្រាក់ចំណេញ	តម្លៃយោងដុល	តម្លៃយោងដុល	តម្លៃយោងសុទ្ធ

ធនាគារ នឹងវាស់វែងលើការខាតបង់តណទានរំពឹងទុក ដោយប្រើវិធីសាស្ត្រទូទៅ។ វិធីសាស្ត្រទូទៅរួមមាន ការញែកអតិថិជនចេញជា 3 ដំណាក់កាលផ្សេងៗគ្នា ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យដំណាក់កាល ដោយធ្វើការវាយតម្លៃហានិភ័យតណទាន។ ការខាតបង់តណទានរំពឹងទុករយៈពេល 12ខែ នឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី 1 ខណៈពេលដែលការខាតបង់តណទានរំពឹងទុក ពេញមួយអាយុកាលនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី 2 និងដំណាក់កាលទី 3។ នាការិយបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារនឹងវាយតម្លៃហានិភ័យតណទាន ទៅតាមគណនីនីមួយៗ បើប្រៀបធៀបនឹងកម្រិតហានិភ័យនៅពេលផ្តល់ឱ្យ។

តណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)

ដំណាក់កាល	ស្ថានភាពហានិភ័យតណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សុចនាករណ៍នៃការយឺតយ៉ាវ	សំវិធានធន
1	មិនមានការកើនឡើងជាសារវន្តលើហានិភ័យតណទានទេ	តណទានធម្មតា	0 ដល់តូចជាង 30ថ្ងៃ	ដំណើរការ	1%
2	ហានិភ័យតណទានបានកើតឡើងជាសារវន្ត	តណទានឃ្លាំមើល	30 ដល់តូចជាង 90ថ្ងៃ	ក្រោមដំណើរការ	3%
3	តណទានមានឱនភាពតម្លៃ	តណទានក្រោមស្តង់ដារ	90 ដល់តូចជាង 180ថ្ងៃ	មិនដំណើរការ	20%
		តណទានជាប់សង្ស័យ	180 ដល់តូចជាង 360ថ្ងៃ		50%
		តណទានខាតបង់	លើសពី 360 ថ្ងៃ		100%

តណទានរយៈពេលខ្លី (មួយឆ្នាំ ឬតិចជាង)

ដំណាក់កាល	ស្ថានភាពហានិភ័យតណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សុចនាករណ៍នៃការយឺតយ៉ាវ	សំវិធានធន
1	មិនមានការកើនឡើងជាសារវន្តលើហានិភ័យតណទានទេ	តណទានធម្មតា	0 ដល់តូចជាង 14ថ្ងៃ	ដំណើរការ	1%
2	ហានិភ័យតណទានបានកើតឡើងជាសារវន្ត	តណទានឃ្លាំមើល	15 ដល់តូចជាង 30ថ្ងៃ	ក្រោមដំណើរការ	3%
3	តណទានមានឱនភាពតម្លៃ	តណទានក្រោមស្តង់ដារ	31 ដល់តូចជាង 60ថ្ងៃ	មិនដំណើរការ	20%
		តណទានជាប់សង្ស័យ	61 ដល់តូចជាង 90ថ្ងៃ		50%
		តណទានខាតបង់	លើសពី 91ថ្ងៃ		100%

ធនាគារ នឹងប្រើប្រាស់ចំនួនថ្ងៃហួសកាលកំណត់សង និងចំណាត់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា សម្រាប់លក្ខណៈវិនិច្ឆ័យក្នុងការបែងចែកដំណាក់កាល។ ដូចគ្នានេះផងដែរ ធនាគារនឹងបង្កើតការដាក់ពិន្ទុតណទាន ឬធាតុដែលអាចប៉ាន់ស្មានបាននាពេលអនាគតនៅពេលមានព័ត៌មានកាន់តែងាយស្រួលរក។ នៅពេលអនុវត្តប្រព័ន្ធផ្ទៃក្នុង ក្នុងការដាក់ពិន្ទុតណទាន ប្រសិនបើកម្រិតហានិភ័យធ្លាក់ចុះទ្វេដង ឬច្រើនជាងនេះ បើប្រៀបធៀបទៅនឹងកម្រិតហានិភ័យនៅពេលផ្តល់ឱ្យនោះ គណនីនឹងតម្រូវឱ្យធ្វើចំណាត់ថ្នាក់ទៅដំណាក់កាលទី 2។

ជាលទ្ធផលពីការអនុវត្ត ស.រ.ហ.អ.ក 9 ធនាគារទទួលស្គាល់ការបាត់បង់ឱនភាពតម្លៃចំពោះប្រាក់បញ្ញើជាមួយធនាគារផ្សេងទៀតដោយផ្អែកលើពិន្ទុតណទានរបស់ធនាគារផ្សេងៗនោះ។

តារាងខាងក្រោម សង្ខេបពីគុណភាពឥណទាននៃហិរញ្ញប្បទានដុលរបស់ធនាគារ ដោយយោងតាមចំណាត់ថ្នាក់ខាងលើ។

	នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025			
	ដំណាក់កាលទី 1 ដុល្លារអាមេរិក	ដំណាក់កាលទី 2 ដុល្លារអាមេរិក	ដំណាក់កាលទី 3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
តណទានផ្តល់ដល់អតិថិជន តាមថ្លៃដើមរំលស់				
តណទានធម្មតា	67,481,255	-	-	67,481,255
តណទានឃ្លាំមើល	-	2,723,227	-	2,723,227
តណទានក្រោមស្តង់ដា	-	-	2,156,674	2,156,674
តណទានជាប់សង្ស័យ	-	-	2,054,260	2,054,260
តណទានខាតបង់	-	-	5,995,869	5,995,869
សរុប	**67,481,255**	**2,723,227**	**10,206,803**	**80,411,285**
ដក៖ សំវិធានធនលើការខាតបង់	(1,167,733)	(255,348)	(1,763,633)	(3,186,714)
តម្លៃយោង (ដុល្លារអាមេរិក)	**66,313,522**	**2,467,879**	**8,443,170**	**77,224,571**
តម្លៃយោង (៣ន់រៀល)	**266,116,164**	**9,903,598**	**33,882,440**	**309,902,203**

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024			
	ដំណាក់កាលទី 1 ដុល្លារអាមេរិក	ដំណាក់កាលទី 2 ដុល្លារអាមេរិក	ដំណាក់កាលទី 3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
តណទានផ្តល់ដល់អតិថិជន តាមថ្លៃដើមរំលស់				
តណទានធម្មតា	75,250,635	-	-	75,250,635
តណទានឃ្លាំមើល	-	1,280,540	-	1,280,540
តណទានក្រោមស្តង់ដា	-	-	1,269,402	1,269,402
តណទានជាប់សង្ស័យ	-	-	274,850	274,850
តណទានខាតបង់	-	-	4,952,486	4,952,486
សរុប	**75,250,635**	**1,280,540**	**6,496,738**	**83,027,913**
ដក៖ សំវិធានធន លើការខាតបង់	(1,397,346)	(55,105)	(842,756)	(2,295,207)
តម្លៃយោង (ដុល្លារអាមេរិក)	**73,853,289**	**1,225,435**	**5,653,982**	**80,732,706**
តម្លៃយោង (ពាន់រៀល)	**297,259,487**	**4,932,375**	**22,757,277**	**324,949,142**

ការបញ្ចូលព័ត៌មានលើការប៉ាន់ស្មានអនាគត

ធនាគារបញ្ចូលនូវព័ត៌មានលើការប៉ាន់ស្មានអនាគតទាំងការវាយតម្លៃ ថាតើហានិភ័យតណទាននៃឧបករណ៍មួយបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់ដំបូងរបស់ខ្លួន និងការវាស់វែងនៃ ECL។ព័ត៌មានខាងក្រៅដែលត្រូវបានពិចារណា រួមមានទិន្នន័យសេដ្ឋកិច្ច និងការព្យាករណ៍ដែលបោះផ្សាយដោយស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធររូបិយវត្ថុក្នុងប្រទេសដែលធនាគារដំណើរការ អង្គការជាន់ខ្ពស់ដូចជា NBC និងវិស័យឯកជន និងការសិក្សារបស់អ្នកព្យាករណ៍។

ធនាគារបានកំណត់អត្តសញ្ញាណ និងចងក្រងឯកសារកត្តាជំរុញសំខាន់ៗនៃហានិភ័យតណទាន និងការខាតបង់តណទានសម្រាប់ផលប័ត្រឧបករណ៍ហិរញ្ញវត្ថុនីមួយៗ ស្របតាមប្រទេសនីមួយៗ ហើយដោយប្រើការវិភាគទិន្នន័យប្រវត្តិសាស្ត្រ ដែលបានប៉ាន់ស្មានពីទំនាក់ទំនងរវាងអថេរម៉ាក្រូសេដ្ឋកិច្ច និងហានិភ័យតណទាន និងការខាតបង់តណទាន។

សំវិធានធនលើការបាត់បង់

តារាងខាងក្រោមបង្ហាញពីការផ្លៀងផ្ទាត់សមតុល្យដើមគ្រា និងចុងគ្រារបស់សំវិធានធនលើការខាតបង់តាមថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ៖

	នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025			
តណាទានផ្តល់ដល់អតិថិជន តាមថ្លៃដើមរំលស់	**ដំណាក់កាលទី 1 ដុល្លារអាមេរិក**	**ដំណាក់កាលទី 2 ដុល្លារអាមេរិក**	**ដំណាក់កាលទី 3 ដុល្លារអាមេរិក**	**សរុប ដុល្លារអាមេរិក**
នាថ្ងៃទី1 ខែមករា	1,397,346	55,105	842,756	2,295,207
ទ្រព្យសកម្មហិរញ្ញវត្ថុបង្កើតថ្មី ឬបានទិញ	(229,613)	200,243	920,877	891,507
នាថ្ងៃទី31 ខែធ្នូ (ដុល្លារអាមេរិក)	**1,167,733**	**255,348**	**1,763,633**	**3,186,714**
នាថ្ងៃទី31 ខែធ្នូ (៣ន់រៀល)	**4,686,113**	**1,024,712**	**7,077,459**	**12,788,284**

	នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025			
តណាទានផ្តល់ដល់អតិថិជន តាមថ្លៃដើមរំលស់	**ដំណាក់កាលទី 1 ដុល្លារអាមេរិក**	**ដំណាក់កាលទី 2 ដុល្លារអាមេរិក**	**ដំណាក់កាលទី 3 ដុល្លារអាមេរិក**	**សរុប ដុល្លារអាមេរិក**
នាថ្ងៃទី1 ខែមករា	1,066,811	274,422	1,350,159	2,691,392
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ឬបានទិញ	330,535	(219,317)	(507,403)	(396,185)
នាថ្ងៃទី31 ខែធ្នូ (ដុល្លារអាមេរិក)	**1,397,346**	**55,105**	**842,756**	**2,295,207**
នាថ្ងៃទី31 ខែធ្នូ (៣ន់រៀល)	**5,624,318**	**221,798**	**3,392,093**	**9,238,208**

គ. ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យដែលមានការផ្លាស់ប្តូរតម្លៃទីផ្សារដូចជា អត្រាការប្រាក់ អត្រាប្តូររូបិយប័ណ្ណបរទេស និងតម្លៃមូលធនដែលនឹងមានផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់ធនាគារ ឬតម្លៃនៃការកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុ។ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺដើម្បីគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យទីផ្សារតាមប៉ារ៉ាម៉ែត្រដែលអាចទទួលយកបានខណៈពេលដែលមានការបង្កើនទូរប្រសិទ្ធភាពក្នុងការទទួលបានចំណូលមកវិញ។

(1) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺសំដៅលើការខាតបង់នូវចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលនៃកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្មនិងបំណុល។ ហានិភ័យអត្រាការប្រាក់ត្រូវបានចាត់ចែងតាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើប្រាក់ចំណូលពីការបណ្តាក់ទុន តម្លៃទីផ្សារ និងតម្លៃដើមនៃមូលនិធិ។ សក្តានុពលនៃការធ្លាក់ចុះចំណូលការប្រាក់សុទ្ធបណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់ដែលមិនអំណោយផលត្រូវបានត្រួតពិនិត្យដោយធៀបទៅនឹងកម្រិតហានិភ័យដែលអាចទទួលយកបាន។

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់ធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយដែលកើតឡើងមុន។

	រហូតដល់ 1 ខែ ដុល្លារអាមេរិក	> 1 - 3 ខែ ដុល្លារអាមេរិក	> 3 - 12 ខែ ដុល្លារអាមេរិក	> 1 - 5 ឆ្នាំ ដុល្លារអាមេរិក	លើសពី 5 ឆ្នាំ ដុល្លារអាមេរិក	ពុំមានការប្រាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	អត្រាការប្រាក់ %
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025								
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ក្នុងដៃ	-	-	-	-	-	59,372,297	59,372,297	-
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	9,817,435	16,177,353	30,934,428			4,423,158	61,352,374	1.5 - 6.75
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	-	549,838	-	-	-	10,202,180	10,752,018	0.3 - 1
តណទានផ្តល់ដល់អតិថិជន	4,275,430	7,590,022	7,247,639	31,523,225	29,774,969	-	80,411,285	5 - 18
ការវិនិយោគ	-	-	-	-	-	25,588	25,588	-
ទ្រព្យសកម្មផ្សេងៗ	-	-	-	-	-	1,059,020	1,059,020	-
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	-	-	-	-	7,500,000	13,797,413	21,297,413	1.03 - 1.06
	14,092,865	**24,317,213**	**38,182,067**	**31,523,225**	**37,274,969**	**88,879,656**	**234,269,995**	
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ	20,282,680	16,447,313	49,314,568	43,088,757	-	26,500,044	155,633,362	1 - 6.75
បំណុលផ្សេងៗ	-	-	-	-	-	466,213	466,213	-
បំណុលភតិសន្យា	278,205	68,022	112,165	322,293	119,901	-	900,586	6 - 7
	20,560,885	16,515,335	49,426,733	43,411,050	119,901	26,966,257	157,000,161	
សរុបគំលាតការប្រាក់	(6,468,020)	7,801,878	(11,244,666)	(11,887,825)	37,155,068	61,913,399	77,269,834	
សមមូលពាន់រៀល	**(25,956,164)**	**31,308,936**	**(45,124,843)**	**(47,705,842)**	**149,103,289**	**248,458,470**	**310,083,843**	

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់ធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយដែលកើតឡើងមុន។

	រហូតដល់ 1 ខែ ដុល្លារអាមេរិក	> 1 - 3 ខែ ដុល្លារអាមេរិក	> 3 - 12 ខែ ដុល្លារអាមេរិក	> 1 - 5 ឆ្នាំ ដុល្លារអាមេរិក	លើសពី 5 ឆ្នាំ ដុល្លារអាមេរិក	ពុំមានការប្រាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	អត្រាការប្រាក់ %
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024								
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ក្នុងដៃ	-	-	-	-	-	64,272,873	64,272,873	-
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	562,229	20,226,727	38,287,176	-	-	16,471,499	75,547,631	1.5 - 7.5
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	-	374,534	-	-	-	8,636,523	9,011,057	1.05 - 1.33
តណទានផ្តល់ដល់អតិថិជន	16,081,327	8,487,748	11,395,747	21,900,274	25,162,817	-	83,027,913	5 - 16.25
ការវិនិយោគ	-	-	-	-	-	25,588	25,588	-
ទ្រព្យសកម្មផ្សេងៗ	-	-	-	-	-	2,107,048	2,107,048	-
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	-	-	-	-	7,500,000	12,148,772	19,648,772	0.08 - 1.33
	16,643,556	**29,089,009**	**49,682,923**	**21,900,274**	**32,662,817**	**103,662,303**	**253,640,882**	
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ	20,480,624	9,353,917	58,197,559	55,833,953	-	26,281,912	170,147,965	1 - 8
បំណុលផ្សេងៗ	-	-	-	-	-	1,137,791	1,137,791	-
បំណុលភតិសន្យា	2,488	67,444	23,259	437,537	129,806	-	660,534	6 - 8
	20,483,112	9,421,361	58,220,818	56,271,490	129,806	27,419,703	171,946,290	
សរុបគំលាតការប្រាក់	(3,839,556)	19,667,648	(8,537,895)	(34,371,216)	32,533,011	76,242,600	81,694,592	
សមមូលៗ៣ន់រៀល	**(15,454,213)**	**79,162,283**	**(34,365,027)**	**(138,344,145)**	**130,945,371**	**306,876,465**	**328,820,733**	

ការវិភាគរវេទយិតភាព

ការផ្លាស់ប្តូរអត្រាការប្រាក់ 1% នៅចុងគ្រារាយការណ៍នឹងមានការកើនឡើង/(ថយចុះ) មូលធននិងចំណេញ ឬខាតតាមចំនួនដែលបានបង្ហាញខាងក្រោម។ ការវិភាគសន្មតថាការប្រាក់ទាំងអស់ជាពិសេសអត្រារូបិយប័ណ្ណបរទេសនៅថេរ។

	ចំណេញ ឬខាត		មូលធន	
	+1% កើនឡើង ដុល្លារអាមេរិក	-1% ថយចុះ ដុល្លារអាមេរិក	+1% កើនឡើង ដុល្លារអាមេរិក	-1% ថយចុះ ដុល្លារអាមេរិក
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025				
ឧបករណ៍ហិរញ្ញវត្ថុមានការប្រាក់	153,564	(153,564)	153,564	(153,564)
សមមូលៗន់រៀល	**616,252**	**(616,252)**	**616,252**	**(616,252)**

	ចំណេញ ឬខាត		មូលធន	
	+1% កើនឡើង ដុល្លារអាមេរិក	-1% ថយចុះ ដុល្លារអាមេរិក	+1% កើនឡើង ដុល្លារអាមេរិក	-1% ថយចុះ ដុល្លារអាមេរិក
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024				
ឧបករណ៍ហិរញ្ញវត្ថុមានការប្រាក់	54,520	(54,520)	54,520	(54,520)
សមមូលៗន់រៀល	**219,443**	**(219,443)**	**219,443**	**(219,443)**

(2) ហានិភ័យការប្តូររូបិយប័ណ្ណបរទេស

ហានិភ័យការប្តូររូបិយប័ណ្ណបរទេស គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុមានការប្រែប្រួល បណ្តាលមកពីការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស។

ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ

ចំនួនទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម៖

	ប្រភេទនៃរូបិយប័ណ្ណ សមមូលដុល្លារអាមេរិក			
	ខ្មែររៀល	**ដុល្លារអាមេរិក**	**ផ្សេងៗ**	**សរុប**
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025				
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	538,949	58,712,340	121,008	59,372,297
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	207,696	60,929,374	215,304	61,352,374
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	401,698	10,350,320	-	10,752,018
តណាទានផ្តល់ដល់អតិថិជន	9,131,113	71,280,172	-	80,411,285
ទ្រព្យសកម្មផ្សេងៗ	135,142	923,878	-	1,059,020
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	257,413	21,040,000	-	21,297,413
	10,672,011	**223,236,084**	**336,312**	**234,244,407**
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ	3,742,674	151,890,688	-	155,633,362
ស្ថានភាពទ្រព្យសកម្មសុទ្ធ	6,929,337	71,345,396	336,312	78,611,045
សមមូលពាន់រៀល	**27,807,429**	**286,309,074**	**1,349,620**	**315,466,124**

	ប្រភេទនៃរូបិយប័ណ្ណ សមមូលដុល្លារអាមេរិក			
	ខ្មែររៀល	ដុល្លារអាមេរិក	ផ្សេងៗ	សរុប
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024				
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	703,640	63,341,482	227,751	64,272,873
សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា	3,648,498	71,548,736	350,397	75,547,631
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	1,271,307	7,739,750	-	9,011,057
តណទានផ្តល់ដល់អតិថិជន	8,203,139	74,824,774	-	83,027,913
ទ្រព្យសកម្មផ្សេងៗ	161,048	1,946,000	-	2,107,048
ប្រាក់តម្កល់តាមបទប្បញ្ញត្តិ	99,379	19,549,393	-	19,648,772
	14,087,011	**238,950,135**	**578,148**	**253,615,294**
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ	5,950,070	164,197,895	-	170,147,965
ស្ថានភាពទ្រព្យសកម្មសុទ្ធ	**8,136,941**	**74,752,240**	**578,148**	**83,467,329**
សមមូលពាន់រៀល	**32,751,188**	**300,877,766**	**2,327,046**	**335,955,999**

ការវិភាគរវេទយិតភាព

សន្មតថា ហានិភ័យអថេរផ្សេងទៀតនៅតែថេរជានិច្ច ការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេសសម្រាប់ធនាគារនាកាលបរិច្ឆេទរាយការណ៍ត្រូវបានបង្ហាញជារូបិយប័ណ្ណជាក់លាក់របស់វានៅក្នុងតារាងខាងក្រោម៖

	ឆ្នាំ2025		ឆ្នាំ2024	
	- 1% ការថយចុះ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក	- 1% ការថយចុះ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក
ប្រាក់រៀល	(69,293)	69,293	(81,369)	81,369
ផ្សេងៗ	(3,363)	3,363	(5,781)	5,781
	(72,656)	72,656	(87,150)	87,150
សមមូលពាន់រៀល	**(291,569)**	**291,569**	**(350,779)**	**350,779**

ឃ. ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាព គឺជាហានិភ័យដែលធនាគារនឹងជួបផលលំបាក់ក្នុងការបំពេញកាតព្វកិច្ច ពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួនដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសន្ទនីយភាពកើតឡើងពីភាពមិនស៊ីគ្នាទៅនឹងពេលវេលា និងចំនួនលំហូរសាច់ប្រាក់ ដែលមាននៅក្នុងប្រតិបត្តិការនិងការវិនិយោគរបស់ធនាគារ។

ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ធនាគារគ្រប់គ្រងសន្ទនីយភាពរបស់ខ្លួនតាមរយៈគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុលដែលទទួលខុសត្រូវក្នុងការបង្កើតគោលការណ៍សន្ទនីយភាព និងត្រួតពិនិត្យសន្ទនីយភាពជាប្រចាំ។ តម្រូវការទ្រព្យសកម្មសន្ទនីយអប្បបរមាត្រូវបានបង្កើតឡើងដើម្បីធានាថា អនុបាតនៃទ្រព្យសកម្មងាយស្រួល និងបំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវទទួលបានកម្រិតអប្បបរមាគ្រប់ពេលវេលា។

តារាងខាងក្រោម សង្ខេបពីទ្រព្យសកម្ម និងបំណុលរបស់ធនាគារដោយផ្អែកលើកាលកំណត់កិច្ចសន្យាដែលនៅសល់។ លំហូរសាច់ប្រាក់ ដែលបានរំពឹងទុកលើទ្រព្យសកម្ម និងបំណុលទាំងនេះ អាចខុសជាសារវន្តពីអ្វីដែលបានបង្ហាញនៅក្នុងតារាង។

ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	រហូតដល់ 1ខែ ដុល្លារអាមេរិក	> 1 - 3ខែ ដុល្លារអាមេរិក	> 3 - 12ខែ ដុល្លារអាមេរិក	> 1 - 5ឆ្នាំ ដុល្លារអាមេរិក	លើសពី 5ឆ្នាំ ដុល្លារអាមេរិក	ពុំមានកាលកំណត់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
បំណុលហិរញ្ញវត្ថុ							
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ	20,282,680	16,447,313	49,314,568	43,088,757	-	26,500,044	155,633,362
បំណុលផ្សេងៗ	-	-	-	466,213	-	-	466,213
បំណុលភតិសន្យា	278,205	68,022	112,165	322,293	119,901	-	900,586
	20,560,885	16,515,335	49,426,733	43,877,263	119,901	26,500,044	157,000,161
សមមូលៗរៀល	**82,510,833**	**66,276,040**	**198,349,480**	**176,079,456**	**481,162**	**106,344,676**	**630,041,647**

ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	រហូតដល់ 1ខែ ដុល្លារអាមេរិក	> 1 - 3ខែ ដុល្លារអាមេរិក	> 3 - 12ខែ ដុល្លារអាមេរិក	> 1 - 5ឆ្នាំ ដុល្លារអាមេរិក	លើសពី 5ឆ្នាំ ដុល្លារអាមេរិក	ពុំមានកាលកំណត់ ដុល្លារអាមេរិក	 ដុល្លារអាមេរិក
បំណុលហិរញ្ញវត្ថុ							
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ	20,480,624	9,353,917	58,197,559	55,833,953	-	26,281,912	170,147,965
បំណុលផ្សេងៗ	-	-	-	1,137,791	-	-	1,137,791
បំណុលភតិសន្យា	2,488	67,444	23,259	567,343	-	-	660,534
	20,483,112	9,421,361	58,220,818	57,539,087	-	26,281,912	171,946,290
សមមូលៗរៀល	**82,444,527**	**37,920,978**	**234,338,792**	**231,594,824**	**-**	**105,784,696**	**692,083,817**

ដើមទុនតាមបទប្បញ្ញត្តិ

គោលដៅរបស់ធនាគារ ក្នុងការគ្រប់គ្រងដើមទុនមានន័យទូលំទូលាយជាងមូលធន ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា
- ការពារលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ដូចនេះធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

គោលការណ៍របស់ធនាគារ គឺធានាឱ្យបាននូវមូលដ្ឋានដើមទុនរឹងមាំ ដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍយូរអង្វែងនៃអាជីវកម្ម។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ភាគទុនិក ក៏ត្រូវបានទទួលស្គាល់ ហើយធនាគារបានទទួលស្គាល់នូវតម្រូវការ ដើម្បីធានាបាននូវតុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើងជាមួយនឹងប្រាក់បម្រុងកម្រិតខ្ពស់អត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ។

ដើមទុនតាមបទប្បញ្ញត្តិបង្ហាញខាងលើនេះ ត្រូវបានគណនាឡើងដោយផ្អែកតាមសេចក្តីណែនាំដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ដែលអាចមានភាពខុសគ្នាទៅលើគោលការណ៍សំខាន់ខ្លះៗ បើប្រៀបធៀបទៅនឹងគោលការណ៍ដែលបានទទួលស្គាល់ជាទូទៅដែលគ្រឹះស្ថានហិរញ្ញវត្ថុនៅប្រទេសដ៏ទៃបានអនុវត្ត។ ដូច្នេះ ព័ត៌មានអំពីដើមទុនតាមបទប្បញ្ញត្តិខាងលើ មិនសមស្របសម្រាប់អ្នកប្រើប្រាស់ដែលមិនបានទទួលពត៌មានអំពីសេចក្តីណែនាំរបស់ធនាគារជាតិ។

ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ ត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់។

28. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុ រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ។ តម្លៃសមស្របគឺជាថ្លៃដែលត្រូវទទួល ដើម្បីលក់ទ្រព្យសកម្ម ឬបានទូទាត់ដើម្បីផ្ទេរបំណុលទៅតាមលំដាប់លំដោយនៅក្នុងប្រតិបត្តិការរវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងចម្បងឬប្រសិនអវត្តមានទីផ្សារដែលមានការរីកចម្រើនបំផុតដែលធនាគារបានទទួលនៅកាលបរិច្ឆេទនោះ។ ព័ត៌មានដែលបានបង្ហាញនៅទីនេះ តំណាងឱ្យការប៉ាន់ស្មាននៃតម្លៃសមស្របនាកាលបរិច្ឆេទនៃស្ថានភាពហិរញ្ញវត្ថុ។

តម្លៃទីផ្សារដែលបានដកស្រង់ និងអាចអង្កេតបាន ហើយអាចរកបានត្រូវបានប្រើសម្រាប់វាស់វែងលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ។ នៅពេលដែលតម្លៃទីផ្សារដែលបានដកស្រង់ និងអាចសង្កេតបានមិនអាចប្រើប្រាស់បាន នោះតម្លៃសមស្របត្រូវបានប៉ាន់ស្មាន ដោយផ្អែកលើវិធីសាស្ត្រ និងការសន្មតជាច្រើនទាក់ទងទៅនឹងលក្ខណៈហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ អត្រាអប្បហារ ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់នាពេលអនាគត និងកត្តាផ្សេងៗទៀត។

ព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុមិនត្រូវបានរាប់បញ្ចូលទេ ពីព្រោះវាមិនស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 7 ៖ ការបង្ហាញឧបករណ៍ហិរញ្ញវត្ថុដែលទាមទារឱ្យមានការបង្ហាញព័ត៌មាននៃតម្លៃសមស្រប។ នេះរួមបញ្ចូលទាំងការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ និងទ្រព្យសម្បត្តិ និងបរិក្ខារ។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានដូចជាសាច់ប្រាក់ និងសាច់ប្រាក់សមមូល សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា សមតុល្យនៅធនាគារជាតិនៃកម្ពុជា ទ្រព្យសកម្មផ្សេងៗ និងបំណុលផ្សេងៗ ដែលមិនមានលក្ខណៈជាសារវន្តចំពោះការផ្លាស់ប្តូរអត្រាប្រាក់ចំណេញក្នុងទីផ្សារ ដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះ មានរយៈពេលកំណត់ជាក់លាក់។ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះ នៅកាលបរិច្ឆេទរាយការណ៍ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា

សមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុរួមមាន គណនីចរន្តដែលមិនមានការប្រាក់ និងប្រាក់បញ្ញើសន្សំ។ តម្លៃសមស្របនៃប្រាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោង។

តណទានផ្តល់ដល់អតិថិជន

តម្លៃសមស្របត្រូវបានប៉ាន់ស្មាន ដោយការធ្វើអប្បហារលើលំហូរសាច់ប្រាក់ ដែលបានប៉ាន់ស្មាននាពេលអនាគតដោយប្រើអត្រាទីផ្សារនៃការផ្តល់ហិរញ្ញប្បទានដែលមានហានិភ័យតណទាន និងកាលកំណត់ស្រដៀងគ្នា។

ហានានុក្រមតម្លៃសមស្រប

ស.រ.ហ.អ.ក 7 បញ្ជាក់ពីហានានុក្រមនៃបច្ចេកទេសវាយតម្លៃដោយផ្អែកលើ ថាតើទិន្នន័យនៃបច្ចេកទេសវាយតម្លៃទាំងនោះអាចអង្កេតបាន ឬមិនអាចអង្កេតបាន។ ទិន្នន័យដែលអាចអង្កេតបាន ឆ្លុះបញ្ចាំងពីទិន្នន័យទីផ្សារដែលទទួលបានពីប្រភពឯករាជ្យ និងទិន្នន័យដែលមិនអាចអង្កេតបាន ឆ្លុះបញ្ចាំងពីការសន្មតទីផ្សាររបស់ធនាគារ។ ចំណាត់ថ្នាក់នៃតម្លៃសមស្របមានដូចខាងក្រោម៖

- កម្រិត 1 - តម្លៃដកស្រង់ (មិនទាន់មានវិយ័តកម្មកែតម្រូវ) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុល ដូចគ្នា។ កម្រិតនេះរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធិ ដែលបានចុះបញ្ជី និងឧបករណ៍បំណុល។
- កម្រិត 2 - ទិន្នន័យក្រៅពីតម្លៃដែលបានដកស្រង់រួមបញ្ចូលក្នុងកម្រិត 1 ដែលអាចអង្កេតបានចំពោះទ្រព្យសកម្ម ឬបំណុលដោយផ្ទាល់ (ឧទាហរណ៍៖ ជាតម្លៃ) ឬដោយប្រយោល (ឧទាហរណ៍៖ កើតមកពីតម្លៃ)។
- កម្រិត 3 - ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (ទិន្នន័យដែលមិនអាចអង្កេតបាន)។ កម្រិតនេះរួមបញ្ចូលទាំងឧបករណ៍មូលធន និងឧបករណ៍បំណុលដែលមានសមាសធាតុមិនអាចអង្កេតបានជាសារវន្ត។ធនាគារ មិនមានទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របទេ។ ដោយសារពុំតម្លៃទីផ្សារដែលអាចវាយតម្លៃបាន ដូច្នេះតម្លៃសមស្របមិនមានសម្រាប់ទ្រព្យសកម្ម និងបំណុលមួយចំណែកធំរបស់ធនាគារ ឡើយ។ ដូច្នេះហើយតម្លៃសមស្របត្រូវបានសន្មតដោយគណៈគ្រប់គ្រងយោងតាមទម្រង់នៃទ្រព្យសកម្ម និងបំណុលទាំងនោះ។ តាមមតិរបស់គណៈគ្រប់គ្រងតម្លៃយោងនៃទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុដែលបង្ហាញក្នុងតារាងតុល្យការគឺជាតម្លៃប៉ាន់ស្មានដ៏សមហេតុផលសម្រាប់តម្លៃសមស្រប។

29. យថាភាពនៃពន្ធ

ប្រព័ន្ធពន្ធនៅក្នុងប្រទេសកម្ពុជា គឺត្រូវបានកំណត់លក្ខណៈដោយប្រភេទពន្ធជាច្រើននិងមានភាពផ្លាស់ប្តូរជាញឹកញាប់នៃបទប្បញ្ញត្តិដែលមានភាពមិនច្បាស់លាស់ប្រឈមគ្នានិងទាមទារអោយមានការបកស្រាយបន្ថែម។ ជាញឹកញាប់ការបកស្រាយខុសគ្នាកើតមានក្នុងចំណោមអាជ្ញាធរពន្ធ និងយុត្តាធិការ។ ពន្ធត្រូវតែត្រួតពិនិត្យឡើងវិញ និងស៊ើបអង្កេតដោយអាជ្ញាធរ ដែលអនុញ្ញាតដោយច្បាប់ក្នុងការប្រតិបត្តិការធាកពិន័យធ្ងន់ធ្ងរ ការពិន័យព្រហ្មទណ្ឌ និងការពិន័យលើការប្រាក់។ គណៈគ្រប់គ្រងជឿជាក់ថា បំណុលពន្ធត្រូវបានផ្តល់យ៉ាងគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទបញ្ជាតិនៃពន្ធ។ ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធរដែលពាក់ព័ន្ធអាចមានការបកស្រាយផ្សេងគ្នាហើយ ផលប៉ះពាល់អាចមានភាពជាសារវន្ត។

នៅថ្ងៃទី24 ខែឧសភា ឆ្នាំ2023 អគ្គនាយកដ្ឋានពន្ធដារ (ហៅកាត់ថា “អ.ព.ដ”) បានចេញលិខិតជូនដំណឹងស្តីពីការធ្វើសវនកម្មពន្ធមានកម្រិតសម្រាប់ចន្លោះពេលគិតចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2022 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំទាន់មានការឆ្លើយតបជាផ្លូវការណាមួយពី អ.ព.ដ នៅឡើយទេ ហើយគណៈគ្រប់គ្រងបានចាត់ទុកថាបំណុលពន្ធដែលអាចកើតមានពីការកំណត់ពន្ធឡើងវិញគឺស្ទើរតែគ្មាន ហើយនឹងមិនបណ្តាលឱ្យមានការខាតបង់ជាសារវន្តដល់ធនាគារនាពេលអនាគតនោះទេ។

30. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងការិយបរិច្ឆេទ

នៅថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ2026 ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសលេខ ធ39-026-118 ប្រ.ក ស្តីពីការដកអាជ្ញាប័ណ្ណធនាគាររបស់ធនាគារក្នុងស្រុកមួយ ហើយដាក់វានៅក្រោមការជម្រះបញ្ជី។

ធនាគារបានរក្សាទុកប្រាក់បញ្ញើជាមួយស្ថាប័នដែលរងផលប៉ះពាល់នេះនាកាលបរិច្ឆេទរាយការណ៍។ ដោយមើលឃើញពីភាពមិនច្បាស់លាស់គួរឱ្យកត់សម្គាល់ដែលកើតឡើងពីដំណើរការជម្រះបញ្ជី គណៈគ្រប់គ្រងបានវាយតម្លៃលើលទ្ធភាពដែលអាចទទួលបានប្រាក់បញ្ញើទាំងនេះមកវិញ និងបានទទួលស្គាល់សំវិធានធនលើការខាតបង់ដែលរំពឹងទុកចំនួន 3% នៃសមតុល្យដែលនៅសល់។

ការទទួលបានមកវិញចុងក្រោយនៃប្រាក់បញ្ញើទាំងនេះ គឺប្រឈមនឹងភាពមិនប្រាកដប្រជាជាសារវន្ត រួមទាំងលទ្ធភាពនៃប្រាក់ទទួលបាននៃការជម្រះបញ្ជី និងអាទិភាពនៃការទាមទារសំណង។ ហានិភ័យដែលមានការខាតបង់បន្ថែមគឺអាចកើតឡើងទៀត។ គិតត្រឹមកាលបរិច្ឆេទនៃការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ វិសាលភាព និងពេលវេលានៃការទទួលបានមកវិញគឺមិនអាចត្រូវបានកំណត់ដោយភាពជឿជាក់បានទេ។

គណៈគ្រប់គ្រងនឹងបន្តតាមដានលើការអភិវឌ្ឍ និងរាយតម្លៃឡើងវិញនូវសំរិធានធនលើការខាតបង់តណទានដែលរំពឹងទុក នៅពេលដែលមានព័ត៌មានបន្ថែម។

31. តួលេខប្រៀបធៀប

តួលេខមួយចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រៀបធៀប និងការបង្ហាញកំណត់សម្គាល់ដែលត្រូវបានចាត់ថ្នាក់ឡើងវិញ ដើម្បីឱ្យមានភាពសមស្របទៅតាមការបង្ហាញគណនីនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។ គណៈគ្រប់គ្រងជឿជាក់ថា ការចាត់ថ្នាក់ឡើងវិញទាំងនេះ នឹងឆ្លុះបញ្ចាំងឱ្យកាន់តែប្រសើរឡើងនូវលក្ខណៈនៃប្រតិបត្តិការទាំងនោះ។

សេចក្តីសង្ខេបនៃការប្រែប្រួលដែលកើតចេញពីការចាត់ថ្នាក់ឡើងវិញ ត្រូវបានបង្ហាញដូចខាងក្រោម៖

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

2024	ដូចបានបង្ហាញពីមុន ដុល្លារអាមេរិក	ផលប៉ះពាល់ពីការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ដូចបានចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក
ទ្រព្យសកម្ម			
ទ្រព្យសកម្មអរូបី	1,059,643	908,993	1,968,636
ទ្រព្យសម្បត្តិ និងបរិក្ខារ	1,632,145	(908,993)	723,152

របាយការណ៍លំហូរសាច់ប្រាក់

2024	ដូចបានបង្ហាញពីមុន ដុល្លារអាមេរិក	ផលប៉ះពាល់ពីការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ដូចបានចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ			
ការទិញទ្រព្យសកម្មអរូបី	(9,388)	(310,627)	(320,015)
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ	(444,767)	310,627	(134,140)

32. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ត្រូវបានអនុម័តឱ្យបោះផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី30 ខែមីនា ឆ្នាំ2026។

លេខយោង៖ GA/0036/0326/C054-0053/KMT

របាយការណ៍សវនករឯករាជ្យជូនចំពោះភាគទុនិកនៃ ធនាគារ កម្ពុជា អាស៊ី ចំកាត់

របាយការណ៍ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ កម្ពុជា អាស៊ី ចំកាត់ (ហៅកាត់ថា “ធនាគារ”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត ដូចដែលបានបង្ហាញពីទំព័រទី6 ដល់ 76។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “ស.រ.ទ.ហ.អ.ក”)។

មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “ស.ស.អ.ក”)។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដាទាំងនោះត្រូវបានរៀបរាប់បន្ថែមនៅក្នុងកថាខណ្ឌស្តីពី ទំនួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល គឺមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

ឯករាជ្យភាព

យើងខ្ញុំមានភាពឯករាជ្យពីធនាគារ ដោយអនុលោមទៅតាម ក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ (រាប់បញ្ចូលទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ដែលចេញផ្សាយដោយក្រុមប្រឹក្សាក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ (ហៅកាត់ថា “ក្រមសីលធម៌អន្តរជាតិ”) ដែលអាចអនុវត្តបានចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពផ្តល់ប្រយោជន៍ សាធារណៈ និងតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំ បានបំពេញទំនួលខុសត្រូវក្នុងផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដោយអនុលោមទៅតាមតម្រូវការទាំងនេះ។

ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករ

ក្រុមប្រឹក្សាភិបាលរបស់ធនាគារ មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍ក្រុមប្រឹក្សាភិបាល និងព័ត៌មានហិរញ្ញវត្ថុបន្ថែម ដែលបានតម្រូវដោយធនាគារជាតិនៃកម្ពុជា ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរបាយការណ៍សវនករ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករឯករាជ្យនេះ និងផ្នែកផ្សេងទៀតដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ គឺរំពឹងថានឹងត្រូវបានផ្តល់ឱ្យយើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនេះ។

មតិសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មិនគ្របដណ្តប់លើព័ត៌មានផ្សេងៗ ហើយយើងខ្ញុំក៏មិនបញ្ចេញមតិសន្និដ្ឋានធានាណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ និងទន្ទឹមនឹងនេះពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ឬការយល់ដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ឬបើមិនដូច្នោះទេមានការរាយការណ៍ខុសជាសារវន្ត។

ប្រសិនបើផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្តលើព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករឯករាជ្យ យើងខ្ញុំសន្និដ្ឋានថាមានការរាយការណ៍ខុសជាសារវន្តទៅលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំចាំបាច់ត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានការរាយការណ៍ខុសជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការរាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅនឹងបញ្ហានោះដោយអនុលោមទៅតាមតម្រូវការនៃ ស.ស.អ.ក 720 (បានធ្វើការកែតម្រូវ)។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានភារៈទទួលខុសត្រូវលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក។ ក្រុមប្រឹក្សាភិបាល ក៏ទទួលខុសត្រូវផងដែរ ចំពោះការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារឱ្យជៀសផុតពីការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬភ័ន្តច្រឡំ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលមានភារៈទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងបិទអាជីវកម្មរបស់ធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យណាផ្សេងក្រៅពីធ្វើបែបនេះ។

ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងដែលសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទាំងមូល ពុំមានការរាយការណ៍ខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬភ័ន្តច្រឡំ និងផ្តល់នូវរបាយការណ៍សវនកររ ដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផល គឺជាអំណះអំណាងក្នុងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា សវនកម្មដែលធ្វើឡើងដោយអនុលោមទៅតាម ស.ស.អ.ក តែងរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើង ដោយសារការក្លែងបន្លំ ឬភ័ន្តច្រឡំ ត្រូវបានចាត់ទុកថា ជាសារវន្ត ប្រសិនបើការរាយការណ៍ខុសតែមួយ ឬរួមបញ្ចូលគ្នាត្រូវបានរំពឹងថានឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយពឹងផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាម ស.ស.អ.ក យើងខ្ញុំតម្រូវឱ្យអនុវត្តនូវការវិនិច្ឆ័យដែលប្រកបដោយ វិជ្ជាជីវៈ និងរក្សានូវការសង្ស័យស្របតាមវិជ្ជាជីវៈក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់ និងវាយតម្លៃហានិភ័យនៃការរាយការណ៍ខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដោយសារតែការក្លែងបន្លំ ឬភ័ន្តច្រឡំ រៀបចំ និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួល ភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការរាយការណ៍ខុសដែលកើតឡើងពីការភ័ន្តច្រឡំ ដោយសារការក្លែងបន្លំអាចរួមបញ្ចូលទាំងការ ឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា បំណកស្រាយមិនពិត ឬការបំពានលើនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ស្វែងយល់អំពីនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធិភាពនៃនីតិវិធីគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ។
- វាយតម្លៃលើភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។

ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យ សម្រាប់និរន្តរភាពអាជីវកម្មរបស់ក្រុមប្រឹក្សាភិបាល និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនច្បាស់លាស់ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌ ដែលអាចធ្វើឱ្យមានភាពមិនប្រាកដប្រជាជាសារវន្ត ទៅលើលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ ទៅលើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ឬប្រសិនបើការបង្ហាញព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវធ្វើការកែប្រែមតិសវនកម្មរបស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើងខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យធនាគារបញ្ឈប់និរន្តរភាពអាជីវកម្ម។

- រាយតម្លៃលើការបង្ហាញជាទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ទានាតាមលក្ខណៈដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនក្រុមប្រឹក្សាភិបាលក្នុងចំណោមបញ្ហាផ្សេងៗ ស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលរួមមានចំណុចខ្វះខាតនៃនីតិវិធីគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក**



ឧកញ៉ា Tan Khee Meng
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ធនាគារ កម្ពុជា អាស៊ី
ការិយាល័យកណ្តាល៖ អគារលេខ ៧៥សេ.០៣៦ វិថីព្រះសីហនុ សង្កាត់វាលវង់
ខណ្ឌ៧មករា រាជធានីភ្នំពេញ។
(+855)23 980 000 www.cab.com.kh